OLD VERSION

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jan-2015, 12:46
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅជំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៣០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ៊័ង

លោក ម៉ាធូវ ម៉ាកាធី
*(Mr. Matthew McCARTHY)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក សាលីម ណាកចាវ៉ានី
*(Mr. Salim Nakhjavani)*

លោក ត្រាវិស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារក្តីលោក នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក សួន វិសាល

**មេធាវីការពារក្តីលោក ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោក យីគាំង លូ *(Mr. Yiqiang LIU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សួន វិសាល | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក មាស សុខា (2-TCW-936) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី: មាស សុខា** (2-TCW-936)


សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ............ ទំព័រ ៧

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្ដើមពី ............ ទំព័រ ៣៤

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ............ ទំព័រ ៣៧

សួរដោយលោក ពេជ អង្គ ផ្ដើមពី ............ ទំព័រ ៤៣

សួរដោយលោក សួន វិសាល ផ្ដើមពី ............ ទំព័រ ៥០

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ............ ទំព័រ ៦៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះផ្ដើមបន្តធ្វើសវនាការពិភាក្សាការដេញដោលពិនិត្យភស្តុតាងលើសំណុំរឿង០០២/០២។ ហើយជាបឋមនេះ អង្គជំនុំជម្រះសូមជម្រាបជូនទៅភាគី និងសាធារណជនជ្រាបថា នៅក្នុងការបន្តស្ដាប់សាក្សីដែលមានរហស្សនាម 2-TCW-936។ ក្នុងកិច្ចដំណើរការសវនាការនេះ ហើយនៅថ្ងៃនេះនឹងអាចថ្ងៃបន្តបន្ទាប់ លោកចៅក្រម យូរ ឧត្តរា ដែលជាចៅក្រមជាតិអវត្តមានដោយមូលហេតុគាត់មានបញ្ហាសុខភាព គាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន។ បន្ទាប់ពីយើងខ្ញុំបានពិភាក្សាពិគ្រោះយោបល់ជាមួយនឹងបណ្ដាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិ ជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលបានអវត្តមាន រហូតដល់ពេលណាដែលលោកចៅក្រម យូរ ឧត្តរា មានវត្តមាននិងអាចមានលទ្ធភាពបំពេញការងារក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ដែលសេចក្ដីសម្រេចនេះដោយផ្អែកតាមបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

លោកស្រី សែ កុលវុឌ្ឍី រាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅក្នុងថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ហើយចំណែកសាក្សី 2-TCW-936 និងដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-296 មានវត្តមាននៅបន្ទប់រង់ចាំៗកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្ដើមសវនាការលើភស្តុតាងក្នុងសំណុំរឿង

០០២/០២ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥។ សវនាការនៅវគ្គដំបូងនៃសំណុំរឿង០០២/០២ គឺពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ រួមទាំងការប្រព្រឹត្តលើពុទ្ធសាសនិកជន និងមន្ទីរសន្តិសុខក្រាំងតាចាន់។ នៅថ្ងៃទី ០៨ ខែមករា ២០១៥ អង្គជំនុំជម្រះបានចាប់ផ្តើមសវនាការស្តាប់សាក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-936។ មុនប្រកាសផ្អាកសវនាការដោយជនជាប់ចោទ ខៀវ សំផន មានបញ្ហាសុខភាពនិងត្រូវទទួលការព្យាបាលនៅឯមន្ទីរពេទ្យ។ ជនជាប់ចោទ ខៀវ សំផន បានចេញពីមន្ទីរពេទ្យនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥។ អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងអ្នកជំនាញដើម្បីធ្វើការវាយតម្លៃលើសម្បទាក្នុងការចូលរួមសវនាការរបស់លោក ខៀវ សំផន និង លោក នួន ជា។

ការវាយតម្លៃដោយអ្នកជំនាញវេជ្ជសាស្ត្រចំពោះជនជាប់ចោទទាំងពីរ បានចាប់ផ្តើមនៅដើមសប្តាហ៍នេះ។ ហើយរបាយការណ៍វេជ្ជសាស្ត្រជាភាសាអង់គ្លេសនឹងត្រូវធ្វើឡើងនៅថ្ងៃនេះ ហើយនិងត្រូវប្រគល់ជូនភាគីយ៉ាងឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។ សំណៅបកប្រែនឹងប្រគល់ជូនមេធាវីការពារក្តីជនជាប់ចោទនៅថ្ងៃស្អែកជាភាសាខ្មែរនិងភាសាបារាំង។ សវនាការលើសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទត្រូវបានកំណត់ធ្វើនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ ខាងមុខនេះ។ អង្គជំនុំជម្រះបង្គាប់ឲ្យភាគីទាំងអស់ជូនដំណឹងមកអង្គជំនុំជម្រះត្រឹមថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ វេលាម៉ោងបីរសៀល ថាតើខ្លួនមានបំណងចង់ឲ្យមានសវនាការលើសម្បទារបស់ជនជាប់ចោទដូចបានបញ្ជាក់ខាងលើនេះដែរឬទេ។

[០៩:០៧:២៨]

ថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនឹងបន្តសវនាការដេញដោលភស្តុតាងក្នុងសំណុំរឿង០០២/០២ និងស្តាប់សក្ខីកម្មសាក្សី មាស សុខា ជាបន្តទៀតប្រសិនបើមានពេលវេលាសេសសល់អង្គជំនុំជម្រះនឹងចាប់ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-296។ មុននឹងស្តាប់សក្ខីកម្មសាក្សីអង្គជំនុំជម្រះសាលាដំបូងត្រូវដោះស្រាយបញ្ហាមួយចំនួនជាមុនសិន។ ១) បញ្ហាមេធាវីប្រចាំការ។ ជាដំបូងអង្គជំនុំជម្រះសាលាដំបូងសូមរំឭកដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះសម្រេចបដិសេធចោលសំណើសុំឲ្យពិចារណាឡើងវិញលើសេចក្តីតែងតាំងមេធាវីប្រចាំការសម្រាប់ ខៀវ សំផន ដោយសារពុំមានកាលៈទេសៈ ឬទឡ្ហីករណ៍ថ្មីណាមួយ ត្រូវបានលើកឡើងដែលខុសពីអ្វីដែលអង្គជំនុំជម្រះបានពិចារណារួចហើយទេ។ អង្គជំនុំជម្រះសូមរំឭកដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះបានសម្រេចបដិសេធចោល សំណើសុំឲ្យកែប្រែទីកន្លែងអង្គុយក្នុងសាលសវនាការក្នុងចំណោមមេធាវី

ការពារក្តីផងដែរ។

អង្គជំនុំជម្រះសូមយកឱកាសនេះបញ្ជាក់បំភ្លឺជាពិសេសដល់ ខៀវ សំផន អំពីតួនាទីរបស់មេធាវីប្រចាំការ។ សេចក្តីលម្អិតបន្ថែមសូមមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤, ឯកសារE321/2។ ជាសង្ខេបអង្គជំនុំជម្រះបានសម្រេចថា ការប្រព្រឹត្តរបស់មេធាវីការពារក្តី ខៀវ សំផន បច្ចុប្បន្នដែលបានធ្វើឲ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីសវនាការ គឺជាកំហុសវិជ្ជាជីវៈ។ ហេតុដូច្នេះអង្គជំនុំជម្រះបានចាត់វិធានការចំនួនបីផ្សេងៗគ្នា។ ទី១ គឺទណ្ឌកម្មតាមវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង។ អនុលោមតាមវិធាននេះ អង្គជំនុំជម្រះស្នើសុំមិនឲ្យបង់កម្រៃសេវាការពារ ក្តីមួយចំនួន។ ទី២ អនុលោមតាមវិធាន៣៨(២) នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះសម្រេចបញ្ជូនកំហុសវិជ្ជាជីវៈការពារក្តីទៅកាន់អង្គភាពមានសមត្ថកិច្ច។ ទី៣ ដែលជាវិធានការផ្សេងពីវិធានការពីរខាងលើនេះ គឺអង្គជំនុំជម្រះបង្គាប់ឲ្យមានការតែងតាំងមេធាវីការពារក្តីប្រចាំការ ដើម្បីរៀបចំនឹងត្រៀមខ្លួនក្នុងការបន្តការការពារក្តីដល់ ខៀវ សំផន នៅគ្រប់ពេលទាំងអស់ បើសិនអង្គជំនុំជម្រះសម្រេចថា វាជាការចាំបាច់ក្នុងការជំនួសមេធាវីការពារក្តីបច្ចុប្បន្ន។ វិធានការនេះគឺដើម្បីធានានូវដំណើរការសមស្របនៃការស្វែងរកយុត្តិធម៌ ដោយធ្វើយ៉ាងណាកុំឲ្យមានការរារាំងដល់ការជំនុំជម្រះ ដោយសារតែកំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្តីនាពេលខាងមុខប្រសិនបើមាន។

[០៩:១០:៥៤]

តួនាទីរបស់មេធាវីប្រចាំការ គឺកើតចេញដោយផ្ទាល់ពីហេតុផលដំបូងនៃការតែងតាំងពួកគេប្រការដែលសំខាន់បំផុត គឺថាពួកគេនឹងត្រូវស្តាប់ នឹងត្រូវស្គាល់សំណុំរឿង និងសារណាទាំងឡាយរបស់ភាគីក្នុងសំណុំរឿង០០២ ឲ្យបានច្បាស់ និងបានឆាប់រហ័ស។ មេធាវីប្រចាំការក៏ត្រូវចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ ដើម្បីស្គាល់នូវការវិវត្តន៍ទាំងឡាយនៅក្នុងសំណុំរឿងក្តីនេះ។ ការស្គាល់ច្បាស់គ្រប់គ្រាន់អំពីសំណុំរឿងក្តីនេះ និងកិច្ចដំណើរការនីតិវិធី គឺជាលក្ខខណ្ឌបឋមចាំបាច់ក្នុងការជំនួសមេធាវីការពារក្តីបច្ចុប្បន្នដោយរលូន ប្រសិនបើចាំបាច់។ ហេតុដូច្នេះ មេធាវីប្រចាំការគឺមិនមែនកំពុងជំនួសមេធាវីការពារក្តីបច្ចុប្បន្ននៅពេលនេះទេ។ មេធាវីប្រចាំការនឹងមិនចូលរួមដោយសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលនេះឡើយ។ ការជំនួសនៅពេលអនាគត ប្រសិនបើមានគឺអាស្រ័យទៅលើសេចក្តីសម្រេចមួយបន្ថែមទៀតពីសំណាក់អង្គជំនុំជម្រះសាលាដំបូងនេះ។

២) សំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យទទួលយកផែនទី

ដែលពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់។ អង្គជំនុំជម្រះសាលាដំបូងនឹងដោះស្រាយសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំឱ្យទទួលយកផែនទីដែលជាឯកសារថ្មីធ្វើជាភស្តុតាងដែលសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីមានចេតនាយកមកប្រើប្រាស់ក្នុងពេលសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-296។ មេធាវីការពារក្ដី ខៀវ សំផន បានជំទាស់នឹងសំណើនេះនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មិនមានភាពចាំបាច់ក្នុងការទទួលយកសារណាបន្ថែមទៀតទេ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឯកសារដែលត្រូវបានស្នើសុំនេះមិនមានប្រយោជន៍អ្វីដល់ការស្វែងរកការពិតនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធចោលសំណើសុំនេះ ដោយមូលហេតុសំណើសុំមិនបានបំពេញតាមលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។

[០៩:១៣:៣០]

៣) សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំតាំងសំណួរទៅអ្នកជំនាញក្នុងអំឡុងពេលសវនាការលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ។ បញ្ហាចុងក្រោយនេះ គឺពាក់ព័ន្ធទៅនឹងសវនាការលើសម្បទាជនជាប់ចោទ ដែលអាចនឹងធ្វើនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤។

អង្គជំនុំជម្រះសាលាដំបូងបានទទួលសារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានបញ្ជាក់ថា ពួកគេគប្បីមានលទ្ធភាពតាំងសំណួរទៅអ្នកជំនាញដែលត្រូវបានចាត់តាំង។

អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា ស្របតាមទម្លាប់អនុវត្តពីមុនមក សហមេធាវីនាំតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវបានអនុញ្ញាតឱ្យតាំងសំណួរទៅអ្នកជំនាញដែលត្រូវបានចាត់តាំងដោយអនុលោមទៅតាមវិធាន៩១(២) នៃវិធានផ្ទៃក្នុង ដរាបណាពួកគេសួរសំណួរដែលពាក់ព័ន្ធទៅនឹងការវាយតម្លៃវេជ្ជសាស្ត្រទៅលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ។

ឥឡូវនេះ យើងបន្តសវនាការស្ដាប់សក្ខីកម្មសាក្សី មាស សុខា។ ហើយតុលាការបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការនាំសាក្សី មាស សុខា ចូលមកកន្លែងអង្គុយផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្ត

ការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**អ្នកបកប្រែ៖**

ជម្រាបលោកប្រធាន មេក្រូហ្វូនរបស់សហព្រះរាជអាជ្ញាអត់ទាន់បានបើក។ អ្នកបកប្រែអត់អាចស្តាប់បានបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការពិនិត្យបញ្ហានេះមើល បើគាត់មានភ្លើងក្រហមហើយ ម៉េចក៏មានបញ្ហាទៀត?

**អ្នកបកប្រែ៖**

បាទ អ្នកបកប្រែនៅតែអត់ស្តាប់គាត់ឮនៅឡើយ លោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

បាទ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអ្នកបច្ចេកទេសប្រព័ន្ធសំឡេងដើម្បីរៀបចំជួសជុល។

[០៩:១៧:១៧]

*(មានបញ្ហាបច្ចេកទេស)*

[០៩:២១:៤៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រី ចៅក្រម។ កូនក្តីរបស់ខ្ញុំចង់សុំអនុញ្ញាតទៅបន្ទប់តាមដាននៅខាងក្រោមដើម្បីសម្រួលដល់ការតាមដានរបស់គាត់បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ តាមប្រព័ន្ធសោតទស្សន៍ ដោយ នួន ជា លះបង់សិទ្ធិមានវត្តមាន ដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាត ឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ច

ដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍នៅក្នុងថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ។ ហើយអង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់ជូនមកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការដោយមានចុះហត្ថលេខា និងផ្តិត ឬផ្តិតស្នាមម្រាមដៃយ៉ាងច្បាស់លាស់របស់លោក នួន ជា ផង។ ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចបន្តតាមដាន កិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមស្ថិតនៅក្រោមសវនាការនេះក្នុងរយៈពេលនៃការអនុញ្ញាតនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមចុះ។

[០៩:២៤:២០]

បាទ ដោយសារតែយើងបានទទួលព័ត៌មានពីខាងអ្នកបច្ចេកទេសរៀបចំប្រព័ន្ធសំឡេងនៅក្នុងបន្ទប់សវនាការនេះ តាមរយៈមន្ត្រីច្បាប់ មន្ត្រីរដ្ឋបាលថាលទ្ធភាពដែលអាចរៀបចំឲ្យដំណើរការវិញបានត្រូវចំណាយពេលប្រហែលជាកន្លះម៉ោងឯណោះ។ ដូច្នេះយើងមិនអាចរង់ចាំ អង្គុយនៅទីនេះរង់ចាំរហូតដល់កន្លះម៉ោងទេ ដូច្នេះគឺអង្គជំនុំជម្រះប្រកាសសម្រាក ផ្អាកសវនាការនេះសិនរយៈពេលរហូតដល់លទ្ធភាពដែលអាចធ្វើបានទំនងជាកន្លះម៉ោងក្រោយ គឺយើងចូលវិញនៅវេលាម៉ោងដប់បាទ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ០៩:២៥ នាទី ដល់ម៉ោង ១០:០០ នាទី)*

[១០:០០:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ហើយអង្គជំនុំជម្រះ

សូមជម្រាបបញ្ជាក់ថាដោយសារមានមូលហេតុរអាក់រអួលច្រើនលើកច្រើនសា ដូច្នេះអង្គជំនុំជម្រះផ្តល់ឱកាសពេលវេលាក្នុងការសួរសាក្សីរូបនេះ សហព្រះរាជអាជ្ញា រួមនឹងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺរហូតដល់អាហារថ្ងៃត្រង់។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី មាស សុខា សូមអរគុណដែលលោកអញ្ជើញមកតុលាការម្តងទៀត ហើយយើងដឹងថាសក្ខីកម្មរបស់លោកហ្នឹងត្រូវបានកាត់ផ្តាច់ម្តងពីរដង ហើយយើងខ្ញុំសូមកោតសរសើរ ហើយនៅដើមខែនេះលោកបានរៀបរាប់ថាក្រុមគ្រួសារទាំងមូលរបស់លោកត្រូវបានខ្មែរក្រហម ចាប់នៅខែមិថុនា ឆ្នាំ១៩៧៦ ដែលថាមានការប្រជុំមួយក្រោយមកគេបានប្រមូលស្នាមមេដៃ ហើយដើម្បីនឹងចាប់ប្រធានភូមិ ហើយយើងបានផ្អាកពីចំណុចនោះ ហើយយើងបានសួរលោកអំពីការដែលលោកទៅដល់មន្ទីរអប់រំក្រាំងតាចាន់ ហើយលោកបានរៀបរាប់ថាមានអគារបីដែលគេឃុំខ្លួនអ្នកទោសនៅទីនោះ ហើយគេបានដាក់ឃុំខ្លួនលោកភ្លាមនៅពេលដែលលោកបានទៅដល់ទីនោះ ហើយខ្ញុំនឹងសួរលោកបន្តពីចំណុចនេះ ហើយនិងសួរសំណួរលោកតទៅទៀតឱ្យលោករៀបរាប់ប្រាប់តុលាការអំពីអគារដែលគេឃុំខ្លួនលោកនៅពេលដែលលោកបានទៅដល់ក្រាំងតាចាន់នោះតើនៅក្នុងអគារណា?

[១០:០២:៤១]

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំទៅដល់ក្រាំងតាចាន់ចូលទៅអគារទី១ ពេលវេលាម៉ោងបួនរសៀល ហើយគេដាក់ខ្នោះម្តាយខ្ញុំនិងបងស្រីខ្ញុំតែពីរនាក់ ប្អូនតូចៗ រូបខ្ញុំគេអត់ដាក់ខ្នោះទេ គេឱ្យនៅអង្គុយនៅលើជាមួយនឹងម្តាយខ្ញុំនិងបងស្រី។

**ស៖** សូមលោករៀបរាប់ តើអគារនោះមានលក្ខណៈដូចម្តេចនៅខាងក្នុង? ថាតើអគារហ្នឹងទំហំប៉ុនណា? តើមានអ្នកទោសមុននៅទីនោះស្រាប់ដែរឬទេ?

**ឆ៖** អគារនោះមានបណ្តោយ១២ម៉ែត្រ ទទឹង៥ម៉ែត្រ។ មនុស្សគេដាក់មុនខ្ញុំក្នុងម្នាក់ៗ អគារ - - ខ្ញុំចូលទៅឃើញមនុស្សជាង២០នាក់ ក្នុងម្ខាងជាង១០នាក់ ម្ខាងជាង១០នាក់ ជើងជាប់ខ្នោះ ខ្លះជាប់ខ្នោះដៃ ខ្លះខ្នោះជើង។

**ស៖** ចំពោះអ្នកទោសដែលជាប់ខ្នោះជើងហ្នឹង តើគេដាក់ខ្នោះរបៀបម៉េច? សូមលោករៀបរាប់ប្រាប់តុលាការផង។

**ឆ៖** វិធីដាក់ខ្នោះជើងគេឲ្យអង្គុយលើក្ដារកម្ពស់ពីដីកន្លះម៉ែត្រ -- បីតឹក ហើយគេដាក់ខ្នោះដែកសរសៃមូល បណ្ដោយ ក្ដាររនាបហ្នឹងបណ្ដោយផុតផ្ទះ១២ម៉ែត្រហ្នឹង ហើយអ្នកទោសត្រូវរអូសដែកសរសៃចូលខ្នោះដែកកជើងខ្លួនឯង។

[១០:០៥:00]

**ស៖** លោកបានផ្ដល់សក្ខីកម្មថា រូបលោក ហើយនិងក្មេងៗផ្សេងទៀត គេមិនដាក់ឃុំខ្លួន ហើយនិងដាក់ខ្នោះទេ ក៏ប៉ុន្ដែម្ដាយ ហើយនិងបងស្រីរបស់លោកត្រូវបានគេដាក់ខ្នោះ។ ចុះតើនៅពេលយប់គេបានដាក់ខ្នោះអ្នកទោសដែរឬទេពេលដែលគេឲ្យអ្នកទោសដេកជាដើមហ្នឹង?

**ឆ៖** អ្នកទោសទាំងអស់នោះ ទាំងស្រីទាំងប្រុស គេដាក់ទាំងយប់ទាំងថ្ងៃ ខ្នោះជើងអត់មានដែលដោះទេ ទោះមានពេលធ្វើការងារបានគេដោះលែងទៅឲ្យធ្វើការ ហើយពេលបាយគេចូលមកដាក់ខ្នោះវិញ។

**ស៖** នៅក្នុងសក្ខីកម្មកាលពីដើមខែនេះ លោកបានប្រាប់តុលាការថាសមាជិកក្រុមគ្រួសាររបស់លោកគឺគេចាប់ខ្លួនទាំងអស់ មានទារក កុមារអាយុបីឆ្នាំក៏គេបញ្ជូនទៅដែរ។ តើគេធ្វើដូចម្ដេចចំពោះទារកនិងកុមារតូចៗនោះ នៅពេលដែលគេបញ្ជូនទៅដល់ក្រាំងតាចាន់? តើគេឲ្យនៅក្នុងមន្ទីរឃុំឃាំងហ្នឹងដូចរូបលោកដែរឬទេចំពោះកុមារនិងក្មេងអាយុបីឆ្នាំជាដើមហ្នឹង?

**ឆ៖** ក្មេងទារកបីឆ្នាំ បីខែ ពីរខែហ្នឹង នៅជាមួយម្ដាយ អត់មានឲ្យឃ្លាតពីម្ដាយ ព្រោះម្ដាយជាអ្នកបំបៅដោះ ដល់ពេលម្ដាយអត់ទឹកដោះអត់អាហារ ក៏ក្មេងហ្នឹងវាស្គមវាស្គាំង វាអឹមបានតិចតួចអ៊ីចឹងទៅ ដល់ពេលគេដោះម្ដាយលែងឲ្យធ្វើកន្ទេលក្នុងមួយថ្ងៃបានមួយ ក្នុងរយៈមួយខែបានគេដោះលែង។ ម្ដាយខ្ញុំ និងបងស្រីខ្ញុំ ហើយរូបខ្ញុំ ដោះចេញពីក្នុងអគារជាប់ខ្នោះហ្នឹងទៅ ឲ្យជួយបំពេញការងារខាងក្រៅគុក ក្រៅអគារហ្នឹងក្នុងមួយថ្ងៃៗហ្នឹង ពេលយប់គេបញ្ជូនឲ្យចូលក្នុងគុកវិញ។

**ស៖** តាមដែលខ្ញុំយល់ តើត្រឹមត្រូវដែរឬទេ គឺមិនមានកន្លែងផ្សេងសម្រាប់ដាក់ទារក ហើយនិងក្មេងៗនោះទេ គឺគេដាក់រួមជាមួយឪពុកម្ដាយរបស់គេនោះឯង។ តើអ៊ីចឹងដែរឬទេលោកសាក្សី?

**ឆ៖** ពិតមែន ក្នុងទារកម្ដាយ -- ប្អូនខ្ញុំ និងក្មួយខ្ញុំនៅជាមួយម្ដាយរហូតទល់ដល់ថ្ងៃគ្នាដាច់ទឹកដោះស្លាប់តែម្ដង ព្រោះប្អូនបីនាក់ហ្នឹងត្រូវស្លាប់ វាអត់អាហារ អត់ទាំងទឹកដោះ។

[១០:០៨:១០]

**ស៖** ឥឡូវនេះ ខ្ញុំនឹងសួរបន្ថែមទៀតអំពីលក្ខខណ្ឌ អំពីការរស់នៅ នៅក្រាំងតាចាន់។ តើលោកអាចប្រាប់តុលាការបានទេ រូបលោក ហើយនិងអ្នកទោសផ្សេងទៀត ដែលគេឃុំខ្លួននៅក្រាំងតាចាន់គេឲ្យអាហារប៉ុន្មានពេលក្នុងមួយថ្ងៃ ហើយគេឲ្យទឹកហូបរបៀបណាដែរ?

**ឆ៖** អាហារហូបចុកនៅក្នុងក្រាំងតាចាន់ ខ្ញុំជម្រាបដល់លោកតុលាការឲ្យច្បាស់លាស់ថា ក្នុងមួយពេលគេឲ្យហូបបបរមួយវែកក្រឡូងតូច អង្ករយ៉ាងច្រើន១០គ្រាប់ ដំឡូងបីដុំប៉ុនៗម្រាមដៃយើង ហើយព្រលឹតបីកំណាត់ហ្នឹង សម្លអត់មានអំបិលប្រៃទេ សាប។ វាមានជាតិអំបិលដែរ ប៉ុន្តែខ្ញុំអត់ទ្រាំហូបក្នុងរយៈមួយៗសប្តាហ៍ ហើយបានខ្ញុំហេវពេក ខ្ញុំចេះតែហុតៗទឹកហ្នឹងទៅ។ បែរទឹកផឹកវិញ ទឹកគេដងគ្រលុកជី ក្បែរគ្រលុកជីចម្ងាយដែល កន្លះម៉ែត្រពីគ្រលុកជី ហើយទឹកហ្នឹងក្រហមរបៀបចេញជីពីក្នុងគ្រលុកជីហ្នឹង។ ក្នុងមួយថ្ងៃគេឲ្យផឹកតែពីរដងទេ ផឹកពីរដងយ៉ាងច្រើនបីក្អៀកចុះ កុំឲ្យតែស្ងួតកក្នុងមួយថ្ងៃ។

**ស៖** តើរៀងរាល់ថ្ងៃ គេឲ្យបរិភោគអាហារប៉ុន្មានពេលដែរ?

**ឆ៖** គឺអាហារ វាមានហូបតែពីរពេល ប៉ុន្តែវាអត់គ្រប់គ្រាន់។ វាខ្វះខាតយ៉ាងច្រើនជាទីបំផុតក្នុងអាហារហូបចុកហ្នឹង។ វាទ្រាំហេវក្នុងមួយថ្ងៃ បានតែពីរពេលមែន ប៉ុន្តែបូកសរុបថា ក្នុងមួយថ្ងៃអង្ករយ៉ាងច្រើនប្រហែលជា២០ ទៅ៣០គ្រាប់ចុះ ក្នុងមួយថ្ងៃ ហើយដំឡូងប្រាមួយដុំចុះ ក្នុងមួយថ្ងៃហូបពីរពេល។

**ស៖** តើរោង ឬអគារដែលគេឃុំខ្លួនម្តាយ ឬបងស្រីរបស់លោក និងរូបលោកនោះ តើជាមានលក្ខណៈស្អាតធម្មតា ឬក៏ដូចម្តេច?

**ឆ៖** អគាររោងសម្រាប់ឃុំឃាំងមនុស្ស វាសត្វសង្កើចរាប់ *(ឮមិនច្បាស់)* ក្នុងទះមួយដៃលើក្តារហ្នឹងទៅ ប្រមូលសង្កើច សឹងតែមួយទូកដៃក្នុងមួយយប់ៗ។ បើអ្នកទោសណាដេករើបម្រាស់ ក្នុងអគារហ្នឹង យប់ឡើង គេអ្នកយាមសួរថាអ្នកណារើ? ហើយបើអត់ឆ្លើយ គឺដំបងគល់ឫស្សីចូលមកវ៉ៃទូទៅទាំងអ្នកទោស អត់រើ និងទាំងអ្នករើ។ អ្នករើហើយ អត់ឆ្លើយ គឺវ៉ៃទូទៅតែម្តង។

[១០:១១:៣២]

**ស៖** លោកបានបញ្ជាក់ប្រាប់តុលាការថា អ្នកទោសទាំងអស់ គេបានឃុំខ្លួន។ ថាតើ -- តើអ្នកទោសដែលឃុំខ្លួន ដែលជាប់ខ្នោះជារៀងរហូតអ៊ីចឹង តើពេលដែលគេបត់ដៃ ឬក៏ទៅបន្ទប់បត់ជើងធំអី

តើគេធ្វើដូចម្ដេចនៅពេលនោះ?

**ឆ៖** អ្នកទោសឃុំខ្លួននៅក្នុងនោះ គេមានប៊ីដុងមួយសម្រាប់ដាក់យកទឹកនោម និងលាមក ហើយគេមានត្រឡោកមួយសម្រាប់ឲ្យយើងងើបជុះ ទាំងជើងជាប់ខ្នោះទាំងអស់ហ្នឹង ងើបជុះផ្អៀងខ្លួនបន្តិចទៅ ហើយហុចបន្តគ្នា យកទៅចាក់ក្នុងប៊ីដុងដាក់ទឹកនោមហ្នឹង ហើយលាមកហ្នឹង បន្តគ្នាហុចរហូតទៅដល់កន្លែងប៊ីដុងហ្នឹង។

**សៈ** លោកសាក្សី ថាតើ តើញឹកញាប់ប៉ុនណាដែលអ្នកដែលគេឃុំខ្លួននៅក្នុងក្រាំងតាចាន់នោះបើអ្នកណាឈឺ តើគេអាចបានទទួលការព្យាបាលដូចម្ដេចដែរ?

**ឆ៖** រឿងឈឺព្យាបាល គ្មាន មានតែទុកឲ្យងាប់នៅក្នុងកន្លែង។ អត់មានអ្នកណាជួយព្យាបាលទេ។ អត់មានពេទ្យ អត់មានគ្រូឬខ្មែរឯណាចូលទៅមើលបាន អត់មាន។ ឈឺដឹងតែស្លាប់នៅទីនោះ។

**សៈ** នៅពេលដែលលោកនៅក្រាំងតាចាន់ តើលោកបានឃើញអ្នកទោសណាម្នាក់ ឬក៏ប៉ុន្មាននាក់ដែលបានស្លាប់ដោយសារអត់អាហារ ដោយសារជំងឺដែរឬទេ? បើសិនជាបានឃើញ តើលោកបានឃើញញឹកញាប់ប៉ុនណាដែរ?

[១០:១៣:៣៦]

**ឆ៖** ឃើញសឹងរាល់ថ្ងៃ អ្នកអត់អាហារ អ្នកឈឺងាប់ ត្រូវរួចខ្លួន ហើយអត់អាហារ ស្លាប់ទៅវាមានច្រើនដែរ វាមិនមែនបួនដប់នាក់ទេ ច្រើន។ ពេលវ៉ៃសួរចម្លើយ ហើយដល់ដាច់អាហារអ៊ីចឹងទៅត្រូវស្លាប់ សឹងរាល់តែយប់ មួយយប់មួយ មួយយប់ពីរអ៊ីចឹងទៅ មុននឹងយកទៅសម្លាប់។

**សៈ** តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើគេឃុំខ្លួនលោកនៅក្រាំងតាចាន់ អស់រយៈពេលយូរប៉ុនណាដែរ?

**ឆ៖** ឃុំខ្លួនរូបខ្ញុំ ជាមួយម្ដាយខ្ញុំ ក្នុងក្រាំងតាចាន់ ពីឆ្នាំ១៩៧៦ រហូតទៅដល់ឆ្នាំ១៩៧៨ ខែ៨ គេយកទៅដាក់នៅត្រៀមសហករណ៍មួយ ត្រៀងធ្វើ ក្រែងដល់ថ្ងៃណាគេប្រមូលយកទៅវិញ។ គេធ្វើបណ្ដោះអាសន្ន។ រយៈជិតបីឆ្នាំ ខ្វះតែពីរខែទៀតទេ បីឆ្នាំ។

**សៈ** នៅក្នុងបទសម្ភាសន៍ទៅការិយាល័យសហចៅក្រមស៊ើបអង្កេតឯកសារ D25/31 ខ្មែរទំព័រ 00163518 ហើយអង់គ្លេស 00223501 ហើយបារាំង ERN 00178117។ លោកបាននិយាយថាសមាជិកក្រុមគ្រួសាររបស់លោកប្រាំនាក់បានស្លាប់នៅក្រាំងតាចាន់ ហើយប្រាំពីរនាក់ទៀតបាននៅរស់។ តើលោកអាចប្រាប់តុលាការបានទេថា ប្រាំនាក់ដែលស្លាប់នោះ គឺអ្នកណាខ្លះដែលស្លាប់នៅក្រាំង-

តាចាន់ ហើយស្លាប់ដោយរបៀបណា? ស្លាប់នៅពេលណា? ក្រោយពីឃុំខ្លួនរយៈពេលប៉ុន្មានណាបាទ?

[១០:១៦:១៨]

**ឆ៖** ឪពុកខ្ញុំស្លាប់មុនគេ ព្រោះខ្ញុំមិនបានឃើញរូបគាត់ទេ គ្រាន់គេអ្នកធ្វើការពន្ធនាគារគេប្រាប់ថា ឪពុកអ្ហែងគេសម្លាប់នៅទីនេះហើយអត់មានយកទៅណាទេ រយៈមុនអ្ហែងមកបីថ្ងៃ។ ហើយប្អូនៗខ្ញុំតូចវាបានរយៈបីខែបានវាស្លាប់ ព្រោះវាដាច់ជាតិទឹកដោះ អត់អាហារហ្នឹងតាមក្រោយរូបខ្ញុំទាំងអស់គ្នាអ្នករស់នៅ។

**ស៖** លោកមាស សុខា ឥឡូវនេះ ខ្ញុំនឹងសួរសំណួរមួយចំនួនទៀតអំពីការងារដែលគេឲ្យអ្នកទោសទៅធ្វើការ ទៅធ្វើនៅក្រាំងតាចាន់នៅក្នុងកំណត់ហេតុ អូ.ស៊ី.អាយ.ជេ នោះគឺថាឯកសារ D25/31 ខ្មែរទំព័រ 00163514 រហូតទៅដល់ 155, អង់គ្លេស 00223497 ហើយបារាំង ERN 00178113 រហូតទៅដល់ 4។ ហើយនៅក្នុងផ្នែកនេះលោកបាននិយាយថា អំពីរយៈពេល២០ ទៅ២៥ថ្ងៃ ក្រោយពីលោកទៅដល់ក្រាំងតាចាន់ ហើយម្តាយរបស់លោកត្រូវបានបំបែកពីលោក ហើយគេឲ្យទៅធ្វើការ ហើយនៅល្ងាចគេបានបញ្ជូនបងស្រី ហើយនិងម្តាយរបស់លោក បញ្ជូនមកដាក់ខ្នោះវិញ។ ហើយនៅចំណុចមួយទៀត សួរថាតើបងស្រីរបស់លោក ហើយនិងម្តាយរបស់លោកត្រូវបានគេដាក់ខ្នោះជើង ឬក៏ដាក់ខ្នោះឃុំខ្លួនរហូតពេញមួយពេលដែលគេទុក គេឃុំខ្លួនគាត់នៅក្រាំងតាចាន់ហ្នឹងដែរឬទេ?

**ឆ៖** បងស្រីខ្ញុំ ហើយម្តាយខ្ញុំ គេឃុំខ្លួនទាល់ដល់ថ្ងៃ ពេលយប់គេឃុំដាក់ខ្នោះជើងម្ខាង ហើយដល់ពេលថ្ងៃគេនឹងឲ្យគាត់មកដាំបបរឲ្យអ្នកទោស ហើយបងស្រីខ្ញុំទៅរែកដីដំបូក ឬដីបាតត្រពាំង។ យប់ឡើង គេឲ្យគាត់មកចូលដេកក្នុងអគារគុកហ្នឹងវិញ ហើយយប់ឡើងគេដាក់ខ្នោះ។

[១០:១៩:១៣]

**ស៖** ចំពោះរូបលោកផ្ទាល់វិញ តើគេឲ្យលោកធ្វើការងារអីដែរនៅក្រាំងតាចាន់កាលនោះ គេប្រើឲ្យធ្វើអ្វី?

**ឆ៖** រូបខ្ញុំផ្ទាល់គេឲ្យខ្ញុំមើលតែគោ ហើយនិងក្របីប្អូន គោពីរតែប៉ុណ្ណឹងទេ។ ហើយមើល ដើរដល់ណាក៏ដើរទៅ ប៉ុន្តែយប់ឡើងគេឲ្យខ្ញុំចូលក្នុងបរិវេណគុកហ្នឹងវិញមុនម៉ោងប្រាំ។

**ស៖** តើលោកអាចរៀបរាប់ថាតើបរិវេណគុកនោះ តើគេឲ្យលោកអាចចេញឃ្វាលគោនិងក្របីហ្នឹងអាចនៅចម្ងាយប៉ុន្មាន នៅក្នុងបរិវេណណា ឬក៏មិនឲ្យហួសពីកន្លែងប៉ុន្មាន លោកអាចពណ៌នាបានទេ?

**ឆ៖** ខ្ញុំពណ៌នាបាន។ ខ្ញុំគេឲ្យឃ្វាលគោ ឃ្វាក្របី គេអត់មានហាមឃាត់ខ្ញុំដល់ត្រឹមម៉ានៗទេ គេឲ្យនិយាយពីត្រឹមឲ្យគោឆ្អែត ក្របីឆ្អែត។ អ្នកឯងឃ្វាលដល់ណាក៏ឃ្វាលទៅ ប៉ុនដឹងតែម៉ោងប្រាំមួយ ម៉ោងប្រាំហ្នឹង ត្រឡប់មកដល់វិញ។ យប់ឡើងដើរផ្លុងកង្កែប ដើរផ្ទះត្រីជាមួយគេ។

**ស៖** នៅពេលដែលគេឲ្យលោកធ្វើដំណើរទៅកន្លែងណាខ្លះបាននៅក្នុងបរិវេណគុក? តើលោកបានឃើញពីអ្វីៗដែលគេប្រព្រឹត្តចំពោះអ្នកទោសផ្សេងទៀតទេ នៅពេលដែលគេយកអ្នកទាំងនោះចេញពីរោង ឬក៏កន្លែងឃុំខ្លួនទៅកន្លែងណាមួយ? តើលោកបានសង្កេតឃើញដូចម្ដេចខ្លះ?

[១០:២១:២១]

**ឆ៖** នៅឆ្នាំ៧៦ ខ្ញុំនៅជាប់ក្នុងពន្ធនាគារ ខ្ញុំអត់ទាន់បានតាមដានពិនិត្យសកម្មភាពអ្វីទេ ក៏ប៉ុន្តែខ្ញុំចាប់តាមដានពីឆ្នាំ៧៧ សកម្មភាពសម្លាប់មនុស្ស។ សម្លាប់មនុស្សខ្ញុំតាមដានពេលគេយកប្រជាជនពីភូមិស្រែននោង ឃុំញ៉ែងញ៉ង មកដាក់នៅទីធ្លាគុកក្រាំងតាចាន់។ វាមិនអាចដាក់ក្នុងគុកនោះអស់មនុស្សមួយរយជាងនាក់ ហើយគេក៏ជីករណ្ដៅហើយ។ នៅក្នុងនោះរណ្ដៅជម្រៅ៣ម៉ែត្រ ទំហំ៥ម៉ែត្របួនជ្រុង។ ហើយបានគេបញ្ជូនមនុស្សទាំងជាងមួយរយនាក់នោះ ទៅម្ដងពីរ ម្ដងបី ម្ដងបួន ទាំងក្មេងទាំងចាស់ ទាំងមនុស្សខ្វិន ទាំងមនុស្សខ្វាក់ ពេលនោះខ្ញុំឃើញផ្ទាល់នឹងភ្នែក ដើរ ខ្ញុំឃ្វាលគោ អត់ទាន់យប់ទេ អាហ្នឹង វានៅម៉ោងបួនរសៀល ចាប់ គេចាប់ផ្ដើមបន្តសម្លាប់មនុស្សពីម៉ោងបួនរសៀលហ្នឹង។ ខាងត្បូងត្រពាំងមួយ ចម្ងាយពីបរិវេណ និយាយរួមក្នុងហ្នឹង វាបរិវេណគុកទាំងអស់ ដីគុកហ្នឹង។ ប៉ុន្តែគ្រាន់តែហាមមនុស្សក្រៅពីអ្នកទោសដែលធ្លាប់ជាប់នៅក្នុងហ្នឹង អត់ឲ្យដើរជិត ឬអ្នកណាមួយដែលគ្មានដឹងហេតុការណ៍អី អត់ឲ្យដើរចូលទេ ហាមដាក់ខាត។ បើអ្នកនោះប៊ានតែដើរចូលក្នុងទីបរិវេណនោះក៏អ្នកហ្នឹងត្រូវតែស្លាប់ខ្លួននៅទីនោះដែរ។ ហើយមុននឹងសម្លាប់ គេនឹងបានចាក់មីក្រូឡើងកងរំពងយ៉ាងទ្រហឹងអឺងកង ពុំឲ្យអ្នកណាស្ដាប់ឮបន្តិចសោះ។ គេវាយនឹងស្ករ គោះជញ្ជាំង គោះប៉ោត ទូងទាំង បន្លប់កុំឲ្យមនុស្សឮ។

[១០:២៣:៥០]

**ស៖** សូមអរគុណលោកសាក្សីដែលលោកបានរៀបរាប់។ ខ្ញុំនឹងត្រឡប់មកចំណុចនេះពីរបីនាទីទៀត ដើម្បីសួរពីការសម្លាប់មនុស្ស ប៉ុន្តែពេលនេះខ្ញុំសូមសួរលោកបន្តិចអំពីការសួរចម្លើយអ្នកទោស។ ពេលដែលលោករៀបរាប់អំពីបរិវេណក្រាំងតាចាន់នៅក្នុងសក្ខីកម្មនៅដើមខែនេះ លោកបានបញ្ជាក់ថាមានកន្លែងមួយសម្រាប់គេសួរចម្លើយអ្នកទោស។ សូមលោកប្រាប់ខ្ញុំមើលថាតើកន្លែងហ្នឹងនៅកន្លែងណា

នៅក្នុងបរិវេណៗនោះ ជាកន្លែងដែលលោកបានឃើញគេយកអ្នកទោសទៅសួរចម្លើយនោះបាទ?

**ឆ៖** កន្លែងសួរចម្លើយអត់ឆ្ងាយពីអគារគុកហ្នឹងទេ ចម្ងាយដី៥០ម៉ែត្រ ពីទីតាំងគុកដាក់ឃុំឃាំងមនុស្ស ចម្ងាយ ហើយអ្នកកន្លែងស្លាប់ហ្នឹងក៏មិនឆ្ងាយ នៅក្បែរៗគ្នា។ ពេលគេសួរចម្លើយ គេ -- ទីតាំងគេមានដំបង មានច្រវាក់ មានទាំងពីពូថៅ មានទាំងដែកកាប់ ពេលគេសួរគេវ៉ៃនឹងគល់ឫស្សី និងថ្នោងផ្តៅទូងទាំង ស្រែកពេញកន្លែងអគារ កន្លែងសួរចម្លើយហ្នឹងទៅ ខ្លះគេឆ្លើយ ខ្លះគេអត់ឆ្លើយ។

**សៈ** តើខ្លួនលោកផ្ទាល់តើគេធ្លាប់យកលោកទៅសួរចម្លើយដែរឬទេ?

**ឆ៖** រូបខ្ញុំផ្ទាល់គេអត់សួរទេ ចម្លើយ ព្រោះក្មេង គឺថាសួរតែចាស់ សួរមេគ្រួសារ ដឹងថាគ្រួសារអត់មានសួរទេរឿងក្មេង។

[១០:២៦:០៨]

**សៈ** លោកបានរៀបរាប់ប្រាប់ខ្ញុំ និងតុលាការអ្វីដែលកើតឡើងនៅពេលសួរចម្លើយនោះហើយ ហើយនៅក្នុងចម្លើយនៅការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង ពេលនោះគេសួរលោកថា៖ "តើលោកបានឃើញគេសួរចម្លើយដែរឬទេ? លោកបានឃើញ។ ដោយសារគេមិនបានយកលោកទៅសួរចម្លើយ តើហេតុអ្វីក៏លោកអាចបានឃើញផ្ទាល់ៗ ហើយបានស្តាប់ឮពីការសួរចម្លើយហ្នឹងច្បាស់ម្ល៉េះ?

**ឆ៖** ព្រោះគេសួរចម្លើយ កន្លែងកណ្តាលវាលអាចមើលឃើញ ហើយខ្ញុំហ្នឹងអាចដើរចេញចូលកៀនហ្នឹងបាន ព្រោះខ្ញុំ គេសម្រាប់ប្រើដូចដើរទៅបេះអំពិល ដូចជាបេះម្លូរ អ្វីៗ បេះជី បេះខ្ទឹម យកឲ្យកន្លែងគេអ្នកដាំស្ល ពួកខាងអង្គរក្សការពារហ្នឹង គេប្រើខ្ញុំព្រោះបន្លែបង្ការចង្ក្រានបាយពួកគេហូបចុកនៅក្បែរហ្នឹង អត់ឆ្ងាយពីកន្លែងគេហូបចុក ព្រោះខ្ញុំចេញចូលយកម្ហូបម្ហាទៅឲ្យគេ រកបានអីចឹងយើងហុចឲ្យគេទៅ។ ចម្ងាយពីគ្នា ៥ម៉ែត្រពីចង្ក្រានបាយគេ ហើយឲ្យខ្ញុំមិនឃើញម៉េច! ព្រោះខ្ញុំភ្នែក ខ្ញុំមើលទៅក៏គេមិនឃាត់ -- ឃាំងឃាត់អីដែរ គ្រាន់តែគេហាមខ្ញុំថា "បើអ្នែងឃើញហើយ ដឹងហើយ ឮហើយចេញទៅក្រៅតែ អ្នែងនិយាយរឿងអ្វីមួយថាកន្លែងនេះជាសួរចម្លើយមនុស្ស វាយមនុស្ស វាយទូងទាំងវាយបែកក្បាលហូរឈាម ប្រយ័ត្នអ្នែងមានរឿង" គេគ្រាន់តែហាមខ្ញុំតែប៉ុណ្ណឹងទេ។

**សៈ** សូមលោកប្រាប់ខ្ញុំថាតើគេបានវាយអ្នកទោស ឬក៏គេធ្វើទារុណកម្មអ្នកទោសទេនៅពេលដែលសួរចម្លើយ? បើសិនជាគេបានវាយឬធ្វើទារុណកម្ម ថាតើគេវាយឬធ្វើទារុណកម្មដោយរបៀបណា?

**ឆ៖** អ្នកទោសសួរចម្លើយគេវាយនឹងគល់ឫស្សី នឹងថ្នោងផ្តៅសួរចម្លើយ ពេលសួរចម្លើយ។ អីចឹងគេចាប់ដង្កាប់ ក្រចកដៃ។

[១០:២៨:៤៤]

**សៈ** នៅក្នុងចម្លើយដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនោះ នៅក្នុងឯកសារ D25/31 ខ្មែរ ERN 00163518 ហើយអង់គ្លេស 00223500 ហើយនិងបារាំង ERN 00178116 លោកបានឆ្លើយដូចតទៅនេះអំពីការសួរចម្លើយ ខ្ញុំសូមដកស្រង់សម្តីរបស់លោក៖ "គេបានសួរថាតើអ្នកឯងបានធ្វើអ្វី? តើអ្នកឯងជា ស៊ី.អ៊ី.អា អាមេរិកាំង ឬក៏ សេ.អ៊ី.អា យួន? តើអ្នកឯងធ្វើអ្វី? មានមុខងារអ្វីនៅក្នុងសម័យលន់នល់? ហើយនៅពេលដែលគេឆ្លើយ ឬក៏មិនឆ្លើយគេបានវាយរហូតដល់សន្លប់ ហើយគេធ្វើទារុណកម្ម។ គេយកថង់ប្លាស្ទិកគ្របក្បាលអ្នកទាំងអស់នោះ អ្នកទោសនោះ"។ ចប់សេចក្តីដកស្រង់។ ខ្ញុំសួរថា តើហេតុអ្វីបានជាលោកដឹងថាគេសួរចម្លើយអំពីតំណែងឋានៈរបស់គេនៅក្នុងរបបលន់ នល់?

**ឆៈ** ព្រោះខ្ញុំនៅតែក្បែរហ្នឹង ព្រោះខ្ញុំឮគេសួរ "អ្អែងធ្វើអីជំនាន់ដែលនៅជាមួយលន់ នល់ អ្អែងស័ក្តិ៣ ឬស័ក្តិ៤ ឬស័ក្តិ៥ អ្អែងផ្កាយប៉ុន្មាន ផ្កាយ៣ ផ្កាយ៤ អ្អែងធ្វើ សេ.អ៊ី.អា អាមេរិកាំង ឬ សេ.អ៊ី.អា យួន? អ្អែងឆ្លើយឲ្យត្រង់មើល៍ បើអត់ឆ្លើយ អ្អែង វៃអ្អែងងាប់ហ្នឹងឥឡូវ"។ គេសួរតែអ៊ីចឹងៗ អត់មានសួរខុសពីរឿងហ្នឹងទេ អ្នកទោស។

[១០:៣០:៥១]

**សៈ** លោកបានរៀបរាប់អំពីអ្នកទោសដែលគេច្រកស្បោងកៅស៊ូ។ តើលោកឃើញគេច្រកស្បោងកៅស៊ូអ្នកទោសហ្នឹង ឬមួយក៏យ៉ាងម៉េចដែរ? លោកឃើញផ្ទាល់ភ្នែកដែរឬទេ?

**ឆៈ** ស្បោងកៅស៊ូ គេកម្រច្រកណាស់។ ទោសអ្នកមិនឆ្លើយ បានគេច្រក។ ខ្ញុំឃើញតែម្តងទេ ច្រកស្បោងកៅស៊ូ ឃើញតែម្តងច្រកបានប្រហែលជា៥នាទី មិនទាន់ផង អ្នកនោះឆ្លើយ ឆ្លើយហើយគេវៃបន្តទៀត។

**សៈ** លោកសាក្សី ខ្ញុំចង់អានឲ្យលោកស្តាប់នូវសម្រង់មួយដែលជាកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត គឺឯកសារ D25/30 ហើយសម្រង់ដែលខ្ញុំដកស្រង់គឺមានលេខ 00163506, ភាសាអង់គ្លេសមានលេខ 00223489-490, បារាំងមានលេខ 00178425-426។ នៅក្នុងចម្លើយរបស់ម្តាយរបស់លោកហ្នឹង គឺម្តាយរបស់លោកបានឆ្លើយដូចតទៅនេះ៖ "សំណួរ៖ នៅពេលដែលគេឃុំខ្លួនអ្នកស្រី តើគេសួរចម្លើយអ្នកស្រីដែរឬទេ? ចម្លើយ៖ ចាស គឺគេសួរចម្លើយខ្ញុំ សួរចម្លើយដោយប្រធាននិងអនុប្រធាន"។ ហើយបន្តមកទៀត៖ "ឌុច តូចបានចេញបញ្ជា ចំណែកឌុចធំ គឺជាអ្នកថែរក្សា

គឺជាអ្នកកត់ត្រា"។ ខ្ញុំចង់សួរថាតើគេអ្វីនៅក្នុងសំណួរនោះ? ហើយចម្លើយគឺថា -- គឺគេសួរអំពីហេតុផលដែលមិនមានអាហារគ្រប់គ្រាន់នៅក្នុងសហករណ៍។ ហើយបន្តមកទៀត រហូតមកខាងក្រោម។ "សំណួរ៖ តើគេសួរអ្នកស្រីយូរដែរឬទេ? ចម្លើយគាត់ឆ្លើយថា៖ គេសួរយូរ។ សំណួរ៖ តើគេមានធ្វើបាបអ្នកស្រីទេ? ចម្លើយអត់ទេ ប្រសិនយើងឆ្លើយត្រង់ គេអាចធ្វើបាបទេ"។ លោក សុខា តើម្ដាយរបស់លោកធ្លាប់ប្រាប់លោកអំពីការដែលគេសួរចម្លើយគាត់នៅក្រាំងតាចាន់ដែរឬទេ?

[១០:៣៣:៣៨]

**ឆ៖** គេដែលសួរគាត់ដែរ សួរពីរឿងឪពុកខ្ញុំនិងរូបគាត់។ "តើរស់នៅពីរបបនោះ តើស្រឡាញ់របបកុម្មុយនីស្ដ ឬរបបសេរី" ពេលដែលគាត់ប្រាប់ខ្ញុំ។ ហើយសួរថាឪពុកខ្ញុំហ្នឹងមានកូនក្រមុំមួយសម្រាប់បង្ហាញឲ្យចៅហ្វាយខេត្តតាកែវ ពីជំនាន់ដែល៦៨-៦៩ហ្នឹង -- ៦៧ហ្នឹង គេបានមកឈប់ពីមុខផ្ទះម្ដាយខ្ញុំហ្នឹង សួររកផ្លូវណាទៅកន្លែងគេធ្វើធារាសាស្ត្រទឹក ហើយឪពុកខ្ញុំក៏បានចង្អុលប្រាប់ថាកន្លែងផ្លូវកែងមួយទៅជើង គេធ្វើធារាសាស្ត្រនោះ ហើយបានគេចាក់ស្រាឲ្យឪពុកខ្ញុំមួយពែង ហើយឪពុកខ្ញុំក៏គាត់អត់ចេះហូប គាត់គ្រាន់តែទទួលកែវហ្នឹងហុចឲ្យគេទៅវិញ គេអរគុណ គេទៅរហូតបាត់ទៅ។ ហើយបានបន្តមក គេថាអ្នកឯងជាគិញសម្ងាត់សម្រាប់រាជការបានមិនចូលធ្វើបដិវត្តន៍នឹងគេ។

**ស៖** តើលោកដឹងដែរឬទេថាបងស្រីរបស់លោក ឬក៏សាច់ញាតិរបស់លោកដទៃទៀតហ្នឹងត្រូវគេសួរចម្លើយនៅពេលឃុំនៅក្រាំងតាចាន់នោះ?

**ឆ៖** ពេលគេសួរចម្លើយបងស្រីខ្ញុំ ម្ដាយខ្ញុំ ខ្ញុំអត់ដឹងព្រោះពេលនោះថ្មីៗគេដាក់ខ្ញុំនៅក្នុងគុកដែរ គេអត់លែងទេ គេអត់ទាន់លែងឲ្យខ្ញុំដើរសេរីទេ ពេលនោះខ្ញុំអត់ទាន់ដឹង ព្រោះអត់ដឹងហេតុការណ៍អីសោះកាលនោះ។ ពេលជាប់ហ្នឹង គេអត់ទាន់ឲ្យយើងខ្ញុំដើរក្រៅបានទេព្រោះគេនៅដាក់នៅក្នុងពន្ធនាគារដដែល។

**លោក ខេល លីសាក់៖**

លោកប្រធាន ក្នុងពេលនេះខ្ញុំចង់ផ្ដល់នូវឯកសារមួយគឺឯកសារមកពីមន្ទីរសន្ដិសុខក្រាំងតាចាន់ជូនទៅសាក្សី គឺឯកសារដែលមានលេខE3/4095 – E3/4095 ហើយគោលដៅដែលខ្ញុំចង់ផ្ដល់ហ្នឹងគឺថាវាមានឈ្មោះមនុស្សមួយចំនួននៅក្នុងឯកសារនេះ។ ហើយខ្ញុំចង់សួរសាក្សីទាក់ទងទៅនឹងឈ្មោះបុគ្គលទាំងអស់នេះ។ ដូច្នេះបើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំនឹងប្រគល់ឯកសារនេះជូនទៅសាក្សី។ សូមលោកប្រធានសម្រេច។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១០:៣៦:៣៧]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ចំពោះបញ្ហានេះ។ អ្វីដែលសហព្រះរាជអាជ្ញាចង់បង្ហាញ បើតាមខ្ញុំស្មាន គឺជាឯកសារថតចម្លងមួយច្បាប់ដែលយើងមិនមានឯកសារច្បាប់ដើមនោះទេ។ ដូច្នេះ ក្នុងការអះអាងក្នុងពេលឥឡូវនេះ ដែលថាបង្ហាញឯកសារនេះជូនទៅសាក្សី គឺជាឯកសារច្បាប់ដើមមកពីក្រាំងតាចាន់គឺជាការមិនត្រឹមត្រូវ ព្រោះថាវាអត់មានឯកសារច្បាប់ដើមពីក្រាំងតាចាន់នោះទេ។ សាក្សីកន្លងមកបានផ្តល់សក្ខីកម្មអំពីបញ្ហានេះហើយ ខ្ញុំមិនមានបញ្ហាអ្វីទេ ប្រសិនបើយើងធ្វើឲ្យត្រឹមត្រូវ។ បានន័យថាព្រះរាជអាជ្ញាបង្ហាញឯកសារអ្វីមួយ គឺថាវាជាឯកសារថតចម្លងអ្វីបញ្ជាក់ឲ្យច្បាស់។ ប៉ុន្តែក្នុងពេលឥឡូវនេះ ដើម្បីជាកំណត់ត្រា ខ្ញុំចង់លើកឡើងថាវាមិនមានឯកសារច្បាប់ដើមៗណាមួយពីក្រាំងតាចាន់នោះឡើយ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ឯកសារនេះគឺជាឯកសារដែលបានដាក់ចូលទៅក្នុងសំណុំរឿង ហើយបានបញ្ជាក់ថាជាឯកសារដែលទទួលបានពីក្រាំងតាចាន់ គឺជាសក្ខីកម្មដែលមានកំណត់ត្រា។ ដូច្នេះ ខ្ញុំគិតថាចំណុចនេះយើងមិនចាំបាច់ត្រូវពិភាក្សាគ្នាអំពីរឿងថាថតចម្លង ឬមិនថតចម្លងនោះឡើយ។ ប៉ុន្តែខ្ញុំសង្កេតឃើញថាឥឡូវនេះយើងមានសាក្សីនៅទីនេះ ហើយគាត់អាចនឹងមានព័ត៌មានលម្អិត ហើយវាអាចជួយយើងទាំងអស់គ្នាឲ្យបានយល់អំពីប្រធានបទក៏ដូចជាបញ្ហាទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[១០:៣៨:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំសូមអរគុណព្រះរាជអាជ្ញាដែលបានផ្តល់ចម្លើយ។ ពេលខ្លះ ប្រហែលជាពីរបីខែកន្លងមក ខ្ញុំបានទៅជួបជាមួយនឹងខាងគ្រប់គ្រងតុលាការដើម្បីពិនិត្យថាតើមានឯកសារច្បាប់ដើមឬទេ ដែលជាមូលដ្ឋាននៃការថតចម្លងនេះ។ ហើយបានបញ្ជាក់ថាមិនមានឯកសារ

ច្បាប់ដើមនៅខាងផ្នែកគ្រប់គ្រងតុលាការនោះទេ។ យើងព្យាយាមស្វែងរកថាតើៗភាគី ឬក៏ស្ថាប័នណាមួយដែលជាអ្នកបង្ហាញអំពីឯកសារនេះ ហើយដាក់ឯកសារនេះចូលទៅក្នុងសំណុំរឿង ហើយយើងរកឃើញថាប្រហែលជាមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមជ្ឈមណ្ឌល ឌី.ស៊ី.ខេម ហើយយើងបានស្នើទៅខាង ឌី.ស៊ី.ខេម ថាតើគេមានឯកសារច្បាប់ដើមឬទេ? ហើយខាងមជ្ឈមណ្ឌលឯកសារកម្ពុជាឆ្លើយថាមិនមានឯកសារច្បាប់ដើមនោះទេ។ ហើយប្រធានមជ្ឈមណ្ឌលបាននិយាយថាឯកសារច្បាប់ដើមបាត់ទៅហើយ។ ដូច្នេះកាលដែលយើងនិយាយថាយើងមានឯកសារថតចម្លងចេញពីឯកសារច្បាប់ដើមដែលច្បាប់ដើមនៅកន្លែងណាមួយនោះ គឺមិនមែនជាការពិតនោះទេ ព្រោះមិនមានឯកសារច្បាប់ដើមពីមន្ទីរក្រាំងតាចាន់ឡើយ។

**លោក ខេល លីសាក់៖**

លោកប្រធាន យើង --

**ប្រធានអង្គជំនុំ៖**

លោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគ្រាន់តែចង់បញ្ជាក់ ថាតើមេធាវីការពារក្តីចង់បានអ្វី? ប្រសិនបើខ្ញុំយល់មិនខុសទេ គឺលោកមិនមែននិយាយអំពីភាពអាចទទួលយកបាននៃឯកសារនោះទេ។ ប្រហែលជាលោកចង់និយាយថាលោកមិនមានបញ្ហាជាមួយឯកសារទេ ហើយលោកគ្រាន់តែចង់និយាយអំពីភាពច្បាប់ដើមនៃឯកសារនោះទេ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១០:៤០:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទត្រឹមត្រូវហើយ។ គឺថា យើងគ្រាន់តែចង់និយាយអំពីភាពត្រឹមត្រូវ ឬក៏ច្បាប់ដើមនៃឯកសារនេះ ព្រោះថា អាចថាជាឯកសារថតចម្លងពីឯកសារច្បាប់ដើម ឬក៏មិនមែនថតចម្លងពីឯកសារច្បាប់ដើម។ ខ្ញុំគ្រាន់តែជំទាស់ទៅលើការនិយាយបង្ហាញថា ដែលថា និយាយថា ឯកសារហ្នឹងគឺជាឯកសារថតចម្លងចេញពីឯកសារច្បាប់ដើមប៉ុណ្ណោះ។ សូមអរគុណ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំនៅតែស្តាប់មិនច្បាស់ ថាតើឯកសារហ្នឹងដាក់បញ្ចូលទៅក្នុងសំណុំរឿងហើយឬក៏នៅ? យ៉ាង

ម៉េចដែរ? ខ្ញុំគិតថាមិនមែនជាបញ្ហានៃការទទួលយកឯកសារ ឬក៏អំពីសច្ចភាព នៃឯកសារនោះដែរទេ មេធាវី កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

ព្រោះថាយើងមិនទាន់មាន យើងមិនមានឯកសារច្បាប់ដើមនៅឡើយ ហើយក៏មិនមានឯកសារច្បាប់ដើមនៅកន្លែងណាមួយនោះឡើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកជំទាស់ជាមួយនឹងភាពពិតប្រាកដនៃឯកសារហ្នឹង តើមែនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោក មាស សុខា តើលោកចេះអក្សរទេ?

**លោក មាស សុខា៖**

--ខ្លួនឯងអត់មានគ្រូបង្រៀន។ ខ្ញុំរៀនបានតិចណាស់លោកចៅក្រម និងលោកតុលាការ ព្រោះខ្ញុំអត់ដែលបានរៀនសោះ រៀនគ្រាន់តែអានកាសែតរួចតិចតួចប៉ុណ្ណឹង។ ព្រោះខ្ញុំចេញពីជំនាន់ខ្មែរក្រហម ខ្ញុំធ្វើទាហានរហូត ខ្ញុំអត់បានរៀន។

[១០:៤២:០៣]

**ប្រធានអង្គជំនុំ៖**

កម្រិតត្រឹមអានឈ្មោះមនុស្សអី លោកចេះអានបានដែរឬទេ? លោក មាស សុខា លោកនិយាយនៅពេលណាដែលក្បាលមីក្រូហ្វូនមានសញ្ញាភ្លើងក្រហម សូមលោកចាប់ផ្ដើមនិយាយ។ បើពុំដូច្នោះទេ សំឡេងរបស់លោកមិនចូលទៅប្រព័ន្ធចែកចាយសំឡេង និងអាចប្រើប្រាស់ជាផ្លូវការបានទេនៅក្នុងសាលសវនាការនេះ។ សូមរំឭកជាថ្មីម្ដងទៀត។ លោកឆ្លើយនូវសំណួររបស់យើងសាជាថ្មីម្ដងទៀត។

**លោក មាស សុខា៖**

ខ្ញុំអត់ចេះអក្សរទេ លោកតុលាការ ព្រោះខ្ញុំអត់បានរៀន ព្រោះខ្ញុំជំនាន់ខ្មែរក្រហម ក៏ខ្ញុំអត់បានរៀន ជំនាន់រដ្ឋកម្ពុជា ខ្ញុំអត់បានរៀន ព្រោះខ្ញុំធ្វើតែកងទ័ព។ ព្រោះអត់បានរៀនសោះ អានបានតិចតួច ប៉ុន្តែបើលោកតុលាការសួរពីរឿងអី ខ្ញុំអាចនឹងឆ្លើយបាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ លោកឆ្លើយនឹងសំណួរយើងហើយ។ យើងសួរថាលោកចេះអក្សរឬអត់ប៉ុណ្ណោះ។

អញ្ជើញលោកស្រីចៅក្រម ហ្វេនស៍ ឆ្លើយតបទៅនឹងសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា។ សូមអញ្ជើញ!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សោកស្ដាយដែរដែលលោកសាក្សីគាត់មិនអាចអានអក្សរបាន ប៉ុន្តែខ្ញុំចង់បញ្ជាក់ទៅលើការជំទាស់ទាក់ទងទៅនឹងបញ្ហាយថាភាព គឺមិនមែនជាបញ្ហានៃការជំទាស់ទៅលើការទទួលយកឯកសារនោះឡើយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយខ្ញុំគិតថាកំណត់ត្រា អ្វីដែលលោកបានលើកឡើងគឺកត់ចូលទៅក្នុងកំណត់ត្រារួចទៅហើយ ហើយយើងក៏បានពិចារណាផងដែរអំពីតម្លៃនៃភស្តុតាង ប៉ុន្តែដោយសារតែសាក្សីមិនអាចអានបានដូច្នេះវាអាចមានបញ្ហាបន្តិចបន្តួច។

[១០:៤៥:៥៣]

**លោក វិចទ័រ កូប៉េ៖**

បាទ នេះជាគឺជាការត្រឹមត្រូវ ប៉ុន្តែអ្វីដែលខ្ញុំលើកឡើងគឺជាបញ្ហាដែលត្រូវសាកសួរទៅលើសាក្សីព្រោះថាឯកសារនេះគឺជាឯកសារថតចម្លងមិនមែនជាឯកសារច្បាប់ដើម ហើយឯកសារច្បាប់ដើមអត់មានទេ។ អានេះមិនមែនជាបញ្ហាដូចគ្នានឹងទស្សនាវដ្ដីទង់បដិវត្តឡើយ ព្រោះខ្ញុំបានជជែកជាមួយនឹងខាងផ្នែកគ្រប់គ្រងតុលាការ ហើយអត់មានឯកសារច្បាប់ដើមណាមួយមកពីមន្ទីរក្រាំងតាចាន់នោះឡើយ។

**លោក ឌេល លីសាក់៖**

ទី១ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់លាស់ គឺខ្ញុំមិនដែលនិយាយថានេះជាឯកសារច្បាប់ដើមនោះឡើយ គឺថាគ្រាន់តែខាងមជ្ឈមណ្ឌលឯកសារបានបញ្ជាក់ថានេះជាឯកសារមកពីខាងមន្ទីរក្រាំងតាចាន់ ហើយជាឯកសារថតចម្លង។ ដូច្នេះ ទោះបីថាវាជាឯកសារថតចម្លង ប៉ុន្តែវាអាចទទួលយកបាន។ ទី២ គឺសាក្សីគាត់បានបញ្ជាក់ថាគាត់អានមិនពូកែ ប៉ុន្តែគាត់អាចអានបាន។ ដូច្នេះខ្ញុំចង់បញ្ជាក់ថា ត្រឹមតែអានឈ្មោះ ហើយនិងពិនិត្យមើលទៅលើឯកសារបន្តិចបន្តួច ហើយអាចឲ្យគាត់ពិនិត្យមើល ថាតើគាត់អាចស្គាល់ពីឯកសារ ពីក្រាំងតាចាន់នេះបានដែរក៏អត់នោះ។

[១០:៤៧:២២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

លោកប្រធាន ប្រសិនលោកប្រធានអនុញ្ញាតខ្ញុំសូមបង្ហាញនៅលើអេក្រង់ ដោយខ្ញុំនឹងសាកសួរសាក្សីអំពីបញ្ហាទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១០:៤៧:៥២]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសុខា ខ្ញុំបានរៀបចំនូវចំណុចសម្គាល់នៅលើទំព័រដែលខ្ញុំចង់សួរលោក ហើយបានគូស *ហាយឡាយ* ទៅលើផ្នែកដែលខ្ញុំចង់សួរលោកនៅលើឯកសារនោះរួចទៅហើយ។ ទី១ និយាយយោងអំពីឯកសារ E3/4095 ហើយខ្ញុំចង់សួរលោកឯកសារខ្មែរគឺមានលេខ 00271098, អង់គ្លេសមានលេខ 00747250 ហើយនិងភាសាបារាំងមានលេខ 00711219-220 ហើយប្រសិនបើលោកមើលនៅខាងស្តាំដៃនៃទំព័រនោះ គឺទំព័រជាភាសាខ្មែរ លោកនឹងមើលឃើញអំពីបុគ្គលពីររូបដែលខ្ញុំបាន *ហាយឡាយ*ជូនលោកមើលហើយ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ បុគ្គលទី១ គឺៗខ្ញុំសូមអានដូចតទៅនេះ ឈ្មោះ មុំ ហឿន អាយុ ២៨ឆ្នាំ។ ប្រពន្ធឈ្មោះ មាស សារ៉ាត់ កូនពីរនាក់។ កំណើតនៅភូមិស្រែគ្រូ ឃុំជាងទង។ ទី២ គឺឈ្មោះ មុំ ប៊ុន។

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំជម្រាបដល់តុលាការ មុំ ហឿន គឺបងថ្លៃរបស់ខ្ញុំ ហើយ មាស គុណ គឺឪពុករបស់ខ្ញុំ ហើយ មាស រតនា គឺបងស្រីបង្កើតរបស់ខ្ញុំ មាស សារ៉ាត់ ហ្នឹង មាស សារ៉ាត់ ហើយ ហ៊ុន គឹមសេង ហៅ ញ៉ គឺម្តាយរបស់ខ្ញុំ។ បន្ទាប់មករូបខ្ញុំផ្ទាល់ មាស សុខាហ្នឹងតែម្តង, បន្ទាប់មក មាស សុខុម, បន្ទាប់មក មាស សំណាង, បន្ទាប់មក មាស ញ៉ឹម, បន្ទាប់មកប្អូនតូចៗមិនទាន់ដាក់ឈ្មោះទេ ហើយបន្ទាប់មកទៀតក្មួយ សព្វថ្ងៃនៅភ្នំពេញគេឈ្មោះ ម៉ុម បេ ហៅ កន្ទេង។

[១០:៥០:៤០]

**ស៖** សូមអរគុណលោកសាក្សី។ នៅក្រោមនេះបន្តិច គឺក្រោមកំណត់ត្រាបងថ្លៃរបស់លោកគឺមានកំណត់ត្រាមួយទៀតអំពីបុគ្គលម្នាក់ឈ្មោះ មាស គុណ អាយុ៤៦ឆ្នាំ ប្រពន្ធឈ្មោះ ញ៉។ ដើម្បីជា

កំណត់ត្រាឲ្យបានច្បាស់លាស់ តើលោកអាចបញ្ជាក់បានទេថា តើឈ្មោះ មាស គុណ និងឈ្មោះ ញ៉ ហ្នឹងជាអ្នកណាដែរ?

**ឆ៖** មាស គុណ ជាឪពុករបស់ខ្ញុំបង្កើត។ ហ៊ុន គឹមសេង ហៅ ញ៉ គឺម្ដាយខ្ញុំបង្កើត។

**ស៖** ខ្ញុំគិតថាប្រហែលជាមានបញ្ហាបន្តិចថា តើ មាស គុណ ហ្នឹងជាឪពុកបង្កើតរបស់លោក តើមែនដែរឬទេ?

**ឆ៖** មាស គុណ គឺឪពុករបស់ខ្ញុំបង្កើត អត់មានក្លែងក្លាយក្លែងបន្លំ។ បើលោកតុលាការមិនជឿ ចុះទៅស៊ើបអង្កេតនៅដល់ទីនោះផ្ទាល់តែម្ដងទៅ ទៅដល់ស្រុកភូមិឃុំខ្ញុំ។

**ស៖** បងថ្លៃរបស់លោក ហើយនិងឪពុករបស់លោកគឺមាន គឺឈ្មោះពួកគាត់នៅលើទំព័រតែមួយ នៅលើឯកសារនេះ។ តើលោកអាចប្រាប់បានដែរឬទេ ថាតើនៅពេលណាដែលបងថ្លៃរបស់ ម៉ុម ហឿន ហ្នឹង ត្រូវបានគេចាប់ខ្លួន? តើគេចាប់ខ្លួនក្នុងពេលជាមួយគ្នា ជាមួយនឹងឪពុកលោក ឬក៏នៅពេលផ្សេងគ្នា?

[១០:៥២:៣២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតប។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំជំទាស់យ៉ាងខ្លាំងចំពោះការសួរបែបនេះ។ អ្វីដែលព្រះរាជអាជ្ញាព្យាយាមបង្ហាញគឺថា គាត់ផ្ដល់ព័ត៌មានឲ្យសាក្សីដឹងអំពីឯកសារទាំងអស់នេះ ហើយសង្ឃឹមថាសាក្សីគ្រាន់តែអាចឆ្លើយតបអះអាងទៅលើអ្វីដែលគាត់ចង់សួរ ហើយការធ្វើដូច្នេះ គឺថាវាជាការលាងសម្អាតឯកសារនេះ។ គាត់គួរតែសួរជាសំណួរបើកវិញអំពីថាតើអ្វីកើតឡើងចំពោះជនទាំងអស់នេះ ខ្ញុំគិតថាគាត់អាចសួរសំណួរទៅលើប្រធាននេះបាន ប្រធានបទនេះបាន ប៉ុន្តែគាត់គួរតែសួរជាលក្ខណៈបើកចំហ មិនគួរជាការផ្ដល់ព័ត៌មាន ហើយណែនាំឲ្យសាក្សីគាត់អាចឆ្លើយបែបនេះ ឬបែបនោះ បែបនេះទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំអត់មានផ្ដល់អ្វីទៅសាក្សីទេ គឺថាយើងឃើញឈ្មោះបុគ្គលទាំងពីរនេះ គឺនៅលើឯកសារជាមួយគ្នាជាប់គ្នា ហើយខ្ញុំគ្រាន់តែសួរសាក្សី ថាតើនៅពេលណាដែលបងថ្លៃរបស់គាត់ត្រូវគេចាប់ខ្លួនប៉ុណ្ណោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ហេតុអ្វីចាំបាច់សាក្សីមានឯកសារធ្វើអី? គាត់មិនចាំបាច់ត្រូវការឯកសារនោះទេ។ គាត់គ្រាន់តែឆ្លើយតាមអ្វីដែលគាត់ដឹងទៅបានហើយ។ ហេតុអីចាំបាច់ត្រូវប្រគល់ឯកសារឲ្យសាក្សី?

[១០:៥៤:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធសេចក្ដីជំទាស់នេះ ហើយអង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សីចំពោះសំណួរនេះរបស់តំណាងសហព្រះរាជអាជ្ញា។ សូមសាក្សីឆ្លើយតបនឹងសំណួរចុងក្រោយ។

**លោក មាស សុខា៖**

**ឆ៖** សំណួរព្រះរាជអាជ្ញាសួរខ្ញុំថា រឿងឪពុកម្ដាយខ្ញុំថាពិតឬមិនពិតគឺ ឪពុកខ្ញុំគឺឈ្មោះ មាស គុណ, បងថ្លៃខ្ញុំ – ម៉ុម បឿន។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី រង់ចាំសំណួរសាជាថ្មីម្ដងទៀត។ លោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដដែលហ្នឹងសាជាថ្មីម្ដងទៀតដើម្បីឲ្យគាត់ស្ដាប់យល់។ ហើយយើងរំឭកសាក្សី លោក មាស សុខា ថា សូមលោកស្ដាប់នូវសំណួរឲ្យបាន ហើយលោកគប្បីឆ្លើយតបទៅនឹងភាពចាំបាច់ទៅនឹងសំណួរដែលបានហើយ ចៀសវាងនិយាយចាកឆ្ងាយនូវភាពមិនចាំបាច់ ដែលវាមិនមែនខ្លឹមសារឆ្លើយតបទៅនឹងសំណួរដែលសួរ។ និយាយរួមឆ្លើយឲ្យចំទៅនឹងសំណួរដែលសួរ។ ស្ដាប់មិនយល់ សូមឲ្យសួរសំណួរសាជាថ្មីម្ដងទៀត។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:៥៥:៤៤]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំចង់សួរលោក សុខា ថាតើលោកដឹងដែរឬទេ ថាបងថ្លៃរបស់លោក មុំ បឿន ហ្នឹង គេចាប់ខ្លួននៅពេលណាដែរ?

**លោក មាស សុខា៖**

**ឆ៖** បងថ្លៃរបស់ខ្ញុំ គេចាប់មុនបីថ្ងៃ។ មុនបីថ្ងៃ ហើយបានក្រោយមក បានគេចាប់ឪពុកខ្ញុំ។ ឪពុកខ្ញុំរយៈមួយសប្តាហ៍ហើយបានគេចាប់ក្រុមគ្រួសារ ទាំងម្តាយខ្ញុំ ប្អូនតូចៗ និងបងស្រីខ្ញុំបន្តក្រោយ។

**ស៖** សូមអរគុណលោក សុខា។ កំណត់ត្រាមួយទៀតអំពីបងថ្លៃរបស់លោក គឺលោក មុំ ហឿន គឺនិយាយអំពីប្អូនថ្លៃមួយទៀត ឈ្មោះ មាស រ៉ា ដែលធ្វើការនៅរោងចក្រតម្បាញ នៅតាកែវ។ តើលោកមានបងប្អូនឈ្មោះ មាស រ៉ា នោះដែរឬទេ? គឺឈ្មោះ មាស រ៉ា ដែលជាបងប្រុសរបស់លោក។ តើលោកមានដែរឬទេ?

**ឆ៖** បងស្រីរបស់ខ្ញុំមាន ឈ្មោះ មាស រ៉ា ធ្វើការរោងចក្រតម្បាញ តាកែវ។

**ស៖** តើបងប្អូនរបស់លោកម្នាក់នេះ គឺជាអ្នកដែលគេចាប់ខ្លួនជាមួយលោក ជាមួយក្រុមគ្រួសារ ហើយគេយកទៅក្រាំងតាចាន់ហ្នឹង មែនទេ?

[១០:៥៧:២៧]

**ឆ៖** បងស្រីមួយហ្នឹង គេនៅធ្វើការរោងចក្រតាកែវ គេអត់មានយកចូលមន្ទីរក្រាំងតាចាន់ទេ។ គេនៅតាមសហករណ៍។

**ស៖** ដូច្នេះដើម្បីបញ្ជាក់ឲ្យច្បាស់ គឺថាមានបងស្រីរបស់លោក គឺបងស្រី មាស រ៉ា មិនត្រូវបានគេចាប់ខ្លួនទេ នៅពេលដែលសមាជិកគ្រួសាររបស់លោកនោះ ត្រូវគេចាប់ខ្លួន។ តើខ្ញុំនិយាយអីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ឯកសារបន្តដែលខ្ញុំចង់ឲ្យលោកពិនិត្យ គឺមានប្រហែលជាប្រាំបីទំព័រ នៅខាងក្រោមនោះ គឺខ្មែរមានលេខ 00271106, ភាសាអង់គ្លេសមានលេខ 00747262 ដល់263 និងភាសាបារាំងមានលេខ 00721233 ដល់234 ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់។ លោកសាក្សី នៅផ្នែកខាងឆ្វេងនៃឯកសារនេះ គឺនៅទំព័រនេះ មានកំណត់ត្រាមួយ ទាក់ទងទៅនឹងបុគ្គលដូចតទៅនេះ ឈ្មោះ ហ៊ុន សេង ភេទស្រី អាយុ៤៤ឆ្នាំ, ប្តីឈ្មោះ មាស គុណ កើតនៅភូមិស្រែគ្រូ ហើយនៅខាងស្តាំដៃនៃឯកសារដដែរនេះ គឺមានកំណត់ត្រានិយាយអំពីបុគ្គលម្នាក់ដែលគេហៅថា ឈ្មោះ មាស សារ៉ាត់ អាយុ២៤ ភេទស្រី, ប្តីឈ្មោះ មុំ ហឿន។ តើលោកអាចបញ្ជាក់បានដែរឬទេ ថាតើបុគ្គលទាំងពីរនាក់ហ្នឹង ជាអ្នកណាដែរ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយតបចាំក្បាលមីក្រូហ្វូនចាប់ផ្ដើមប្រតិបត្តិការសិនណ៎ះ!

**លោក មាស សុខា៖**

**ឆ៖** បងស្រីខ្ញុំបង្កើត មាស សារ៉ាត់ ហៅ មាស រតនា ហើយ មុំ បឿន គឺបងថ្លៃខ្ញុំតែម្ដង អត់មានក្លែងបន្លំ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយស្ត្រីម្នាក់ដែលឈ្មោះ ហ៊ុន សេង ហ៊្វឹង តើហ៊ុន សេង ហ៊្វឹងជាអ្នកណាដែរ? លោកអាចប្រាប់បានទេ?

**ឆ៖** អ្នកស្រី ហ៊ុន សេង ហ៊្វឹង គឺម្ដាយខ្ញុំបង្កើតតែម្ដង អត់ក្លែងបន្លំ។

**ស៖** លោកសាក្សី តើម្ដាយរបស់លោក ឬក៏បងស្រីរបស់លោកធ្លាប់ប្រាប់ថា អ្នកណាជាអ្នកសួរពួកគាត់នៅក្រាំងតាចាន់ដែរឬទេ គាត់ធ្លាប់និយាយដែរឬទេ?

**ឆ៖** គាត់ធ្លាប់សួរ -- ប្រាប់ខ្ញុំដែរថា តាអាន់ – ស៊ីវ អាន់ គឺប្រធានគុកក្រាំងតាចាន់តែម្ដង។ សួរម្ដាយខ្ញុំហើយ បានសួរបងក្រោយ។

[១១:០១:៣០]

**ស៖** តើលោកត្រឡប់មកខាងដើមវិញនៅខាងដើមនៃឯកសារនេះគឺE3/4095 គឺខ្មែរ00271109 ប៉ុន្តែនៅក្នុងនេះគឺជាសៀវភៅសរសេរមួយ។ នៅពេលដែលលោកនៅក្រាំងតាចាន់ តើលោកធ្លាប់បានឃើញសៀវភៅដែលមានទ្រង់ទ្រាយបែបនេះទេ ជាសៀវភៅសម្រាប់កូនសិស្សសរសេរនោះបាទ?

**ឆ៖** អត់មានទេលោកតុលាការ ខ្ញុំអត់ដែលឃើញ។

**ស៖** លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនៅលើអេក្រង់នៅប្រហែលជាពីរបីទំព័រសម្រាប់តុលាការបានពិនិត្យ ពីព្រោះថាមេធាវីបានជំទាស់លើយថាភាព ខ្ញុំចង់បញ្ជាក់ឲ្យមានកំណត់ត្រាជូនលោក លោកស្រីចៅក្រមគឺថា គឺឯកសារ TCW-900 គឺថា D239 គឺថារហូតដល់ 3033 ហើយគាត់បាន ទទួលបញ្ជីឈ្មោះអ្នកទោសពីប្រធាននៅក្រាំងតាចាន់ ដែលស្ថិតនៅក្នុង -- ដែលមានថាសៀវភៅសរសេរសម្រាប់សិស្ស ហើយគាត់បានរៀបរាប់ថា -- ហើយមានរូបកុមារនៅលើក្រប ហើយនិងមានមេលេខសម្រាប់គេសូត្រ មេលេខគុណនោះ។ ហើយនៅក្នុងក្របទំព័រនោះគឺ បញ្ជាក់ពីបញ្ហា

ដោយខ្លួនឯង គឺថាឯកសារយោងចុងក្រោយនៅក្នុងសៀវភៅនេះ ខ្ញុំចង់សួរលោក មាស សុខា នោះគឺនៅខ្មែរ 00271101 រហូតដល់ 102, ហើយអង់គ្លេស 00747254 រហូតដល់ 257, ហើយបារាំង 00711224 រហូតដល់ 227។ ទំព័រទាំងអស់នេះមានកំណត់ត្រាមួយចំនួនដែលគេបញ្ជាក់ថា អ្នករស់នៅក្នុងភូមិស្រែគ្រួដំបូងគេនោះគឺកំណត់សរសេរនៅក្នុងទំព័រខ្មែរ 00271101 កំណត់សរសេរនេះគឺស្ត្រីម្នាក់អាយុ៣៧ឆ្នាំ ថោ ស៊ិន មកពីព្រៃវែង ហើយគេបញ្ជាក់ថាបានរៀបការជាមួយអាចារ្យហ៊ុន ដែលត្រូវបានគេកម្ទេច។ សំណួរខ្ញុំសួរលោកថា តើលោកស្គាល់ស្ត្រីដែលគេហៅថា ថោ ស៊ិន នៅក្នុងឯកសារនេះដែរឬទេ? ថោ ស៊ិន បាទ។

[១១:០៥:០១]

**ឆ៖** បាទ គឺស្គាល់។ គាត់ជាម្ដាយធំជីដូនមួយខ្ញុំ ព្រោះគាត់មកពីស្រុកព្រៃវែង ឪពុក អ៎! ប្ដីគាត់ឈ្មោះ ហែម ហួន គឺជាអ្នកគ្រូអាចារ្យបាលីពីដើម។

**ស៖** នៅដើមខែនេះ នៅពេលដែលលោកឆ្លើយប្រាប់តុលាការ លោកបានបញ្ជាក់បុរសម្នាក់ជាអ្នកទោស មនុស្សម្នាក់ជាអ្នកទោស ដែលខ្ញុំជឿថា លោកហៅថា យាយស៊ីន ជាបុគ្គលម្នាក់ដែលបានប្រាប់លោកថា ឪពុករបស់លោកហ្នឹង គេបានធ្វើទារុណកម្មគាត់ ហើយគេយកគាត់ចេញទៅ។ តើស៊ិននេះ ជា ថោ ស៊ិន នេះជាមនុស្សដែលលោកហៅថា យាយស៊ីន ពេលនោះ ឬក៏គាត់ជាមនុស្សផ្សេងទេ?

**ឆ៖** អត់មានមនុស្សផ្សេងទេលោក មនុស្សតែមួយ។

**ស៖** តើម្ដាយមីង ថោ ស៊ិន គាត់បានរួចជីវិតពីក្រាំងតាចាន់ដែរទេ?

**ឆ៖** ម្ដាយធំខ្ញុំអត់បានរួចទេ គាត់ស្លាប់ទាំងពូជនៅក្នុងហ្នឹងតែម្ដង ទាំងកូនទាំងអីទាំងអស់ កូនប៉ុន្មានប្រាំមួយនាក់ ឬប្រាំនាក់ ខ្ញុំអត់បានចាំកូនទេ អត់ចាំបានកូនគាត់ប៉ុន្មានៗ ខ្ញុំថាដឹងថាប្រហែលប្រាំមួយនាក់ ទាំងប្ដីគាត់។

**ស៖** តើលោកដឹងថា ពួកគាត់ស្លាប់ដោយរបៀបណាដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងគេសម្លាប់របៀបណាទេ កាលនោះខ្ញុំនៅ គេដាក់នៅ -- ពេលថ្មីៗ គេយកខ្ញុំទៅចូលទៅក្នុងឃុំឃាំងវិញ ពេលគេសម្លាប់មនុស្ស គេអត់ឲ្យទាន់ឲ្យខ្ញុំដឹងទេ។

**ស៖** នៅក្នុងកំណត់ដៃមួយទៀតដែលនិយាយអំពី ម្ដាយមីង ថោ ស៊ិន នោះគឺមានបញ្ជាក់ឈ្មោះថាអាចារ្យហួន។ គេបញ្ជាក់ថា “កម្ទេច”។ តើលោកចងចាំនឹងឃើញរឿងអ្វីខ្លះដែរទេ អំពីអាចារ្យ ហួន? តើលោកអាចប្រាប់ជម្រាបតុលាការអំពីកាលៈទេសៈ ដែលគេចាប់ខ្លួនគាត់ ឬក៏អ្វីបន្ថែមបានទេ?

**ឆ៖** ខ្ញុំបានជម្រាបលោកតុលាការ លោក ហែម ហួន គឺគេចាប់គាត់មួយសាជាពីរសា។ លើកទី១ គេយកនៅដាក់នៅមន្ទីរ១២០៤។ បន្ទាប់មកគេលែងគាត់ត្រឡប់មកផ្ទះវិញ។ ដល់ឆ្នាំ ចុងឆ្នាំ៧៤ គេចាប់គាត់ម្តងទៀត ទៅបាត់រហូត។ ខ្ញុំអត់ដឹងរឿងហេតុការណ៍អីទេ ព្រោះគាត់កាលនោះ គាត់ធ្វើជាមន្ត្រីឃុំខាងខ្មែរក្រហមដែរ។

[១១:០៨:៤៨]

**ស៖** ថាតើលោកអាចបញ្ជាក់ថាមន្ទីរ២០៤ជាមន្ទីរអ្វីបាទ?

**ឆ៖** មន្ទីរ២០៤ គឺមន្ទីរឃុំឃាំងអ្នកទោសរាជការ លន់ នល់ ចាប់ខ្លួនពីអង្គតាសោម ពីតាកែវ ពីកន្លែងណាក៏ដោយ មន្ត្រីរាជការ ឬអ្នកមាន អ្នកក្រ។ អ្នកមាន និយាយទៅ អ្នកសក្តិភូមិ នាយទុន គេយកទៅដាក់នៅមន្ទីរនោះ នៅចំណុចខាងលិចត្រពាំងក្រញូង។

**ស៖** សូមអរគុណលោកសាក្សី។ ហើយមនុស្សចុងក្រោយដែលខ្ញុំចង់សួរលោកនៃឯកសារនេះ នៅទំព័របន្ទាប់ ខ្មែរ 00271102 បាទ 102 នៅខាងចុង ហើយនៅក្នុងខាងលើខាងស្តាំនៃទំព័រនោះគឺមានកំណត់សម្គាល់ដែលបញ្ជាក់ពីមនុស្សម្នាក់ឈ្មោះ សុក សាន អាយុ៣៨ ដែលគាត់មកពីភូមិស្រែគ្រូ។ តើលោកអាចប្រាប់តុលាការបានទេ ថាតើ សុក សាន ជាអ្នកណា? ទំនាក់ទំនងអ្វីដែរ?

**ឆ៖** សុក សាន បង សុក សុត បង្កើត គឺអ្នកស្រុក អ្នកភូមិជាមួយគ្នាជាប់សាច់សាលោហិតជាមួយ ហែម ពួន ជាក្មួយបង្កើតរបស់ហែម ហួន។

**ស៖** សូមអរគុណលោកសាក្សី។ ឈ្មោះ សុក សុត គឺបទសម្ភាសការិយាល័យសហចៅក្រមស៊ើបអង្កេត គឺD25/32 ខ្មែរ ERN00163521 ហើយនិង 525 អង់គ្លេស 00223505 ហើយនិង 508 ហើយនិងបារាំង 00178430 ហើយនិង 433។ សុក សុត បានបញ្ជាក់ថាជាសរុបគឺថា បងប្អូនបង្កើតប្រាំនាក់របស់គាត់គឺបានស្លាប់នៅក្រាំងតាចាន់ ហើយនិងប្អូនរបស់គាត់ត្រូវបានគេសម្លាប់។ ប្រហែលជាមួយពេលឪពុករបស់លោក ហើយគាត់ -- លោកបាននិយាយថា សុក សាន ហ្នឹង បាទ តើលោកចាំសមាជិកក្រុមគ្រួសាររបស់គាត់ផ្សេងទៀតទេរបស់ សុក សុត, សុក សាន នេះនៅក្រាំងតាចាន់មានឈ្មោះអ្វីខ្លះ?

**ឆ៖** កូនគាត់មានបីនាក់ ឈ្មោះ អ៊ូ សុផល – អ៊ូ សុផល ហើយសុភាព ហើយនិង រិន – រិនកូនពៅប្រុស។

[១១:១២:២៩]

**ស៖** តើកុមារទាំងអស់នោះត្រូវបានគេឃុំខ្លួននៅក្រាំងតាចាន់នោះ បន្ទាប់មកពួកគេហ្នឹងត្រូវមានបញ្ហាអ្វីដែរទេ?

**ឆ៖** កូនរបស់លោកយាយស៊ិនហ្នឹង គេឃុំរហូតដល់ថ្ងៃគេសម្លាប់ គេអត់មានបញ្ហាដោះលែងឲ្យទៅក្រៅឃុំជួយការងារគេ អត់មានទេ។

**ស៖** ខ្ញុំត្រឡប់មកសំណួររបស់ខ្ញុំវិញ ខ្ញុំចង់សួរលោកតើលោកចាំឈ្មោះបង -- បងប្អូនប្រុសរបស់ សុក សុត ដែលគេឃុំខ្លួននៅក្រាំងតាចាន់ទេ? ដែលក្រៅពី សុក សាន ហ្នឹងតើមានបងប្អូនប៉ុន្មានទៀតរបស់ សុក សុត ដែលគេយកទៅក្រាំងតាចាន់ដែរនោះបាទ?

**ឆ៖** អត់មាន បងប្អូនបង្កើតរបស់គាត់អត់មានអ្នកណាជាប់ទេ។

**ស៖** ឥឡូវនេះខ្ញុំចង់ត្រឡប់ទៅប្រធានបទអំពីការប្រហារជីវិត ឬក៏ការសម្លាប់អ្នកទោសនៅក្រាំងតាចាន់។ កាលពីព្រឹកមិញនេះលោកបានរៀបរាប់ជម្រាបតុលាការពីរបៀបដែលលោកអាចបានទៅឃើញទៅស្តាប់ឮ អំពីកាលៈទេសៈដែលគេយកអ្នកទោសទៅសម្លាប់នោះហើយ។ តើលោកអាចប្រាប់តុលាការបានទេលោកបានឃើញប៉ុន្មានដង ដែលគេយកអ្នកទោសយកទៅដាក់នៅក្បែររណ្តៅ នៅខាងក្រៅរបង ឬនៅខាងក្រៅបរិវេណគុកនោះ?

**ឆ៖** អ្នកទោសដាក់ក្រៅរបងគ្មាន ដាក់ក្នុងរបង បរិវេណដីបីហិកតាហ្នឹង គឺគេអត់ឲ្យចេញក្រៅ គេដាក់តែក្នុងបរិវេណហ្នឹង។ គេ -- ខ្ញុំ បើនិយាយរួមទៅ វាឃើញ បើត្រួតពិនិត្យទៅ ឃើញសឹងរាល់ថ្ងៃ ប៉ុន្តែគេសម្លាប់វារំលងតែ មួយសប្តាហ៍គេសម្លាប់តែម្តងៗ។

[១១:១៥:00]

**ស៖** ខ្ញុំសូមបំភ្លឺជូនលោកអំពីទីកន្លែងដែលលោកបានឃើញរណ្តៅ ហើយនិងកន្លែងដែលគេយកអ្នកទោសទៅសម្លាប់ទៅទីនោះ។ លោកបានជម្រាបប្រាប់តុលាការ គឺថាមានរបងពីរជាន់ គឺរបងជាន់ខាងក្រៅ និងខាងក្នុង។ សូមលោករៀបរាប់ថា តើបើនិយាយរបងខាងក្រៅនិងខាងក្នុង ថាតើគេសម្លាប់មនុស្សហ្នឹងនៅត្រង់កន្លែងណា?

**ឆ៖** សម្លាប់ទី១ នៅក្នុងបរិវេណរបងទី១។ សម្លាប់ឆ្នាំ៧៧ បរិវេណរបងទី២ ចម្ងាយបរិវេណទីតាំងអគារទី១ ចម្ងាយកន្លែងដាក់មនុស្សហ្នឹងចំនួន៥០ម៉ែត្រ សម្លាប់ កន្លែងដាក់មនុស្សជាប់ក្នុងគុក។

**ស៖** សូមលោកប្រាប់ខ្ញុំ តើលោកបានឃើញ ថាតើគេយកអ្នកទោសចេញពីកន្លែងទៅរណ្តៅនោះ ឬក៏លោកឮថា អ្នកផ្សេងប្រាប់ថាគេយកទៅសម្លាប់ មិនបានឃើញទេ ឬក៏បានឃើញខ្លួនឯងតាំងពីយក

ទៅ ហើយក៏គេសម្លាប់ បានឃើញទៀត?

**ឆ៖** ពេលគេយកទៅសម្លាប់ គេបណ្តើរពីមុខខ្ញុំមានបន្តបន្ទាប់ អ្នកបណ្តើរតគ្នា មួយកន្លែងពីរនាក់ៗអ៊ីចឹង តគ្នារហូត ទៅដល់រណ្តៅមុននឹងសម្លាប់ គេប្រាប់ថា៖ “មិត្តឯងអញ្ជើញទៅមូលដ្ឋានវិញតាមសហករណ៍វិញ ឲ្យស្តាប់បង្គាប់ពីអង្គការប្រាប់កន្លែងនេះផង កុំថាលំបាកលំបិនអី មិត្តឯងត្រឡប់ទៅសហករណ៍ហើយ។ ហើយមុនទៅដល់សហករណ៍ ត្រូវទៅសហករណ៍ មិត្តឯងទៅជួបនឹងអង្គការធំមួយកន្លែងសិន បានវិលដល់កន្លែងសហករណ៍”។

[១១:១៧:២២]

**ស៖** លោកសាក្សី តើមានឱកាសណាមួយលោកបានឃើញផ្ទាល់ភ្នែកថា គេសម្លាប់អ្នកទោសបើអ៊ីចឹង តើគេសម្លាប់ដោយរបៀបណា ដែលលោកបានឃើញដោយផ្ទាល់ភ្នែកនោះ?

**ឆ៖** សម្លាប់វិធីប្រើអារ-ក ប៉ុន្តែខ្ញុំសូមជម្រាបប្រាប់តុលាការសិន។ ពេលម៉ោងប្រាំបួនព្រឹក ឬម៉ោងប្រាំបីព្រឹក គេឲ្យឈ្មោះ សយ សែន អ្នកកាប់រណ្តៅជាមួយ តាចិន ហើយបន្ទាប់មកគេសំលៀងដាវ។ ដាវនោះទំហំប្រវែង ៦តឹក ផ្លែប៉ុនចំនួនពីរថ្នាប់ប៉ុណ្ណេះ។ ហើយបន្ទាប់មក ម៉ោងមួយរសៀលទើបនិងគេឲ្យខ្ញុំដើរចេញពីទីតាំងបរិវេណគុកហ្នឹង ឲ្យខ្ញុំដើរមើលគោក្របី។ ហើយខ្ញុំក៏សង្កេតគេ មើលគេបណ្តើរមនុស្សដើរទៅកន្លែងណា ខ្ញុំដឹងថា កន្លែងហ្នឹងគឺកន្លែងទីតាំងសម្លាប់មនុស្សហើយ អត់មានខុសពីកន្លែងហ្នឹងទេ។ បន្ទាប់មក គោក្របី វាចេះតែដើរស៊ីស្មៅកៀនៗរបងហ្នឹង ខ្ញុំក៏ធ្វើទៅដេញគោ ដេញក្របីអ៊ីចឹង មិនបាច់ធ្វើដឹង ធ្វើឮ គ្រាន់តែចោលភ្នែកមើលជៀងទៅ វិធីសម្លាប់មនុស្ស គេភាគច្រើនគេអារ-ក គេអត់មានវ៉ៃនឹងគល់ឫស្សី ឬវ៉ៃនឹងត្បូងចបអីទេ ព្រោះវ៉ៃនឹងគល់ឫស្សី វាយូរណាស់។ គេប្រើវិធីអារ-កហ្នឹងតែម្តង។ ពីរនាក់អ្នកតោង ម្នាក់អ្នកអារ។

[១១:១៩:១៩]

**ស៖** នៅពេលដែលលោកអាចបាន -- ដែលលោកបានឃើញគេសម្លាប់អ្នកទោសនោះតើលោកអាចប្រាប់ខ្ញុំបានទេ តើគេ -- នៅក្នុងឱកាសម្តងៗដែលលោកបានឃើញហ្នឹង តើគេសម្លាប់អ្នកទោសប៉ុន្មាននាក់?

**ឆ៖** អ្នកទោសវាអត់ទៀងទាត់ ជួនណា៥០នាក់ ជួនណា១០០នាក់ ជួនណា៧០នាក់ ជួន៨០នាក់ ជួនណា៦០នាក់ ជួនណា២០នាក់ តិចបំផុតក្នុងមួយថ្ងៃ។ បើនាំចូលយប់ គឺជាបន្តបន្ទាប់ ឬរាល់យប់អាហ្នឹងនាំចូលដាក់ក្នុងពន្ធនាគារ ក្នុងគុកហ្នឹងតែម្តងយប់ឡើង។

**ស៖** លោកបានរៀបរាប់កាលពីខាងដើមហ្នឹងគឺគេបានចាក់ចម្រៀង ឬចាក់មីក្រូដើម្បីគេសម្លាប់មនុស្សថាតើមីក្រូទាំងអស់នោះ ហើយថាតើគេៗចាក់ចម្រៀង ឬក៏គេចាក់អ្វីនៅពេលដែលគេសម្លាប់មនុស្សកាលនោះ តាមដែលលោកស្ដាប់ឮនោះ?

**ឆ៖** ចាក់ល្ខោនរឿងយាយឡូត។ យាយឡូត តស៊ូពស់ចឹកកំបុតដៃ។

**ស៖** តើមីក្រូទាំងអស់ហ្នឹងគេដាក់នៅកន្លែងណា? បើនិយាយក្នុងបរិវេណគុកតាមដែលលោកចាំ។

**ឆ៖** ដាក់កន្លែងគុកហ្នឹងតែម្ដងដើម្បីកុំឲ្យមនុស្សឮ។ គេអត់យកទៅដាក់កន្លែងសម្លាប់ទេ។ គេយកទៅដាក់កន្លែងមនុស្សណានៅរស់ គឺអត់ឲ្យឮតែម្ដង។

**ស៖** គេបានឲ្យលោកនៅក្រាំងតាចាន់ហ្នឹងជាងពីរឆ្នាំ តើលោកអាចផ្ដល់ចំនួនប៉ាន់ប្រមាណបានទេ ថាតើអ្នកទោសម្នាក់ៗ ឬក៏អ្នកទោសមួយក្រុមៗគេទុកនៅក្រាំងតាចាន់រយៈពេលប៉ុន្មានបានគេយកចេញទៅៗនោះបាទ?

**ឆ៖** អ្នកទោសយកមកដាក់នៅក្នុងក្រាំងតាចាន់ចំនួនក្នុង -- ចំនួនមួយសប្ដាហ៍គេបង្អត់បាយឲ្យស្គមស្គាំង ហើយបានគេបញ្ជូនទៅកន្លែងរណ្ដៅយកទៅសម្លាប់។

**ស៖** លោកបានជម្រាបតុលាការថា អ្នកទោសនៅក្រាំងតាចាន់ដែលមានកុមារ ហើយនិងទារកផងដែរ។ តើលោកធ្លាប់បានឃើញថាគេសម្លាប់កុមារតូចៗ ឬក៏ទារកដែរឬទេនៅក្រាំងតាចាន់?

**ឆ៖** រឿងកុមារតូចៗគេកម្រហ្នឹងអារ-កណាស់ គេបោកតែនឹងគល់ឈើទាលនៅក្បែរហ្នឹង គេអត់មាន -- គេបោកនឹងគល់ឈើទាលហើយ គេបោះចូលរណ្ដៅ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសូមបង្ហាញជូនទៅបញ្ជីអ្នកទោសនៅក្រាំងតាចាន់ គឺថាឯកសារ E3/4145 នៅខ្មែរ ERN 00068730, អង់គ្លេស 00762837, បារាំង 00761093។ ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញអំពីបញ្ជីនេះទៅសាក្សី ហើយនិងខ្ញុំសួរបន្ត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សី។

[១១:២៤:០០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក មាស សុខា ឯកសារហ្នឹងមានចំណងជើងថា "បញ្ជីអ្នកទោសដែលគេឃុំខ្លួនមួយឆ្នាំ -- មួយខែឬមួយឆ្នាំអាស្រ័យទៅលើសេចក្តីសម្រេចបក្សបាទ។ ហើយនិងចុះហត្ថលេខានៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨ ដែលហត្ថលេខាដោយមនុស្សម្នាក់ឈ្មោះ អាន់"។ តើលោកអាចជម្រាបប្រាប់តុលាការបានទេថា អាន់ ហ្នឹងជាអ្នកណាបាទ?

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំជម្រាបដល់តុលាការ ឈ្មោះ អាន់ គឺគាត់ជាប្រធាន។ បន្ទាប់មក ឈ្មោះ ឱម ពេញ។ បន្ទាប់មកទៀតឈ្មោះ ចេង ហើយអ្នកកត់ត្រា ឈ្មោះ ឌុច –ឌុច ហ្នឹងមិនមែន ឌុច ធំទេ ឌុចតូច– គឺគាត់អ្នកកត់ត្រា ព្រោះឌុចធំ គាត់អញ្ជើញចេញពីកន្លែងក្រាំងតាចាន់ ពីឆ្នាំ៧៧ គាត់ត្រឡប់ទៅនៅភូមិភាគឧត្តរ។

**ស៖** តើលោកអាចជម្រាបបញ្ជាក់ប្រាប់តុលាការបានទេ ចំពោះអ្នកទោសដែលនៅក្នុងបញ្ជីនេះត្រង់លេខ២ ហើយនិងលេខ៣ នៅលើបញ្ជីនេះ។

**ឆ៖** អ្នកទោសនៅក្នុងបញ្ជីនេះ ខ្ញុំមិនបានត្រួតពិនិត្យច្បាស់លាស់ទេ ព្រោះថ្ងៃណាមួយ -- មួយថ្ងៃៗ ឃើញតែវាយតែអង្គុលីលេខ។

**ស៖** ខ្ញុំសូមរៀបសំណួរឡើងវិញគឺថា បុគ្គលទី២ នៅលើបញ្ជីនេះគឺឈ្មោះ ហ៊ុន សេង។ តើលោកអាចជម្រាបតុលាការបានទេ ហ៊ុន សេង នោះជាអ្នកណាបាទ?

**ឆ៖** ហ៊ុន សេង គឺម្តាយខ្ញុំ ហៅ ហ៊ុន ញ៉។ អត់ក្រៅពីអ្នកណាគេ ក្រៅពីម្តាយខ្ញុំទេ ម្តាយខ្ញុំផ្ទាល់តែម្តង។ គាត់រស់នៅសព្វថ្ងៃ។

**ស៖** ចុះមនុស្សម្នាក់ទៀត នៅលេខ៣ នៅខាងក្រោម ហ៊ុន សេង នោះ ឈ្មោះ មាស សារ៉ាត់។ តើគាត់ជាអ្នកណា មាស សារ៉ាត់ នេះ?

**ឆ៖** មាស សារ៉ាត់ គឺបងស្រីបង្កើតរបស់ខ្ញុំ។

**ស៖** នៅក្នុងកូឡោន នៅខាងស្តាំដៃដែលនិយាយអំពីម្តាយនិងបងស្រីរបស់លោកនោះ គឺយោបល់និយាយថា "ស្ត្រីទាំងពីរនាក់នេះ គឺជាប្រពន្ធរបស់ គុណ ហើយនិង បឿន យើងបានកម្ទេចប្តីរបស់ពួកគាត់ ដោយសារពួកគេបានចូលរួមក្នុងការញុះញង់ឱ្យមនុស្សបោកគេឯងឱ្យជួយ ឱ្យផ្តិតមេដៃ ហើយលាក់ប្រធានភូមិ"។ ហើយតើមានអ្នកណាប្រាប់លោកទេថា ឪពុករបស់លោក ហើយនិងបងថ្លៃរបស់

លោកត្រូវបានគេកម្ទេចដែរឬទេ?

[១១:២៨:២៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតបនឹងសំណួរនេះ។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់កំណត់ត្រាតុលាការ។ គឺថាមិនចាំបាច់ត្រូវឲ្យសហព្រះរាជអាជ្ញាអានខ្លឹមសារនៅក្នុងឯកសារនេះទេ គឺគ្រាន់តែឲ្យសហព្រះរាជអាជ្ញាសួរសំណួរបើកទៅបានហើយ។ ប្រសិនជាអានដូចជាសួរនាំមុខផ្តល់ចម្លើយទៅសាក្សី ដូច្នោះដែរ។

**លោក ឌេល លីសាក់៖**

ខ្ញុំមិនបាននាំមុខនោះទេ ហើយគាត់បានធ្វើសក្ខីកម្មអំពីគាត់ដឹងថា ឪពុករបស់គាត់បានបាត់ខ្លួនត្រូវបានគេសម្លាប់ ហើយយើងបានប្រើឯកសារតុលាការ ដែលតុលាការទទួលស្គាល់អំពីបញ្ជីអ្នកទោស ហើយខ្ញុំគ្រាន់តែសួរថាតើ ប្រធានគុកជាអ្នករៀបចំឯកសារនេះបានប្រាប់គាត់ដែរឬទេអំពីហេតុការណ៍នេះតែប៉ុណ្ណោះបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយតបរបស់សាក្សីទៅនឹងសំណួរនេះរបស់សហព្រះរាជអាជ្ញា។ សូមសាក្សីឆ្លើយតប!

**លោក មាស សុខា៖**

**ឆ៖** ប្រធានគុកបានប្រាប់ខ្ញុំថា "ឪឯងគេកម្ទេចនៅទីនេះហើយ គេអត់មានយកទៅណាទេ!" ហើយអ្នកអង្គរក្សគុកក៏បាននិយាយប្រាប់ខ្ញុំដែរ " ហឺ! ឪឯងនៅនេះ អត់មានទៅណាទេ ឯងមិនបាច់ទៅរកឯណាឆ្ងាយ ឆ្ងល់អីទេ នៅតែក្នុងហ្នឹងទេ!"។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើបញ្ជីអ្នកទោសចុះថ្ងៃ១៥ ឧសភា ឆ្នាំ៧៨នេះ តើ -- ដូចដែលខ្ញុំបានបញ្ជាក់រួចទៅហើយ គឺបញ្ជីស្នើបក្សចំពោះអ្នកទោសជាប់យូរឆ្នាំយូរខែកន្លងមកហើយ។ តើលោកចាំដែរឬទេថា បន្ទាប់ពីឯកសារនេះបានចេញ ថាតើក្រោយឯកសារហ្នឹងចេញប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរ ដែលលោកត្រូវបានគេដោះលែងចេញពីក្រាំងតាចាន់នោះ?

**ឆ៖** ខ្ញុំជាប់ពីខែ៦ ឆ្នាំ៧៦ បន្ទាប់មកបានដល់ឆ្នាំ៧៨ ខែ៨ គេដោះលែងខ្ញុំវិលត្រលប់ផ្ញើនៅតាមសហករណ៍មួយហៅភូមិតារាប ឃុំជាងទង។ គេថា "សុំផ្ញើសិន" គេគ្រាន់ប្រាប់ប៉ុណ្ណឹងទេ។ ដល់ឆ្នាំ៧៩ ខែមករា បានមានក្រុមអាដែងគុគហ្នឹងគេកៀងខ្ញុំយកទៅតាមគេ នៅបានឃ្លួនចូលមកខ្ញុំបាន គេកៀងខ្ញុំទៅតាមរហូតទល់ដល់ ក្រុមគ្រួសារខ្ញុំរហូតទល់ដល់ភ្នំក្រវាញ។ ហើយដល់ខ្ញុំឡើងភ្នំអត់រួចគេនាំគ្នាដោះខ្លួនរត់គេចខ្លួនរៀងៗខ្លួន។

[១១:៣១:៥៩]

**ស៖** ខ្ញុំចង់សួរលោកថាម្តាយរបស់លោក ហើយនិងបងស្រីរបស់លោកត្រូវបានគេដោះលែងក្នុងពេលជាមួយគ្នាជាមួយលោកដែរឬទេ?

**ឆ៖** ម្តាយខ្ញុំ បងស្រីខ្ញុំ ប្អូនខ្ញុំ គឺលែងតែថ្ងៃជាមួយគ្នា មួយក្រុមហ្នឹងមានចូលអ្នកដទៃចំនួនបីនាក់ផង ប៉ុន្តែម្នាក់ទៀតស្លាប់ ម្នាក់ទៀត ខ្ញុំអត់ដឹងគេនៅស្រុកណា ឃុំណាទេ ព្រោះខ្ញុំអត់ដឹង តែស្រុកគីរីវង់ ប៉ុន្តែមិនដឹងនៅឃុំណា ខ្ញុំអត់ដឹង មនុស្សស្រី។ ហើយមួយទៀត សយ សែន ហើយតាចិន នៅឃុំគុស ពីមុខវត្តសំណាប ប៉ុន្តែគាត់ស្លាប់ហើយ។

**ស៖** តើមានអ្នកនៅក្រាំងតាចាន់ ឬក៏នរណាម្នាក់មកពីខាងស្រុកមកប្រាប់លោកថា គេដោះលែងលោកដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹង ព្រោះឃើញតាអីគេ គណៈតំបន់មកម្តងព្រោះខ្ញុំអត់ស្គាល់ ប៉ុន្តែគេថា "គណៈតំបន់មកៗ" ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ខ្ញុំចង់សួរលោកបន្តបន្តិចទៀត។ លោកសាក្សី នៅថ្ងៃទី៣០ មិថុនា ឆ្នាំ៧៨ គឺមួយឆ្នាំក្រោយពេលគេដាក់ គេឃុំឃាំងលោកនៅក្រាំងតាចាន់ គឺមានសកម្មភាពនៅត្រាំកក់ ហើយត្រាំកក់ត្រូវបានគេទទួលស្គាល់ថាជាស្រុកគំរូក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំចង់សួរលោកថា តើលោកធ្លាប់ឃើញមេដឹកនាំខ្មែរក្រហមមកធ្វើទស្សនកិច្ចនៅមន្ទីរឃុំឃាំងក្រាំងតាចាន់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញលោក វិចទ័រ កូប៉េ!

[១១:៣៤:៣១]

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំសូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅលើការរៀបចំសំណួរនេះ ព្រោះថាសំណួរទាំងអស់

នេះគឺប្រើពាក្យថា "ខ្មែរក្រហម"។ នៅក្នុងឆ្នាំ៧៧ ខ្មែរក្រហមគឺជាពាក្យទូទៅមួយ សាក្សីគាត់អាចដឹងថារបបហ្នឹងគឺជារបបខ្មែរក្រហម ប៉ុន្តែនៅពេលនោះគឺក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពាក្យ ឬក៏ការរៀបរាប់ហ្នឹង វាហាក់ដូចជាមិនមានតម្លៃអ្វីនោះទេ។ ដូច្នេះ ខ្ញុំជំទាស់ទៅនឹងការប្រើពាក្យ "ខ្មែរក្រហម"។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំដឹងអំពីការប្រើប្រាស់ពាក្យ។ ឧទាហរណ៍ដូចជាគេប្រើពាក្យ "កម្មាភិបាល ឬក៏សមាជិកបក្ស" ប៉ុន្តែដោយសារតែសាក្សីគាត់មិនមែនជាសមាជិកបក្ស។ ដូច្នេះ ខ្ញុំគិតថា "ពាក្យកុម្មុយ-នីស្ត", ពាក្យ "ខ្មែរក្រហម" វាអាចជាពាក្យសមស្រប។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ហ្នឹងមិនសមស្របទេ ហើយអង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សីចំពោះសំណួរនេះរបស់តំណាងសហព្រះរាជអាជ្ញា។

សាក្សីឆ្លើយតបនឹងសំណួរ!

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំនៅក្នុងគុកក្រាំងតាចាន់ ព្រោះខ្ញុំអត់ស្គាល់គេ ព្រោះខ្ញុំអត់ស្គាល់មេ មេគេធំៗខ្ញុំអត់ដែលស្គាល់។ ហើយខ្ញុំក៏មិនដឹងគេចូលពេលណា ចេញពេលណាក៏ខ្ញុំអត់ដឹង គ្រាន់តែខ្ញុំដឹងថា ថ្ងៃមួយមានគណៈតំបន់គេចូលទៅ ខ្ញុំដឹងតែប៉ុណ្ណឹង គេដេញខ្ញុំឱ្យទៅក្រៅបរិវេណគុកហ្នឹង។ គេថា "គណៈតំបន់ចូលមក អ្អែងកុំនៅ អ្អែងចេញភ្លាម!" តែប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹង។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ខ្ញុំបន្តបន្តិចមុននឹងខ្ញុំបញ្ចប់នូវការសួររបស់ខ្ញុំ។ ឥឡូវនេះ ខ្ញុំសុំដកស្រង់ពីកិច្ចសម្ភាសន៍របស់ម្ដាយលោកជាមួយសហចៅក្រមស៊ើបអង្កេត។ D25/30 គឺ 00160507 ដល់ 508, ភាសាអង់គ្លេស 00223491, ភាសាបារាំងមានលេខ 00178426 ដល់ 427 ហើយម្ដាយរបស់លោកឆ្លើយតទៅនេះ៖ "សំណួរ៖ តើអ្នកស្រីធ្លាប់ឃើញមេដឹកនាំខ្មែរក្រហមមកក្រាំងតាចាន់ដែរឬទេ? ចម្លើយ៖ ពួកគេមក។ តាម៉ុក, តាគិត, តាគារ មកពីគណៈស្រុក"។ ហើយបន្តចុះមកក្រោមទៀត "សំណួរ៖ តើតាម៉ុកមកប៉ុន្មានដងដែរ? ចម្លើយ៖ ប្រហែលជាម្ដង ឬក៏ពីរដង។ គាត់មកមើលអ្នកទោស គាត់អត់មានសួរនាំអ្វីទេ។ តាគិត, តាគារ គឺតាគិត, តាគារ ហ្នឹងមកច្រើនដង"។ ខ្ញុំសូមបញ្ចប់ការដកស្រង់របស់ខ្ញុំ។

លោក សុខា តើលោកស្គាល់តាម៉ុក ឬក៏មេដឹកនាំដទៃទៀតដែលម្ដាយរបស់លោកបានលើកឡើង

ថាតើលោកអាចស្គាល់ថាពួកគាត់ហ្នឹងមកក្រាំងតាចាន់ដែរឬទេ? ហើយតើលោកធ្លាប់ឃើញបុគ្គល ឬក៏មនុស្សទាំងអស់នោះមកក្រាំងតាចាន់ដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ឃើញដែរ ប៉ុន្តែខ្ញុំអត់ស្គាល់។ ខ្ញុំមិនស្គាល់ទេរឿងគេអ្នកធំជំនាន់ហ្នឹង ខ្ញុំអត់ស្គាល់ព្រោះខ្ញុំអត់ដែលសួរយកចិត្តទុកដាក់រឿងគេអ្នកធំ ព្រោះកាលហ្នឹងខ្ញុំនៅវ័យវាភ័យខ្លាច ខ្ញុំអត់ដែលយកចិត្តទុកដាក់ ព្រោះគេមិនសួរឲ្យយើងឃើញទៀត។ ឃើញតែម្តងហ្នឹង តាអី តាគិតអីមិនដឹងទេ ខ្ញុំអត់ស្គាល់ទេ ខ្ញុំដឹងតែគេថា តាគិត មកៗ ខ្ញុំដឹងតែប៉ុណ្ណឹង ព្រោះអ្នកណាមកក្រោយៗទៀតខ្ញុំអត់ដឹង។

**លោក ឌេល លីសាក់៖**

សូមអរគុណលោក សុខា ដែលបានផ្តល់ពេលវេលាឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ។

លោកប្រធាន ខ្ញុំសុំបញ្ចប់ការសួររបស់ខ្ញុំហើយ។ សូមអរគុណ។

[១១:៣៨:៥៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលខាងតុលាការសម្របសម្រួលជាមួយអ្នកបច្ចេកទេសដើម្បីផ្លាស់ប្តូរនូវ ឌីវីឌី។

បាទ យើងបន្តកិច្ចដំណើរការនីតិវិធីរបស់យើងតទៀត ឥឡូវរៀបចំផ្លាស់ប្តូរឌីវីឌីថ្មីរួចហើយ។ ហើយអស់លោក លោកស្រីចៅក្រមមានសំណួរអីសួរទេ?

សូមអញ្ជើញលោកចៅក្រម ហ្វេនស៍។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំមានសំណួរបន្តិចបន្ថែមទៅលើអ្វីដែលព្រះរាជអាជ្ញាទើបតែសួរលោកកន្លងមកនេះ។ គឺសំណួរខ្ញុំពាក់ព័ន្ធជាមួយនឹងអ្វីដែលលោកបានប្រាប់អង្គជំនុំជម្រះ អំពីការសួរចម្លើយអ្នកទោស។ លោកបានផ្តល់សក្ខីកម្មថា ទាំងលោកបានប្រាប់អំពីខ្លឹមសារនៃការសួរ ក៏ដូចជាវិធីសាស្ត្រនៃការសួរ។ បានន័យថា គេប្រើទារុណកម្មដើម្បីសួរនោះ។ នៅពេលដែលព្រះរាជអាជ្ញាសួរលោកថាតើលោកដឹងដោយរបៀបណា? ឬក៏សួរថាតើលោកបានឃើញដោយផ្ទាល់ ឮដោយផ្ទាល់ដែរទេ? លោកឆ្លើយថា បាទ។ ហើយបន្ទាប់មកទៀត ព្រះរាជអាជ្ញាបានសួរលោកថា តើលោកឃើញ ឮដោយរបៀបណា? គឺលោកឆ្លើយថាលោកនៅក្បែរនោះ។ តើលោកអាចពន្យល់បន្តិចឲ្យច្បាស់ដែរឬទេ ថាតើលោកមានន័យយ៉ាងម៉េច ដែលលោកនិយាយថាលោកនៅក្បែរនោះ?

[១១:៤១:០៤]

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំជម្រាបដល់កន្លែងពេលគេសួរចម្លើយ។ ខ្ញុំប្រាប់វិធីខ្ញុំដើរធ្វើការនៅក្នុងបរិវេណហ្នឹង។ ព្រោះពេលនោះ គេ ពេលព្រឹកគេមិនទាន់ឲ្យខ្ញុំមើលគោមើលក្របីទេ។ ពេលព្រឹកគេច្រើនតែប្រើខ្ញុំបេះបន្លែ បេះម្ហូរទៅ យកម្ហូបម្ហាទៅឲ្យគេ ហើយកន្លែងសួរចម្លើយវានៅជិតហ្នឹង។ គេអត់មានឲ្យនៅឆ្ងាយពីបរិវេណហ្នឹងទេ ខ្លាចសួរចម្លើយទៅ អ្នកទោសហ្នឹងវារត់រួច ឬអ្នកហ្នឹងនៅដាំបាយជិតហ្នឹង ក្រែងគេជួយចាប់គ្នា ព្រោះមានរួចម្នាក់ទៅហើយ។ រួចហ្នឹងគេតាមទៅចាប់បាន។ រួចហើយខ្ញុំក៏ឃើញហេតុ-ការណ៍នោះភ្លាម នៅកៀកនឹងកន្លែងចង្ក្រានបាយអង្គរក្សគុកហ្នឹងតែម្តង។

**ស៖** ខ្ញុំចង់បន្តបន្តិចទៀត។ ថាតើគេសម្ភាសនៅក្នុង -- គេសួរចម្លើយនៅក្នុងបន្ទប់ ឬក៏សួរចម្លើយនៅកណ្តាលវាល?

**ឆ៖** ចម្លើយនេះគេអត់មានសួរក្នុងបន្ទប់អីទេ ព្រោះគេធ្វើជាការិយាល័យមួយ ម្ខាងបាំង ម្ខាងបាំងតែពីខាងក្រោយអ៊ីចេះ វាលពីខាងត្បូង វាលពីខាងជើង វាលពីខាងកើត ចំហ គេអត់មានធ្វើក្នុងបន្ទប់ថ្ម បន្ទប់អីទេ អត់មាន មានតែកៅអីមួយសម្រាប់អង្គុយ។ អ្នកទោសអង្គុយ ហើយអ្នកកត់ត្រាគេមានកៅអីមួយ មានតែពីរទេ ហើយអ្នកចាំគេចាំវៃ ឈរវៃផ្សេងទៅ។ អ្នកសួរ គេសួរទៅ។

**ស៖** អ៊ីចឹង បានន័យថាលោកអាចមើលឃើញដោយសេរីនៅពេលគេសួរចម្លើយ ដោយសារតែមិនមានជញ្ជាំង មិនមានអីបិទបាំង ឬមួយក៏លោកអើតមើល លួចមើលទៅតាមបង្អួច?

[១១:៤៣:២០]

**ឆ៖** អត់ចាំបាច់អើតទេ គ្រាន់តែងាកឃើញតែម្តង។ ប្រវែងហ្នឹង កន្លែងតុលាការអង្គុយហ្នឹងអត់មានឆ្ងាយទេ។

**ស៖** ខ្ញុំយល់ ប៉ុន្តែអ្វីដែលខ្ញុំយល់មិនទាន់ច្បាស់ គឺអំពីការសួរចម្លើយនោះ គឺបានន័យថាអំពីទីតាំងសួរចម្លើយ។ ថាតើគេបិទជញ្ជាំងទាំងបួនទិស ទាំងបីទិស ទាំងពីរទិស ឬក៏ថាមានដំបូលដែរឬទេកន្លែងគេសួរចម្លើយនោះ?

**ឆ៖** មានតែដំបូលទេ អត់ជញ្ជាំងទេ។ មានតែជញ្ជាំងតឿកម្ពស់៥តឹកពីដីទេ។ អត់មានជញ្ជាំងបាំងជុំវិញទេ។ គេអង្គុយសួរក្នុងរោង តែមានខាងក្រោយហ្នឹង ទីតាំងគេដាក់ខោអាវអ្នកទោសស្លាប់ទៅគេស្រាតយកមកគរទុកក្នុងហ្នឹងទេ។ មានតែប៉ុណ្ណឹងទេ។ ព្រោះខ្ញុំអត់ខោអត់អាវ ខ្ញុំទៅយកកន្លែងហ្នឹងយកមកស្លៀក។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំច្បាស់ហើយអំពីការសួរចម្លើយ។ ឥឡូវនេះ ខ្ញុំមានសំណួរបន្ថែមមួយទៀត គេសួរលោកថាតើលោកបានឃើញ គឺបានឃើញពីបែបបទនៃការធ្វើទារុណកម្មវ៉ៃពីក្រោយខ្នង ហើយលោកនិយាយថាលោកឃើញម្ដង។ គឺនិយាយអំពីការច្រកថង់ប្លាស្ទិក ហើយលោកនិយាយថាឃើញម្ដង។ ឥឡូវនេះ ខ្ញុំចង់សួរថាតើមានវិធីធ្វើទារុណកម្មផ្សេងទៀតទេក្រៅពីច្រកថង់នោះ ឧទាហរណ៍ដូចជា ការវ៉ៃ ឬក៏មានការធ្វើទារុណកម្មអ្វីផ្សេងៗទៀតហ្នឹងគឺ ខ្ញុំចង់បានន័យថា ក្រៅពីការច្រកស្បោងកៅស៊ូហ្នឹង តើមានប្រើវិធីសាស្ត្រធ្វើទារុណកម្មផ្សេងទៀតទេដែរឬទេ ហើយប្រសិនបើមាន តើគេប្រើទារុណកម្មហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** វិធីសួរចម្លើយ ខ្ញុំជម្រាបប្រាប់ថាខាងតុលាការថា គេវាយសំពងហើយ តែសួរមិនឆ្លើយគឺគេវ៉ៃហើយ បើកាលណាវ៉ៃមិនហើយ គេវិធីគេច្រកស្បោង។ បើកាលណាច្រកស្បោងមិនឆ្លើយ គឺគេវ៉ៃទាល់តែងាប់នៅនឹងកន្លែង។ ហើយម៉្យាងទៀតក៏គេមានវិធីចាប់ចុងក្រចក។ មានតែប៉ុណ្ណឹងទេ។

[១១:៤៦:០៥]

**ស៖** ខ្ញុំយល់ ប៉ុន្តែសំណួរខ្ញុំចង់សួរថាតើលោកឃើញដោយផ្ទាល់នូវការធ្វើទារុណកម្មហ្នឹងញឹកញាប់ប៉ុនណាទេ? ខ្ញុំមិនចង់សួរឲ្យបញ្ជាក់ថាប៉ុន្មានដង ប៉ុន្មានអីទេ ប៉ុន្តែអាចថាមួយអាទិត្យប៉ុន្មានដង មួយខែប៉ុន្មានដង ឬក៏មួយថ្ងៃហ្នឹងគេធ្វើទារុណកម្មហ្នឹងប៉ុន្មានដង? លោកអាចប្រាប់បានទេ?

**ឆ៖** ខ្ញុំអាចប្រាប់តុលាការបាន ពេលគេសួរចម្លើយធ្វើទារុណកម្មថ្ងៃណា អ្នកណាគេឆ្លើយត្រង់ចេះតែឆ្លើយទៅ អាហ្នឹងគេអត់ធ្វើទេ។ ថ្ងៃណាមួយ អ្នកណាអត់ឆ្លើយរឹងរូសថា មិនឆ្លើយថាអ្នកឯងធ្វើជា សេ.អ៊ី.អា អាមេរិកាំង ឬធ្វើសេ.អ៊ី.អា យួន អាហ្នឹងគឺគេវ៉ៃអ៊ីចឹងតែម្ដង។ ហើយខ្ញុំកាលនៅកន្លែងអត់ទាន់ទៅមើលគោ មើលក្របី គឺខ្ញុំឃើញហើយ ព្រោះខ្ញុំគេមានឲ្យដើរក្រៅពីក្បែរចង្ក្រានបាយឯណាគេឲ្យនៅជួយរត់ចង្ក្រានបាយសិន។ ហើយគេសួរចម្លើយមួយថ្ងៃពីរដង ម៉ោងមួយរសៀល និងម៉ោងប្រាំពីរព្រឹក គេសួរហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថា តើ-- ខ្ញុំគិតថា ខ្ញុំបានទទួលនូវព័ត៌មានអស់ហើយ។ សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១១:៤៧:៤៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក មាស សុខា ដែលបានមានវត្តមាននៅទីនេះ និងបានឆ្លើយនៅសំណួរ។ ខ្ញុំមានសំណួរមួយចំនួនទៀតដើម្បីសួរលោក។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ជាដំបូង ខ្ញុំចង់សួរលោកថាតើលោកចាំទេ លោកអាចនិយាយអំពីចំនួនមនុស្សនៅក្នុងចំណោមបុគ្គលិកដែលនៅក្រាំងតាចាន់បានទេ? លោកអាចរៀបរាប់អំពីរចនាសម្ព័ន្ធ។ ឧទាហរណ៍ដូចជាប្រធាន អនុប្រធាននៅក្រាំងតាចាន់ហ្នឹង ហើយនិងមានកងអង្គរក្សប៉ុន្មាន? ហើយម្នាក់ៗមានតួនាទីអ្វីខ្លះនៅទីនោះ?

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំជម្រាបប្រាប់លោកតុលាការក្នុងអង្គរក្សក្រាំងតាចាន់។ ខ្ញុំជម្រាបប្រាប់ មាន១២នាក់ៗ ហើយជូនណាគេយកពីឃុំក្រៅមកចូលរៀនច្បាប់សម្លាប់មនុស្ស និងផ្សេងៗបន្តបន្ទាប់ទៀត។ ហើយតួនាទីអ្នកនៅក្នុងគុកក្រាំងតាចាន់នេះ ខ្ញុំជម្រាបថាមាន ផៃ អាន់ ជាប្រធាន, បន្ទាប់មក កាលតាឌុចនៅគាត់គឺអនុប្រធាន។ បន្ទាប់មក ឱម ពេញ បន្ទាប់មក តាចេង, បន្ទាប់មក តាមឿន, បន្ទាប់មក ឈឿន, បន្ទាប់មក អ៊្លក, បន្ទាប់មក សៀង, បន្ទាប់មកកូនអង្គរក្សវាចំនួនប៉ុន្មានដែរ ខ្ញុំអត់ចាំមនុស្ស ព្រោះខ្ញុំគ្រាន់តែខ្ញុំស្គាល់ឈ្មោះ ខ្ញុំជម្រាបប្រាប់លោកតុលាការ ចាំកត់ត្រាអារឿងឈ្មោះអ្នកនៅក្នុងហ្នឹងចុះ។ ទី១ ស៊ាន់, ទី២ ស៊ីន, ទី៣ សាំង, ទី៤ ឌុច, ទី៥ ទូច។ ហើយ អ៊្លក ខ្ញុំបានរាប់ហើយមិនដឹងទេភ្លេចហើយអំមិញ។ ហ្នឹងអង្គរក្សការពារ។ ហើយតួនាទី ឌុច គឺអ្នកកត់ត្រា។ ហើយ សៀង គឺអ្នកឃាតកម្ម។ ហើយ មឿន, ហើយ ចេង គឺអ្នកឃាតកម្ម។ ហើយរួមចំណែកហ្នឹង ប្រធានៗគេចូលរួមបើអ្នកប្រាំមួយនាក់អង្គរក្សហ្នឹង គេអ្នកជញ្ជូនពីកន្លែងអគារទៅ។

[១១:៥០:៤៤]

**ស៖** លោកបាននិយាយអំពីអំពើហិង្សាទៅលើអ្នកទោស។ តើលោកអាចប្រាប់បានទេពាក់ព័ន្ធទៅនឹងស្ត្រីដែលជាប់ឃុំនោះ? តើគេប្រព្រឹត្តអំពើហិង្សាផ្លូវភេទទៅលើស្ត្រីជាប់ឃុំទាំងអស់នុ៎ងទេ?

**ឆ៖** រឿងជាប់ផ្លូវភេទកុំសួរខ្ញុំ ខ្ញុំអត់ដឹងទេ កាលនោះ វ័យខ្ញុំអត់ដឹងរឿងផ្លូវភេទ ព្រោះខ្ញុំអត់ដឹងតែម្តង ព្រោះខ្ញុំអត់ដឹង។ ព្រោះកាលនោះដឹងតែអ្នកណាខូចសីលធម៌ គឺកោរបញ្ជោស កោរត្រងោហើយដើរវាយស្គរ វាយត្រឡោកអីកុំឲ្យយកតម្រាប់តាម។ ខ្ញុំអាហ្នឹងខ្ញុំឮតែចាស់ៗគាត់ -- អេ៎! មើលឃើញ

កាលខ្ញុំរួចពីគុកមកវិញ អាហ្នឹង ខ្ញុំរួចពីក្រាំងតាចាន់ ខ្ញុំឃើញម្នាក់ឈ្មោះស៊្រីគេ ឈ្មោះស៊្រីទេខ្ញុំភ្លេចឈ្មោះហើយ។ គេបណ្ដើរពីមន្ទីរឃុំទៅ ឲ្យស្រែកអាក្រោសនោះ ខ្ញុំដឹងតែប៉ុណ្ណឹងទេ មិនដឹងសីលធម៌រឿងអីអត់ដឹងសោះកាលណោះ។ រឿងផ្លូវភេទអត់ដឹងតែម្ដង។

[១១:៥២:២០]

**ស៖** ខ្ញុំចង់ឲ្យលោកប្រាប់ផងដែរពាក់ព័ន្ធនឹងអគារ ជាអគារដែលលោក ម្ដាយរបស់លោកប្អូនបងប្អូនរបស់លោកដែលគេឃុំនោះ តើអគារនោះជាអគារសម្រាប់អ្នកទោសដែលត្រូវធ្វើការនៅពេលថ្ងៃ ឬក៏នៅក្នុងអគារហ្នឹង ក៏មានអ្នកទោសដែលជាប់នៅក្នុងហ្នឹងរហូតតែម្ដងអត់មានចេញទៅធ្វើការអី?

**ឆ៖** អគារនោះអត់មានសម្រាប់ថាអ្នកណាទោសចេញទៅធ្វើការ ឬមិនចេញធ្វើការ គឺដាក់ទូទៅទាំងអស់តែម្ដង។ អត់មានចាំបាច់ថា អឺ! អ្នកនេះស្រាល អ្នកនេះធ្ងន់ ដូចគុកសម័យឥឡូវទេ អត់ទេ គឺអ្នកណាក៏ជាប់នៅក្នុងហ្នឹងដែរ។ អ្នកឯងធ្វើការនៅ -- ជួយធ្វើការខាងក្រៅក៏ជាប់នៅក្នុងហ្នឹង អ្នកមិនធ្វើក៏ជាប់នៅហ្នឹង។ អ្នកជាប់នៅក្នុងហ្នឹង គឺពួកគេបង្អត់បាយតែមួយសប្ដាហ៍ហ្នឹង គឺស្គមស្គាំងដើរលែងរួចហើយ។ គេស្រួលយកទៅសម្លាប់ហើយ។

**ស៖** ចុះម្ហូបអាហារវិញ លោកបាននិយាយថាម្ដាយរបស់លោកជាអ្នករៀបចំម្ហូប រៀបចំបបរធ្វើបបរសម្រាប់អ្នកទោស។ តើលោកដឹងទេថា ម្ហូបដែលដូចគ្នាហ្នឹង គឺគេបានផ្ដល់ជូនទៅដល់កម្មា-ភិបាល។ គឺមានន័យថា តើម្ហូបហ្នឹងគឺថាម្ហូបសម្រាប់មនុស្សទាំងអស់តែម្ដង ឬក៏មានសម្រាប់កម្មា-ភិបាលផ្សេង អ្នកទោសផ្សេងអ៊ីចឹង?

[១១:៥៤:១៧]

**ឆ៖** បញ្ហាម្ហូបហូបចុកនៅកន្លែងគុកក្រាំងតាចាន់ គេមិនមែនឲ្យហូបចុកជាមួយអ្នកទោសទេ។ អ្នកទោសគេហូបតែបបរ គេកន្លែងនោះគេហូបបាយស្រួយ។ ម្ហូបគេប្ដូនមុខ ឬមួយថ្ងៃ។ ហើយកន្លែងសម្រាប់អ្នកទោស តែចានគេអត់ឲ្យលាងផង គេឲ្យ -- សម្រាប់ចានវិញ គេឲ្យដាក់នៅក្រោមដើមស្វាយមួយ មាន់អាចម៍ដាក់រាល់ថ្ងៃ គេអត់ឲ្យលាងទៀត គេមិនឲ្យលាងជាដាច់ខាត។ ហើយបបរអ្នកទោសក្នុង១០០នាក់ក៏១០កំប៉ុង ដំឡូង៥គីឡូ។ ២០០នាក់ក៏ប៉ុណ្ណឹង ២០នាក់ក៏ប៉ុណ្ណឹង អា១០នាក់ក៏ប៉ុណ្ណឹង វាអត់មានអីកំណត់ថាអង្ករ១០កំប៉ុងហ្នឹងតែម្ដង ហើយអំបិលមួយវែកក្រឡុមហ្នឹង តែប៉ុណ្ណឹងទេ។ ប្រៃក៏ដោយសាបក៏ដោយ ស្រេចអ្នកឯងធ្វើបានប្រៃក៏ដោយ អត់មាននិយាយ រឿងប្រៃសាប។

**ស៖** តើលោកមានបានឃើញថាកម្មាភិបាលមួយចំនួននោះផឹកស្រាទេ?

**ឆ៖** កម្មាភិបាលមួយចំនួនគេផឹក ផឹកគេផឹកដោយបិតស្រាដោយខ្លួនឯង។ ខ្ញុំក៏ចូលរួមជាមួយគេ ដេកបិតជាមួយគេដែរ។ ក្នុងមួយឆ្នាំគេបិតបីដង ស្រា-ស ហើយគេលួចផឹកគ្នាគេ នៅពេលនេះគេផឹកហើយ ថែមដាក់ទាំងប្រមាត់មនុស្សទៀត។

**ស៖** ឥឡូវនេះខ្ញុំ -- អ្វីដែលខ្ញុំទើបតែស្ដាប់ឮអម្បាញ់មិញនេះ គឺលោកថាកម្មាភិបាលខ្លះនោះស៊ីថ្លើមមនុស្ស។ តើនេះជាអ្វីដែលលោកឃើញផ្ទាល់ភ្នែកតែម្ដង ស៊ីគ្រឿងក្នុង (សុំទោស) ហើយជាគ្រឿងក្នុងរបស់អ្នក -- មនុស្សប្រភេទណាដែរ?

[១១:៥៦:៣៨]

**ឆ៖** ខ្ញុំអំមិញមិនមែននិយាយថ្លើមទេ ខ្ញុំនិយាយប្រមាត់គេដាក់ជាមួយស្រាផឹក -- ផឹកស្រា មិនមែននិយាយថ្លើមទេ។ រឿងថ្លើមមនុស្សគេអត់ដែលឃើញស៊ីទេ ឃើញគេដាក់ប្រមាត់ ប្រមាត់ហ្នឹងគេវះយកវិធីណាខ្ញុំអត់ដឹងទេ។ គេយកមកហាលប្រមាត់ហ្នឹង ជាច្រើនអ៊ីចឹងមិនដឹងថាគេយកបញ្ជូនទៅណាខ្ញុំអត់ដឹងទេរឿងប្រមាត់មនុស្សអត់ដឹងទេៗ ដឹងតែឃើញគេហាល។ ហាលគេហាលលាក់លៀមទៀតគេមិនឲ្យយើងឃើញទៀត តែបើខ្ញុំដើរទៅប៉ះ។ ហើយថ្ងៃមួយឃើញគេដាក់ស្រាផឹកគ្នាគេប៉ុន្មាននាក់ហ្នឹងមេៗហ្នឹង រឿងពួកបុគ្គលិកតូចតាចវាអត់ដែលផឹកទេ ផឹកតែមេៗប៉ុន្មាននាក់ទេ តូចតាចអត់ផឹក។ តែពេលសម្លាប់មនុស្សបានគេផឹក ពេលណាគេអត់សម្លាប់គេអត់ផឹកទេ ពេលសួរចម្លើយ គេដាក់មួយកែវ ពីរកែវហ្នឹង គេយកស្រាហ្នឹងទៅដាក់កៀនសួរចម្លើយហ្នឹង ខ្ញុំឃើញដបស្រានៅក្បែរហ្នឹង។

**ស៖** ចំពោះការសម្លាប់ លោកបានឆ្លើយថា នៅពេលម្ដងៗនោះមានក្រុមអ្នកទោសនោះពីរ ឬក៏ទៅបីនាក់ហ្នឹងគេនាំទៅក្បែររណ្ដៅហើយសម្លាប់ចោល គឺថាម្ដងពីរបីនាក់។ ខ្ញុំក៏ស្ដាប់ឮផងដែរថា នៅថ្ងៃនោះមានលើសពីពីរទៅបីនាក់ទៅទៀតដែលត្រូវបានសម្លាប់នោះ ជួនកាលសម្លាប់មនុស្សច្រើន។ ខ្ញុំបានកត់ត្រាអម្បាញ់មិញដែរគឺលោកអាច -- លោកបាននិយាយថាប្រហែលអាចពីដប់ទៅដល់ម្ភៃ ឬក៏ជួនកាលលើសពីម្ភៃទៅទៀត។ បើតាមលោកចាំនោះថាតើ -- គឺថាអ្វីៗគឺទៅអ៊ីចឹងរហូតមែនទេ? គឺថាជួនកាលមានពីរទៅបីនាក់ទៅនាំទៅមាត់រណ្ដៅ ហើយជួនកាលនោះ គឺលើសពីហ្នឹងទៅទៀតគេនាំទៅមាត់រណ្ដៅហ្នឹងដើម្បីសម្លាប់ចោលនោះ។ តើអ៊ីចឹងមែនទេ?

[១១:៥៩:០១]

**ឆ៖** លោកស្ដាប់ខ្ញុំអត់បានទេ រឿងសម្លាប់មនុស្ស។ គេបណ្ដើរម្ដងបីនាក់ ឬពីរនាក់យកទៅរណ្ដៅ ហើយគេនឹងមកបណ្ដើរម្ដងទៀត បណ្ដើរទាល់អស់គ្នាក្នុងមួយអគារមាន ក្នុងអគារហ្នឹងមាន

៣០នាក់ ឬ៥០នាក់ ឬ២០នាក់ ឬ៧០នាក់គេបណ្ដើរម្ដងពីរ ម្ដងបី ម្ដងបួនទៅ យកឲ្យអ្នកចាំអារ-កនៅរណ្ដៅឯណោះ។ អ្នកបញ្ជូនចេះតែបញ្ជូនទៅ អ្នកសម្លាប់ចេះតែសម្លាប់ទៅ គេបណ្ដើរម្ដងពីរ ម្ដងបី។ ស្ដាប់ខ្ញុំឲ្យបានលោកតុលាការ ព្រោះមិនមែនគេសម្លាប់មួយថ្ងៃបីនាក់ទេ ព្រោះក្នុងមួយសប្ដាហ៍គេសម្លាប់ ឬជួនណាគេសម្លាប់រាល់ថ្ងៃក៏មានដែរ។

**ស៖** បើតាមលោកចាំ តើចំនួនមនុស្សដែលគេសម្លាប់ហ្នឹង ក្នុងមួយថ្ងៃច្រើនបំផុតប៉ុន្មាន? តើលោកមានដឹងទេ?

**ឆ៖** ខ្ញុំដឹងថ្ងៃមួយ គេយកពីឃុំស្រែនោង និងឃុំញ៉ែងញ៉ង់មក ក្នុងនោះមានមួយរយជាងនាក់ ១៣០នាក់។ គេដឹកមកដល់ម៉ោងបីរសៀល គេជីករណ្ដៅ៥ម៉ែត្របួនជ្រុង ជម្រៅ ៣ម៉ែត្រ។ គេសម្លាប់ក្នុងមួយយប់ហ្នឹងមួយរយជាងនាក់។ មានជាងហ្នឹងតទៅទៀតហ្នឹងក៏មានដែរ។ ហ្នឹងគេអត់បានចាំបាច់សួរចម្លើយទេ គេអត់មានអាល័យតែសួរចម្លើយទេ ចាស់ ក្មេង ស្រី ប្រុសអី គឺយកមកដល់ គឺគេចាត់ការហើយ គេឲ្យព័ត៌មានមកពីក្រៅហើយ ឲ្យធ្វើរណ្ដៅឲ្យហើយ គេអត់មានចាំបាច់ចាំស្អែកទេ ព្រោះគេអត់មានកន្លែងដាក់ឃុំឃាំង។

[១២:០១:២១]

**ស៖** លោកក៏បានឆ្លើយផងដែរថាមានពេលម៉ោងសម្រាប់ -- ឧទាហរណ៍ដូចពេលព្រឹកសម្រាប់សួរចម្លើយ ហើយមានសម្រាប់ពេលថ្ងៃ ពេលរសៀល។ ចុះមានម៉ោងពេលសម្រាប់ការសម្លាប់មនុស្សហ្នឹងទេ គេមានកំណត់ថាត្រូវសម្លាប់ម៉ោងណាៗទេ?

**ឆ៖** សម្លាប់មនុស្ស តែម៉ោងពីររសៀលគេចាប់ផ្ដើមសម្លាប់ហើយ អត់មានម៉ោងណាៗអីទេ តែថ្ងៃល្ងាច គឺម៉ោងពីរហ្នឹង គេសម្លាប់ពេលព្រឹក អត់សម្លាប់ទេ សម្លាប់តែពេលល្ងាច ម៉ោងពីរហ្នឹងរហូតទល់ដល់ម៉ោងប្រាំ។ ជួនណាដល់ច្រើនមែនទែន រហូតដល់ម៉ោងប្រាំបីយប់។

**ស៖** ខ្ញុំនឹងត្រឡប់មកសួរលម្អិតអំពីចំណុចនេះ ក៏ប៉ុន្តែអម្បាញ់មិញហ្នឹងលោកនិយាយអំពីប្រមាត់ដែលពួកខ្មែរក្រហម ឬក៏កម្មាភិបាលខ្មែរស៊ី។ អ៊ីចឹងលោកដឹងម៉េចបានថាប្រមាត់ហ្នឹង ឬក៏គ្រឿងក្នុងហ្នឹងជារបស់មនុស្សនោះ? គេប្រាប់លោក ឬក៏លោកបានឃើញផ្ទាល់ភ្នែក?

**ឆ៖** ប្រមាត់មនុស្ស ខ្ញុំដើរទៅឃ្វាលគោ គេហាលលាក់នៅកៀនរបង ខ្ញុំឃើញគេដោតព្យួរ។ ខ្ញុំដឹងថាប្រមាត់មនុស្សហ្នឹង អត់មានក្រៅជាប្រមាត់សត្វទេ។ ទៅរកប្រមាត់សត្វឯណាមក អត់មានប្រមាត់គោ ប្រមាត់ក្របីទេ ព្រោះប្រមាត់ច្រើន។

[១២:០៣:១៥]

**ស៖** លោកក៏បានឆ្លើយអម្បាញ់មិញផងដែរថា លោកមានបងមួយឈ្មោះ មាស វ៉ាត់ គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរផ្សេងទៀត។ ចុះលោកដឹងពីឈ្មោះមន្ទីរហ្នឹង ដែលបងរបស់លោក មាស វ៉ាត់ ដែលគេបញ្ជូនទៅហ្នឹងទេ?

**ឆ៖** មាស វ៉ាត់ អត់មាន។ ខ្ញុំឆ្លើយទៅ បញ្ជូនទៅណា មានតែ មាស វ៉ា។ គេបញ្ជូនមកពីតាកែវមកនៅតាមសហករណ៍នេះ មានតែ មាស វ៉ា ទេ ខ្ញុំឆ្លើយ។ ព្រោះ មាស វ៉ាត់ នៅជាប់ជាមួយខ្ញុំរហូតទាល់ដល់គ្នាចេញរួចមកផ្ញើនៅភូមិតារាបទេ។ មាស រតនា ហៅ វ៉ាត់ហ្នឹង ចេញជាមួយម្ដាយខ្ញុំរួបប្អូនខ្ញុំហ្នឹង ចេញពីគុកហ្នឹង។

**ស៖** តើលោកធ្លាប់ឮមន្ទីរមួយឈ្មោះ ម១០៥ ទេ?

**ប្រធានអង្គជំនុំ៖**

លោក លោកកុំអាលឆ្លើយតប!

**លោក មាស សុខា៖**

**ឆ៖** អឺម១០៥ ហ្នឹងខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែមន្ទីរ២០៤ ហើយប៉ុន្តែនៅទីតាំងដែលចម្ការសៀង គេដាក់ជួរកម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហម អ្នកថ្នាក់ឃុំ ថ្នាក់ប្រធានកង ឬប្រធានស្រុកអីនៅចម្ការសៀង នៅមុខភ្នំដំរីរមៀល។ អាហ្នឹងខ្ញុំ ពួកអង្គរក្សគុកគេនាំខ្ញុំទៅជួយជញ្ជូនគល់ឈើ គល់ជន្លង់សណ្ដែក ខ្ញុំឃើញមន្ទីរហ្នឹងមួយកន្លែង។ ប៉ុន្តែគេថាមន្ទីរអីៗខ្ញុំអត់ដឹងទេ។ប៉ុនគ្រាន់គេថាមន្ទីរៗឃុំឃាំងមនុស្សដែរ "កន្លែងនេះអ្អែងកុំដើរចូលផ្ដេសផ្ដាស" គ្រាន់តែប៉ុណ្ណឹងទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីឱ្យមានការកត់ត្រាចូលក្នុងកំណត់ហេតុសវនាការ។ នៅក្នុងឯកសារ E3/4145 ដែលជាឯកសារបង្ហាញអម្បាញ់មិញដោយសហព្រះរាជអាជ្ញានៅពេលសួរលោក។ ទាំងអស់មាន ១១ទំព័រ -- សុំទោសមានប្រាំបីទំព័រ ហើយមានបញ្ជីហ្នឹងគេដាក់ថាបញ្ជីអ្នកទោសឃុំនៅមន្ទីរម១០៥ "អស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយសូមការសម្រេចពីបក្ស"។ ឈ្មោះទី៤នៅក្នុងបញ្ជីនេះ គឺមានថាឈ្មោះ មាស វ៉ា មកពីភូមិស្រែគ្រួ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំអត់មានសំណួរសួរលោកទៀតទេ សូមអរគុណលោកសាក្សី សូមអរគុណលោកប្រធាន។

[១២:០៦:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយនិងសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកសមរម្យដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ផង ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះចុះ ហើយនិងឲ្យបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៧ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៦:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនាំមុខដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយសូមបញ្ជាក់ថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល២០នាទី នៅក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ពីព្រឹកមិញពេលដែល -- សូមអរគុណដែលបានផ្តល់ឱកាសឲ្យខ្ញុំសួរសំណួរ តែខ្ញុំសូមចាប់អារម្មណ៍បន្តិចពីព្រឹកមិញ ពេលដែលលោក លោកស្រី លោកចៅក្រម, លោកស្រីចៅក្រមបានសួរសំណួរ ពេលនោះម៉ោងដប់មួយនិងសាមសិបប្រាំនាទី។ ដូច្នេះប្រហែលជាខ្ញុំអាចមានរហូតដល់ទៅ ២៥នាទី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមជម្រាបសួរលោក មាស សុខា។ បាទ ខ្ញុំបាទ ឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាជនរងគ្រោះដែលបានដាក់ពាក្យធ្វើជាភាគីមួយនៅចំពោះមុខសាលាក្តីនេះ។ ខ្ញុំមានសំណួរមួយចំនួនសួរលោក ហើយខ្ញុំសង្កេតឃើញថាព្រឹកមិញលោកបានឆ្លើយសំណួរជាច្រើន ទាំងថ្ងៃទី០៨ ខែមករា កន្លងទៅនេះ។ ខ្ញុំមានសំណួរ -- សំណួររបស់ខ្ញុំជាដំបូងពាក់ព័ន្ធទៅនឹងជីវិតរបស់លោក កាលលោកនៅកងចល័ត ខ្ញុំចង់សុំសួរថាតើពេលដែលលោកនៅកងចល័ត លោកអាចជម្រាបបានទេ ថាតើការដេក ការស្នាក់នៅរបស់លោកមានលក្ខណៈយ៉ាងដូចម្តេចដែរនៅពេលដែលលោកនៅកងចល័តនាឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦នោះ? បាទ សូមអញ្ជើញ។

[១៣:៣៨:១២]

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំជម្រាប ជីវិតរបស់ខ្ញុំពីបញ្ហាជំនាន់ ៧៥ និង ៧៦ ខ្ញុំពេញវ័យអាយុ ១៥ឆ្នាំ។ ប៉ុន្តែពីមុនហ្នឹងខ្ញុំគេឲ្យឃ្វាលតែគោទេ ព្រោះគោឪពុកខ្ញុំ គឺគោសម្រាប់បររទេះ បររទេះដឹកសេដ្ឋកិច្ច គឺអត់អ្នកមើលគឺអត់បានទេ។ ប៉ុនពេលណាមើលគោផ្ទាល់ខ្លួន ពេលណាមើលគោរួមក៏មាន ពេលរួមដោយខ្លួនពេលកម្មសិទ្ធិដោយខ្លួន ពេលសម្រាប់បររទេះដឹកសេដ្ឋកិច្ចឲ្យកងចល័ត។ ខ្ញុំអត់ដែល--

**ស៖** សូមអធ្យាស្រ័យ ខ្ញុំចង់លើកសំណួរសាជាសាថ្មី។ ថាតើពេលដែលលោកធ្វើការនៅក្នុងកងចល័តហ្នឹង តើការស្នាក់នៅរបស់លោកយ៉ាងដូចម្តេចដែរ? តើលោកមានផ្ទះសម្បែងត្រឹមត្រូវនៅក្នុងការស្នាក់នៅដែរឬទេ នៅពេលដែលលោកសម្រាន្ត ថាតើលោកសម្រាន្តនៅកន្លែងណា?

**ឆ៖** ខ្ញុំសម្រាន្តនៅតែផ្ទះ ព្រោះខ្ញុំដូចជាស្រួលដែរជំនាន់នោះ។ ខ្ញុំនៀយតែមើលគោមួយមុខ។ ពេលគេឲ្យទៅកង គេឲ្យខ្ញុំមើលគោ យប់ឡើងឲ្យមកនៅដេកផ្ទះ។ អត់មានទៅដេកនៅព្រៃ នៅវាលតាមកងចល័តគេទេ ព្រោះខ្ញុំ កងខ្ញុំមានតែប្រាំមួយនាក់ទេ សម្រាប់តែមើលគោ។

**ស៖** អម្បាញ់មិញលោកនិយាយថា លោកអត់មានទៅដេកក្នុងព្រៃ ឬនៅវាលទេ។ ថាតើអ្នកណាដែលទៅដេកនៅព្រៃ ឬក៏នៅវាលដូចគេហ្នឹង ដែលហ្នឹងថាតើពួកគាត់គឺជានរណា?

[១៣:៤០:០៨]

**ឆ៖** គឺក្រុមគេអ្នកធ្វើការពលកម្មរែកដី រែកប្រឡាយ រែកត្រពាំង រែកភក់ រែកដីដំបូក គេដេកក្នុងវាលហើយ គេទៅរែកកន្លែងណា គឺគេទៅបោះទីតាំងនៅដេកកន្លែងនោះ គេអត់បានមកផ្ទះទេ។

**ស៖** តើគេមានផ្ទះសម្បែងត្រឹមត្រូវដូចលោកដែរឬទេ?

**ឆ៖** ខ្លះគេមានដែរ ប៉ុន្តែមេកងគេម៉េចនឹងឲ្យមក។

**ស៖** បាទ ខ្ញុំចង់សុំសួរអំពីការស្លៀកពាក់របស់លោក សម្លៀកបំពាក់របស់លោកវិញ ថាតើលោកមានសម្លៀកបំពាក់គ្រប់គ្រាន់ទេនៅក្នុងការធ្វើការរបស់លោកហ្នឹង?

**ឆ៖** សម្លៀកបំពាក់ខ្ញុំអត់គ្រប់គ្រាន់ទេក្នុងមួយឆ្នាំស្លៀកតែមួយតែចង្កេះហ្នឹង ស្លៀកទៅស្លៀកមកហ្នឹង សើមព្រឹកស្ងួតល្ងាចអ៊ីចឹងទៅ។

**ស៖** តើស្លៀកពាក់អ៊ីចឹងថាតើអាចមានប៉ះពាល់អ្វីទៅដល់សុខភាពរបស់លោកដែរឬទេ?

**ឆ៖** សុខភាពខ្ញុំកាលនោះដូចវាធម្មតាទេ អត់មានដែលឈឺថ្កាត់ទេ ដូចសព្វថ្ងៃអ៊ីចឹងព្រោះខ្ញុំអត់អត់ដែលទម្លាប់រឿងស្លៀកពាក់តាំងពីតូចអ៊ីចឹង មានក៏ស្លៀកអត់ក៏ហី មានតែខោខ្លីមួយចេះតែស្លៀកទៅ។

**ស៖** អ្នកដែលឈឺ ឬក៏ថាសមាជិករបស់ក្រុមលោក ថាតើធ្លាប់មានអ្នកឈឺដែរឬទេប្រសិនបើគាត់ឈឺថាតើគាត់មានបានទទួលការព្យាបាលដែរឬទេ?

**ឆ៖** ឈឺដឹង អត់ដែលដឹងមានពេទ្យអីណាផង ដឹងថាមានពេទ្យឃុំគេនៅមន្ទីរពេទ្យវត្តមឿងថាហ្នឹង ប៉ុន្តែអត់ដែលឃើញនរណាទៅ ខ្ញុំអត់ដែលដឹងរឿងមន្ទីរពេទ្យខ្ញុំអត់ដែលចូលព្រោះអីខ្ញុំអត់ដឹងថាមានមនុស្សឈឺ។

[១៣:៤២:៣៤]

**ស៖** បាទសូមអរគុណលោក មាស សុខា។ ខ្ញុំសួរលោកអំពីបញ្ហាមួយទៀតគឺការអប់រំរបស់លោក លោកបាននិយាយអំពីកាលពីថ្ងៃ០៨ ខែ មករា កន្លងទៅនេះថាមាន អត់មានសាលាអីទេមានការបង្រៀនអីនៅតាមបន្តិចបន្តួចនៅតាមក្រោមដើមឈើ តើលោកបានមានប្រសាសន៍អ៊ីចឹងមែនដែរឬទេពីថ្ងៃមុន?

**ឆ៖** បានមានប្រសាសន៍អ៊ីចឹងមែន រៀននៅក្រោមដើមឈើ ដើមម្លប់ដូងម្លប់ឈើហ្នឹង។

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាតើពេលអ្វីដែលលោករៀនហ្នឹងលោករៀនអំពីអ្វីខ្លះ?

**ឆ៖** រៀនពីរឿងការងារធ្វើពលកម្ម រីកចម្រើនធ្វើស្រែមួយហិកតាបីតោន តែប៉ុណ្ណឹង។

**សះ** តើមានការបង្រៀនអំពីអក្សរឬក៏លេខអ្វីទេ?

**ធះ** អត់ដែលឃើញមានបង្រៀនអក្សរផង ឃើញតែក្ការខៀនគេដាក់ចោលនៅហ្នឹង ហើយគ្រូគេមិនដឹងនៅទីណា គ្រូមេកងកុមារហ្នឹង គេអត់ចេះដូចគ្នាមិនដឹងទៅបង្រៀនថាម៉េច គ្រូអត់ចេះ សិស្សក៏អត់ចេះ មិនដឹងបង្រៀនអីគេ បើខ្ញុំអត់ដែលដឹង ឃើញគ្រូហ្នឹងអត់ចេះដូចគ្នា។

**សះ** ខ្ញុំសូមសួរមួយនៅពេលដែលលោករៀនហ្នឹង ថាតើលោកមានធ្លាប់ឮគ្រូគាត់និយាយពាក្យមួយដែលនិយាយថា "អង្គការជាឪពុកម្ដាយរបស់កុមារ" អីទេ?

**ធះ** ដែលឮព្រោះអង្គការជាឪពុកម្ដាយរបស់គេ សសរទ្រូងនៃប្រទេសជាតិ។ កុមារគឺទំពាំងស្នងឫស្សី។

**សះ** តើគេមានជម្រាបលោកថាតើយើងត្រូវប្រព្រឹត្តយ៉ាងដូចម្ដេច ឬក៏ធ្វើយ៉ាងដូចម្ដេចជាមួយនឹងអង្គការហ្នឹងដែរឬទេ?

**ធះ** គេឲ្យស្រលាញ់អង្គការឥតព្រំដែន។

**សះ** ហើយក្រៅពីនេះ មានអីទៀតទេ អំពីការណែនាំអ្វីរបស់អង្គការ? គេថាតើត្រូវធ្វើយ៉ាងម៉េចចំពោះការណែនាំរបស់អង្គការ?

**ធះ** ឲ្យស្រលាញ់សាមគ្គីគ្នា ហូបបាយរួម ដេករួម តែប៉ុណ្ណឹង។

**សះ** ខ្ញុំចង់សួរលោក ថាតើពេលនោះលោកមានយល់ទេ ថាតើអង្គការហ្នឹងគឺជាអ្នកណា? ឬក៏ជាអ្វី? នៅពេលនោះលោកមានយល់ទេ ថាតើមានន័យថាយ៉ាងដូចម្ដេច "ពាក្យអង្គការ"នោះ?

**ធះ** ពាក្យ "អង្គការ" ខ្ញុំដឹងថាថ្នាក់លើអ្នកធំ អ្នកខាងលើ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**សះ** បាទខ្ញុំចូលទៅដល់បញ្ហាមួយទៀតអំពីទំនាក់ទំនងរវាងឪពុកម្ដាយរបស់លោកថា លោកបាននៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយសហចៅក្រមស៊ើបអង្កេត។ លោកបាននិយាយថា គេឲ្យលោកទៅលេងផ្ទះដប់ថ្ងៃម្ដង។ ថាតើអីចឹងមែនទេ? ហើយខ្ញុំភ្ជាប់សំណួរតែម្ដង ថាតើ ១០ថ្ងៃម្ដងហ្នឹងថាតើជាការ -- បើសិនជាថាក្នុងករណីហ្នឹងមែន ថាតើជាសេចក្ដីសម្រេចរបស់ខាងណាមក ដែលឲ្យមានកម្មវិធីជួបជុំគ្រួសារ ១០ថ្ងៃម្ដងនេះ?

[១៣:៤៦:៤៥]

**ធះ** ការជួបជុំគ្នា១០ថ្ងៃម្ដង គ្រាន់តែគេថា ប៉ុន្តែគ្មានបានពេលណាបានមកដល់ផ្ទះ ព្រោះដូចនៅជាស្រុកបុរីជលសារិញ គ្នាម៉េចបានមកដល់ផ្ទះ គ្រាន់តែថាឲ្យបានជួបជុំ គ្រាន់ថាតែមាត់ ប៉ុនអត់ដែល

បានមកផង។ ធ្វើការកាប់ប្រឡាយ កាប់ជីកព្រែកធ្វើប្រាំងនៅស្រុកអង្គរបុរី។ ហើយនៅស្រុកត្រាំកក់ ក្នុងមួយថ្ងៃហ្នឹងដើរត្រឡប់ទៅត្រឡប់មក ដើរអត់ទាន់ទេ ប៉ុនគ្រាន់តែគេថាឲ្យយើងមក ប៉ុនមិនដឹង អត់ដែលឃើញមនុស្សមកផង។

**ស៖** ខ្ញុំចង់សួរបញ្ជាក់លោកអំពីបញ្ហាហ្នឹងបន្តិច ថាតើ១០ថ្ងៃម្តងហ្នឹង គឺជាអ្វី? ជាថ្ងៃឈប់សម្រាក ឬក៏ជាៗពេលវេលាយ៉ាងដូចម្តេចរយៈពេល ១០ថ្ងៃម្តងនុង?

**ឆ៖** ១០ថ្ងៃម្តងគ្រាន់តែពាក្យថាឲ្យឈប់ ប៉ុន្តែពេលកម្មគេត្រូវជឿនលឿន គេត្រូវតែធ្វើ។ គ្រាន់តែថាសម្រាក១០ថ្ងៃម្តង ប៉ុននៅតែធ្វើការងារដដែល។

**ស៖** ចុះគោលការណ៍ឈប់សម្រាក១០ថ្ងៃម្តងនេះ តើលោកដឹងទេថានៅកន្លែងផ្សេង គេមានគោលកាណ៍ហ្នឹងដែរឬទេ?

[១៣:៤៨:១៧]

**ឆ៖** កន្លែងផ្សេងខ្ញុំអត់ដឹងទេ គេឆ្ងាយពីកន្លែងខ្ញុំ ខ្ញុំអត់ដឹង បាទកន្លែងខ្ញុំ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** បាទអរគុណ។ ខ្ញុំចង់សួរលោកថែមទៀត ពាក់ព័ន្ធទៅនឹងរឿងគ្រួសារហ្នឹង។ នៅពេលដែលលោកមិនបានមកជួបជុំគ្រួសាររយៈពេល ១០ថ្ងៃម្តងហ្នឹង ថាតើលោកមានការនឹករឭកដល់ក្រុមគ្រួសារដែរឬទេ?

**ឆ៖** ខ្ញុំនឹក។ នឹករហូតរត់មកលួចមកផ្ទះទៀតនុះ។ រត់ហើយគេតាមមកចាប់ខ្ញុំទៀត ពេលទៅកង។ បើខ្ញុំនឹក ខ្ញុំរត់។

**ស៖** តើលោកអាចពន្យល់បានទេ ការនឹករឭកហ្នឹង សម្រាប់លោកហ្នឹងមានន័យថា យ៉ាងដូចម្តេច ដើម្បីឲ្យអ្នកផ្សេងៗទៀតគេអាចយល់បាន? ថាតើអត្ថន័យនៃការនឹករឭកហ្នឹងមានន័យថាយ៉ាងដូចម្តេច?

**ឆ៖** ខ្ញុំនឹកម្តាយខ្ញុំ ពុកខ្ញុំ។ ប៉ុន្តែម្តាយឪពុកទៅធ្វើការក្រៅអស់ហើយ វាគ្រាន់មក។ និយាយរួមខ្ជិលធ្វើការផង ការងារហត់ពេក អស់កម្លាំងផង។

[១៣:៤៩:៣៣]

**ស៖** អម្បាញ់មិញលោកនិយាយអំពីរឿងខ្ជិលធ្វើការ។ ខ្ញុំចង់សុំសួរលោក ថាតើលោកមានសេរីភាពក្នុងការជ្រើសរើសការងាររបស់ខ្លួនហ្នឹងដែរឬទេ ដែលលោកនិយាយថា ឃ្វាលគោ ឃ្វាលក្របីនេះ?

**ឆ៖** ពេលឃ្វាលគោ ពេលណា ខ្ញុំនឹក គេ -- សុំគេមក គេមិនឲ្យមក ជ្រើសរើសម៉េច ស្រេចគេចាត់តាំង។ គេចាត់តាំងឲ្យមើលតែម្ដង។

**ស៖** លោកមិនអាចធ្វើការងារហ្នឹងបានដែរឬទេ?

**ឆ៖** ត្រូវតែធ្វើ អត់ប្រកែកបាន។

**ស៖** មានអ្វីកើតឡើង ប្រសិនបើ -- សូមទោស បាទ។ នៅពេលដែលលោកធ្វើការងារហ្នឹង ថាតើលោកបាន មានបានទទួលផលប្រយោជន៍អ្វីជាសម្ភារៈ ឬក៏ជាអង្ករ អ្វីសម្រាប់យកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬក៏ក្រុមគ្រួសាររបស់លោកដែរឬទេ?

**ឆ៖** បាទ របស់អ្វី? បើផ្ទាល់ខ្លួន បើសម័យនោះជាសម័យបាយរួម បាយរួម ស៊ី ហូបទាំងអស់គ្នា។ អត់មានរបស់អីមកផ្ទាល់ខ្លួនបានទេ គឺមានផ្ទាល់ខ្លួន មានតែចានមួយ ស្លាបព្រាមួយ។ ចានយួរៗ គេដាក់រួមដដែល តែយកកម្មសិទ្ធិក៏អត់បានដែរ មានចានរួមហើយ។ ពេលហូបចុកអីចឹង គេដាក់ចានមកឲ្យមក។ យើងដឹងតែមើលគោ។

[១៣:៥១:២៩]

**ស៖** បាទ ខ្ញុំចូលទៅដល់បញ្ហាផ្សេងមួយទៀត ពាក់ព័ន្ធទៅនឹងរឿងបញ្ហាព្រះពុទ្ធសាសនា។ លោកបានឆ្លើយមួយចំនួនពាក់ព័ន្ធទៅនឹងរឿងការផ្សឹកព្រះសង្ឃ។ ក៏ប៉ុន្តែនៅក្នុងឃ្លាមួយដែលលោកបាននិយាយនៅថ្ងៃទី០៨ ខែមករា កន្លងទៅនេះ វេលាម៉ោងដប់មួយ និង សាមសិបនាទី លោកបានមានប្រសាសន៍ថា៖ "មានព្រះសង្ឃមួយអង្គ ព្រះនាម នន្ទ ង៉ែត មិនព្រមសឹក។ តើព្រះនាមរបស់ព្រះអង្គអីចឹងមែនឬទេ? ហើយថាបន្ទាប់ពីលោកមិនព្រមសឹកហ្នឹង ថាតើមានអ្វីកើតឡើងចំពោះព្រះសង្ឃហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំឮចាស់ៗស្រុកហ្នឹងគេនិយាយថា លោកអត់ព្រមសឹក។ សឹកៗមែន ប៉ុន្តែដោះតែស្បង់ក្រហមចេញ ស្លៀកតែ-ស ពាក់-ស នៅតែវត្ត អត់ដែលទៅណាមកណាផង។ នៅទល់ដល់គ្នា៧៩ លោកមក ដែលបួសនៅនឹងវត្តលង្ការវិញ។ ព្រោះកាលណោះខ្ញុំក្មេង ព្រោះលោក ឆ្នាំ៧៤ គាត់មិន -- លោកគេដេញឲ្យមកនៅគង់តាមភូមិស្រែគ្រួហ្នឹង ចុងខាងកើតហ្នឹង។ ប្រហែលជាបួនដប់អង្គ នៅវត្តព្រៃជោរ ដេញយកមកនៅនឹងភូមិខ្ញុំហ្នឹងតែម្ដង ហើយលោកអត់ព្រមដោះស្បង់ចីពរ។ ដល់៧៥ គេតឿនឲ្យលោកសឹកទៀត។ លោកបានសម្រេចចិត្តថា ដោះស្បង់ចីពរនៅធ្វើសង្គមកិច្ចចុះ។

[១៣:៥៣:២៣]

**ស៖** "សង្គមកិច្ច" ថាតើសង្គមកិច្ចនេះគឺជាអ្វីទៅ? តើលោកធ្វើកិច្ចការអ្វីខ្លះ ក្នុងនាមជាសង្គមកិច្ចពេលនោះ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

កុំអាល់ឆ្លើយ! ចាំមើលក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណ៎ះ!

**លោក មាស សុខា៖**

**ឆ៖** សង្គមកិច្ច គាត់ផ្សំថ្នាំឫសឈើសម្រាប់តាមកង តាមអី ប៉ុន្តែមិនដែលឃើញអ្នកណាយកទៅផឹកផង អត់ដែលឃើញ។ គាត់គ្រាន់តែចិញ្ច្រាំឲ្យតែមាន១ អ្នកណាត្រូវការលួចលាក់អីចឹង គាត់ចេះតែឲ្យទៅ។ កូនក្មួយលោកអីចឹងទៅ ប៉ុន្តែមិនដឹងយកទៅដាំផឹកណាផងសម័យនោះ អត់ដែលឃើញអ្នកណាដាំផឹក។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមអរគុណ។ ខ្ញុំឈានទៅរឿងបញ្ហាក្រាំងតាចាន់បន្តិច ខ្ញុំព្យាយាមមិនមានសំណួរច្រំដែលពាក់ព័ន្ធទៅនឹងអ្វីដែលបានសួរពីមុនទេ។ ខ្ញុំចង់សុំសួរលោកបញ្ជាក់បន្ថែមបន្តិច ដែលលោកនៅក្រាំងតាចាន់ជិតបីឆ្នាំ លោកមានសង្កេតមើលទេថា តើមនុស្សដែលគេយកមកដល់ក្រាំងតាចាន់ហ្នឹងជាទូទៅ ពេលវេលាដែលដល់ហ្នឹង ដែលនាំមកដល់ ម៉ោងប៉ុន្មានដែរ លោកអាចបញ្ជាក់ពីបញ្ហាហ្នឹងបានទេ?

**ឆ៖** មនុស្សនាំពីក្រាំងតាចាន់ភាគច្រើន មកពេលយប់ម៉ោងប្រាំបីយប់ ឬម៉ោងប្រាំបួនយប់ អត់កម្រពេលថ្ងៃណាស់ ពេលថ្ងៃតែក្រុមគ្រួសារខ្ញុំមួយក្រុមទេ ពេលថ្ងៃ ហើយនិងខាងឃុំញ៉ែងញ៉ង ឃុំស្រែរនោងនោះ មួយរយជាងនាក់ហ្នឹង កាលយកមកសម្លាប់ពេល១ រហូតដល់ម៉ោងប្រាំបីយប់អាហ្នឹងពេលថ្ងៃ ក្រៅពីហ្នឹងសុទ្ធតែយប់។

[១៣:៥៥:២៨]

**ស៖** តើគេមានបានបែងចែកយ៉ាងម៉េចជាមួយនឹងអ្នកដែលនៅថ្មី -- នៅចាស់ នៅក្នុងមន្ទីរឃុំឃាំងហ្នឹងដែរឬទេ? អ្នកដែលមកដល់ថ្មីគេដាក់លាយឡំជាមួយអ្នកចាស់ ឬក៏គេដាក់ដាច់ដោយឡែកពីអ្នកចាស់? ដូចជាករណីក្រុមគ្រួសាររបស់លោកនេះ។

**ឆ៖** អត់បែងចែកទេ។ កំណាត់តែពេញហ្នឹងតែម្តង កំណាត់ពេញក្នុងផ្ទះហ្នឹង ថាក្នុងផ្ទះហ្នឹងមាន

១០០នាក់ គឺដាក់១០០នាក់ហ្នឹងឲ្យពេញទៅ, ផ្ទះហ្នឹងដាក់ ៥០នាក់ពេញ ៥០ទៅ, ផ្ទះមួយទៀត ៧០នាក់ ៧០នាក់ដាក់ពេញទៅ ពេញហើយគេយកទៅ។

**ស៖** លោកបាននិយាយអំពីផ្ទះអម្បាញ់មិញ ខ្ញុំហាក់ដូចជាយល់មិនច្បាស់ ថាតើផ្ទះដែលឃុំឃាំងមនុស្សហ្នឹង មានមួយ ឬក៏ពីរ ឬក៏បី នៅក្រាំងតាចាន់ហ្នឹង?

**ឆ៖** មានផ្ទះបីអគារសម្រាប់ដាក់អ្នកទោសហ្នឹងតែម្តង។

**ស៖** បាទ អរគុណ។ ខ្ញុំចង់សួរបញ្ជាក់បន្តិច ចំពោះអ្នកដែលមានកូនតូចថា តើគេដាក់កូនតូចហ្នឹងនៅកន្លែងណា? ដូចជាករណីបងប្អូនស្រីរបស់លោកមានកូនតូច ឬក៏ថាប្អូនតូចរបស់លោកហ្នឹង ថាតើពេលយប់ឬក៏ពេលថ្ងៃគេឲ្យនៅជាមួយម្តាយដែរ ឬក៏យ៉ាងម៉េចមុនដែលកូនហ្នឹងស្លាប់ទៅ?

**ឆ៖** កូនតូចនៅជាមួយម្តាយ អត់មានបែកពីម្តាយកើតទេ។ មិនដឹងយកទៅដាក់ឯណា ក្រៅពីម្តាយឪពុក ម្តាយអ្នកឱបបី ដេកពីលើម្តាយហ្នឹងអ៊ីចឹងទៅ ព្រោះកន្លែងចង្អៀតដេកលើម្តាយហើយ នោមក៏លើម្តាយដែរ អាចម៍ លាមកហ្នឹងក៏លើម្តាយដែរ។

**ស៖** ពេលដែលកូនហ្នឹងស្លាប់ ឬក៏ថាករណីរបស់សាច់ញាតិរបស់លោកដែលស្លាប់ហ្នឹង ថាតើលោកមានឱកាសម្រាប់ធ្វើបុណ្យទៅដល់ ឬក៏សាច់ញាតិរបស់លោកមានឱកាសធ្វើបុណ្យសម្រាប់ពួកគាត់ហ្នឹងដែរឬទេ?

**ឆ៖** ពុំមានសាច់ញាតិណាធ្វើបុណ្យកើតទេសម័យនោះ ព្រោះសម័យនោះគឺសម័យបំបាត់ព្រះពុទ្ធសាសនា ហើយយើងនៅជាប់ក្នុងពន្ធនាគារទៀត មានពេលឯណាធ្វើបុណ្យកើត?

[១៣:៥៨:១៨]

**ស៖** ខ្ញុំមានសំណួរមួយចំនួនតូចទៀត ខ្ញុំគិតថាខ្ញុំជិតដល់ម៉ោងហើយ។ ខ្ញុំចង់សុំសួរថាតើបន្ទាប់ពីបែក ប៉ុល ពតទៅ –សម័យកម្ពុជាប្រជាធិប្បតេយ្យទៅ– ថាតើលោកមានឱកាសទៅរកមើលឆ្អឹងធាតុរបស់សាច់ញាតិរបស់លោកដែលបានស្លាប់នៅក្រាំងតាចាន់ដែរឬទេ?

**ឆ៖** ខ្ញុំទៅរកដែរអដ្ឋិធាតុ ប៉ុន្តែរកពុំឃើញទេ ព្រោះកប់ច្រើនគ្នាពេក។ គ្រាន់តែទៅធ្វើជាគណៈកម្មការសាងសង់នៅទីនោះជាមួយម្តាយខ្ញុំ និងបងប្អូនសាច់ញាតិអ្នករួមស្លាប់ជាមួយគ្នា ភូមិនានាហ្នឹង។

**ស៖** ខ្ញុំសុំសួរលោកបន្ថែមទៀតថា បច្ចុប្បន្ននេះថា តើលោកចង់ឲ្យគេធ្វើអ្វីសម្រាប់ជា សម្រាប់ក្រុមគ្រួសារលោកដែលបានស្លាប់ទៅ ឬក៏ថាសម្រាប់លោកដែលជាជនរងគ្រោះនៅទីនោះដែរឬទេ? នៅទីកន្លែងក្រាំងតាចាន់នុ៎ង?

**ឆ៖** ខ្ញុំចង់ឲ្យរដ្ឋាភិបាលជួយអំពាវនាវឲ្យសហគមន៍អន្តរជាតិ និងអន្តរជាតិនានា ដែលជួយសាងសង់ជាសមិទ្ធិផលអ្វីមួយនៅទីនោះជាតំណាងនិមិត្តរូប។

**ស៖** សំណួរចុងក្រោយបំផុតដែលខ្ញុំមានសម្រាប់ថ្ងៃនេះ ដោយសារដល់ម៉ោងហើយ។ លោកបានឆ្លើយទៅនឹងលោកចៅក្រម ឡាវែន៍ ពាក់ព័ន្ធទៅនឹងរឿងប្រមាត់ ដែលយកទៅដាក់នៅក្នុងស្រា។ តើលោកអាចពន្យល់បានទេថាតើគេយកប្រមាត់ហ្នឹងទៅដាក់នៅក្នុងស្រាហ្នឹងដើម្បីអី ប្រមាត់មនុស្សហ្នឹង?

[១៤:០០:៣២]

**ឆ៖** គេដាក់សម្រាប់ផឹក ប្រមាត់។ ផឹកឲ្យក្លាហាន។ ប៉ុន្តែប្រមាត់ច្រើនមិនដឹងយកទៅណាខ្លះខ្ញុំអត់ដឹង។ ឃើញគេដាក់មួយពីរអ៊ីចឹងទៅនៅក្នុងស្រាមួយកាទិន គេមានដាក់ច្រើនឯណា។

**ស៖** តើការយល់ -- លោកមានប្រសាសន៍ថា ដាក់នៅក្នុងស្រា ផឹកដើម្បីឲ្យក្លាហានហ្នឹង ថាតើអាហ្នឹងជាការយល់ឃើញជាទូទៅរបស់មនុស្ស ឬក៏ការយល់ឃើញរបស់កងឈ្លប ឬក៏ថាអ្នកនៅក្រាំងតាចាន់តែមួយ ឬក៏ថានៅកន្លែងផ្សេងគេយល់របៀបអ៊ីចឹងដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរបែបនេះទេ។ បាទ សំណួរបែបនេះមិនអាចស្វែង -- ឈានទៅដល់រកការពិតបានទេ។

បាទ ចប់ហើយ អស់ពេលហើយណ៎ាលោកមេធាវី។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញៗលោកមេធាវី!

**លោក សួន វិសាល៖**

សូមគោរពតុលាការ! ខ្ញុំឈ្មោះ សួន វិសាល ជាមេធាវីការពារក្តីឲ្យលោក នួន ជា។ ហើយមុននឹងសួរ ខ្ញុំចង់សង្កត់ធ្ងន់ទៅលើលោកសាក្សីដែរថា អ្វីដែលខ្ញុំសួរគឺថាចង់ស្វែងរកការពិត ហើយសំណួរ-- ចម្លើយអាចខ្លីៗតែប៉ុណ្ណោះ ព្រោះដោយសារលោកបានឆ្លើយច្រើនហើយនៅចំពោះមុខសវនាការនេះតាមរយៈសំណួររបស់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សួន វិសាល៖**

**ស៖** សំណួររបស់ខ្ញុំគឺចែកចែងជាបួនវគ្គធំៗ គឺទី១ ខ្ញុំសួរលោកអំពីជីវភាពរបស់លោកទាក់ទង

ទៅនឹងសហករណ៍ និងកងកុមារ ហើយទី២ ទាក់ទងទៅនឹងការចាប់ខ្លួនរបស់លោកនៅមន្ទីរឃុំឃាំងក្រាំងតាចាន់ ហើយទី៣ ទាក់ទងទៅនឹងការសម្លាប់មនុស្ស និងទី៤ ទាក់ទងទៅនឹងការធ្វើទារុណកម្មអ្នកទោស។ អ៊ីចឹង សំណួរខ្ញុំទី១ គឺទាក់ទងស្ថានភាពនៃការរស់នៅរបស់លោក។ ខ្ញុំចង់ដឹងថា តើលោកនៅកងកុមារហ្នឹង តើគេជ្រើសរើសរបៀបណាបានជាលោកក្លាយទៅជាសមាជិកកងកុមារបាទ?

**លោក មាស សុខា៖**

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

ឈប់អាល កុំទាន់អាលឆ្លើយតប! ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក មាស សុខា៖**

**ឆ៖** គេជ្រើសរើសតាំងពីអាយុ១៥ឆ្នាំ ក្រោមអាយុ១៥ឆ្នាំ ទៅតាមកងកុមារ។ ដល់អាយុ១៧ គេបញ្ជូលទៅខាងយុវជនត្រៀម។

**សួរដោយលោក សួន វិសាល៖**

**ស៖** កាលពីថ្ងៃទី០៨ ខែមករា លោកបានឆ្លើយនៅចំពោះមុខអង្គសវនាការថា លោកនៅជាសមាជិកកងកុមារ គឺថាពី -- ទើបអាយុ១៥ ហើយនៅពេលអាយុ ១៥គឺលោកមានកងយុវជន។ បានន័យថាកងបម្រុង។ តើនៅពេលនោះ លោកធ្វើជាកងបម្រុង ឬក៏នៅកងកុមារបាទ?

**ឆ៖** ខ្ញុំកងបម្រុងកុមារ។

**ស៖** កងបម្រុងកុមារ។ អ៊ីចឹងសំណួរបន្ទាប់ទៀត គឺថាខ្ញុំចង់ដឹងថា តើនៅក្នុងសហគមន៍របស់លោកមានកុមារប៉ុន្មាននាក់បាទ?

**ឆ៖** កងបម្រុងខ្ញុំមានតែគ្នាប្រាំមួយនាក់ទេ តែកងគេផ្សេង គេច្រើន ខ្ញុំរាប់មិនអស់ ព្រោះខ្ញុំបម្រុងឲ្យមើលគោ។

**ស៖** បាទ នៅពេលដែលលោកទៅធ្វើការនៅកងបម្រុង ប្រាំមួយនាក់ហ្នឹង តើគេមានកំណត់ទីតាំងនៅកន្លែងណាមួយច្បាស់លាស់ទេ ឬមានអ្នកដឹកនាំនៅក្រុមនោះដែរឬទេបាទ?

[១៤:០៤:៤៦]

**ឆ៖** មានទីតាំងកន្លែងក្រោលហ្នឹងតែម្ដង សម្រាប់ទីតាំងនៅយប់ព្រលប់ ហើយសង្កេតការណ៍គេមានប្រាំមួយនាក់ អ៎! ពីរនាក់ទៀតកងឃ្លបគេជាមួយ -- ឃ្វាលជាមួយ។

**សៈ** បានន័យថានៅពេលដែលលោកទៅធ្វើការនៅកងកុមារហ្នឹង គឺមានកងឈ្លបសម្រាប់តាមលោកដែរ។ អ៊ីចឹងមែនទេបាទ?

**ឆៈ** មានកងឈ្លបពីរនាក់។

**សៈ** បាទ សូមអរគុណ។ ខ្ញុំចង់សួរបន្ទាប់ទៀត។ អម្បាញ់មិញលោកបាននិយាយថា លោកមានលក្ខណៈពិសេសជាងអ្នកដទៃ គឺថាលោកបានមកសម្រាន្ត បានទៅធ្វើការនៅកងហើយ ប៉ុន្តែលោកបានសម្រាកនៅផ្ទះរហូត។ អ៊ីចឹងមែនទេបាទ?

**ឆៈ** ខ្ញុំបានសម្រាកនៅផ្ទះមែន ព្រោះខ្ញុំតូចជាងគេ គេឲ្យមកផ្ទះ។

**សៈ** បាទ សូមអរគុណ។ ខ្ញុំសូមដកស្រង់ទាក់ទងទៅនឹងចម្លើយរបស់លោកបន្តិច នៅកាលពីលោកឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត ឯកសារ D25/31 ឯកសារជាទំព័រជាភាសាខ្មែរគឺលេខ 00163511, ឯកសារជាភាសាបរទេសគឺ 00223495។ ក្នុងនោះលោក -- ខ្ញុំសូមដកស្រង់បាទ៖ "លោកនៅកងកុមារមានគេមានឲ្យលោកទៅលេងផ្ទះសម្បែងដែរឬទេ? ហើយប៉ុន្មានថ្ងៃគេឲ្យទៅម្តង?" ចម្លើយលោកឆ្លើយ៖ "កាលនៅកងកុមារនោះ គេឲ្យនៅឆ្ងាយពីក្រុមគ្រួសារដាច់ស្រយាល មិនដែលបានជួបគ្នាទេ។ ១០ថ្ងៃគេឲ្យមកលេងផ្ទះម្តង ក្នុងរយៈពេលប្រហែល២០នាទី"។ តើលោកចម្លើយរបស់លោកនៅចំពោះមុខចៅក្រមស៊ើបអង្កេតហ្នឹង អម្បាញ់មិញនេះតើពិតទេបាទ? លោកឆ្លើយអ៊ីចឹងទេ?

[១៤:០៧:០៤]

**ឆៈ** ខ្ញុំឆ្លើយពិតមែន ប៉ុន្តែមិនមែនចំពោះរូបខ្ញុំម្នាក់ទេ រូបទូទៅ។

**សៈ** បានន័យថា លោកឆ្លើយអ៊ីចឹងមែន ហើយលោកឆ្លើយជំនួសគេទេ មិនមានរឿងរបស់លោកផ្ទាល់ទេ។ អ៊ីចឹងមែនទេបាទ?

**ឆៈ** ពិតមែនហើយ។

**សៈ** បាទ អរគុណ។ ខ្ញុំសួរបន្តទៀត។ នៅ -- ចុះទាក់ទងនឹងការហូបចុកវិញ តើហូបចុករបៀបណាដែរ លោកនៅពេលនៅកងកុមារនោះ?

**ឆៈ** ពេលហូបចុក ហូបរួមគ្នា។ ក្រុមខ្ញុំប្រាំមួយនាក់ ហូបប្រាំមួយនាក់ទៅ។ គេកងគេផ្សេង គេហូបផ្សេងទៅ មិនមែនមួយកងណា មនុស្សរាប់រយនាក់។

**សៈ** បាទ តើលោកបានម្ហូបអាហារហ្នឹងពីណាមក? ពីណាធ្វើចុងភៅឲ្យលោកពេលនោះ ក្រុមលោក?

**ឆ៖** បាយទឹក--

**ប្រធានអង្គជំនុំ៖**

មើលក្បាលមីក្រូហ្វូនមិនប្រតិបត្តិការ? ហើយដាច់វិញ?

**លោក មាស សុខា៖**

**ឆ៖** ការហូបចុកពេលនោះវាអាស្រ័យតាមសហករណ៍គេបញ្ជូនមកឲ្យទៅយកតាមក្រុម។ ក្រុមទីមួយៗអ្នកណានៅកងណា អ្នកណាធ្វើអី គឺអ្នកហ្នឹងទៅយកម្ហូប។

**សួរដោយលោក សួន វិសាល៖**

**ស៖** តើម្ហូបអាហារពេលនោះ គឺគ្រប់គ្រាន់ឬទេបាទ?

**ឆ៖** អាហារពេលនោះ វា--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ!

[១៤:០៩:០៤]

**លោក ពេជ អង្គ៖**

សូមអរគុណលោកប្រធាន។ តាមការពិតខ្ញុំតាមដានសំណួរដោយយកចិត្តទុកដាក់របស់លោកមេធាវីរបស់លោក នួន ជា ឃើញថាសំណួរច្រើនច្រំដែល ហើយសំណួរអម្បាញ់មិញ ចុងក្រោយនេះក៏ច្រំដែលដែរ។ អ៊ីចឹងសូមលោកប្រធានមេត្តាដើម្បីចំណេញពេល ធ្វើយ៉ាងណាកុំឲ្យមានការលើកសំណួរច្រំដែលនេះបាទ។ សូមអរគុណលោកប្រធាន។

**លោក សួន វិសាល៖**

សូមអរគុណ ប៉ុន្តែខ្ញុំចង់បញ្ជាក់អ៊ីចេះថា សំណួររបស់គឺអត់ច្រំដែលទេ គឺថាពីមុនមកគឺថាអត់មានដឹងប្រភពចំណូល ឬក៏ម្ហូបអាហារហ្នឹងពីណាមកទេ។ តាមវគ្គដែលខ្ញុំឆ្លងកាត់មក គឺថាអ្វីដែលខ្ញុំឆ្លើយ គឺព័ត៌មានថ្មីដែលស្វែងរកការពិតបាទ។ ដូច្នេះ ខ្ញុំសូមលោកអនុញ្ញាតបន្តសួរទៀតបាទ។

**ប្រធានអង្គជំនុំ៖**

បាទ សំណួរ -- សេចក្តីជំទាស់របស់មេធាវីនាំមុខតំណាងរដ្ឋប្បវេណីគ្មានមូលដ្ឋានត្រឹមត្រូវទេ។ សាក្សីឆ្លើយតបនឹងសំណួរដែលមេធាវីការពារក្តីបានសួរលោកនូវសំណួរចុងក្រោយអម្បាញ់មិញនេះ។

**លោក មាស សុខា៖**

**ឆ៖** ខាងម្ហូបអាហារយកពីតាមកង គេកងណាគេយកពីសហករណ៍នោះ សហករណ៍គេចាត់ចែងឲ្យក្នុងគ្នាប្រាំមួយនាក់យកប្រាំមួយនាក់ គ្នា២០នាក់យក២០នាក់ គ្នា១០នាក់ យក១០នាក់។ តាមសហករណ៍ម្ហូបអាហារមានសេដ្ឋកិច្ចគេអ្នករក ប៉ុនហូបវាមិនគ្រប់គ្រាន់។

[១៤:១០:៣០]

**សួរដោយលោក សួន វិសាល៖**

**ស៖** អរគុណ។ នៅពេលដែលលោកហូបអត់គ្រប់គ្រាន់ តើលោកអាចមានឱកាសក្នុងការដើររកម្ហូបអាហារបន្ថែមសម្រាប់ហូបចុកនៅពេលនោះទេបាទ?

**ឆ៖** អត់មានពេលរកម្ហូប ហូបចុកឯកជនបានទេពេលនោះ គឺអ្វី របស់អ្វីក៏ដោយក៏ត្រូវតែហូបរួម ស៊ីរួមអីចឹងហ្មង គេសង្កត់ប្រាប់តែអីចឹង ស៊ីហូបឯកជន គឺមានរឿងអីចឹងតែម្ដង។

**ស៖** ឥឡូវនេះខ្ញុំមានសំណួរលោកបន្តទៀតទាក់ទងទៅនឹងកិច្ចការរបស់លោកតែម្ដង កាលពីថ្ងៃទី០៨ ខែមករា លោកបានឆ្លើយនៅចំពោះមុខតុលាការ ថាលោកនៅក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យលោកបានឃ្វាលគោតែប៉ុណ្ណោះ ហើយមិនដែលជីកប្រឡាយ ឬរែកដីទេ។ តើចម្លើយនេះជាចម្លើយត្រឹមត្រូវរបស់លោកទេបាទ?

**ឆ៖** ពិតមែនហើយ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមដកស្រង់សម្ដីរបស់លោកនៅចំពោះមុខចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី៣១ ខែតុលា ២០០៧ បាទ ឯកសារ D25/31 ឯកសារជាទំព័រជាភាសារខ្មែរ 00163511, ភាសាបរទេស 00223494។ ខ្ញុំសូមដកស្រង់បាទ វគ្គសំណួរ គឺបានន័យថាសំណួរ "សួរ៖ នៅសម័យនោះតើលោកធ្វើការអ្វីដែរ?" ចម្លើយរបស់លោក៖ "គេឲ្យខ្ញុំលើកអាចម៍គោ លើកប្រឡាយនៅកងកុមារ"។ តើចម្លើយនេះជាចម្លើយរបស់លោកឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ចម្លើយ លើកអាចម៍គោ កើបអាចម៍គោនេះ អ្នកឃ្វាលគោត្រូវតែលើកហើយអាចម៍គោហើយប្រឡាយ តែកាលណាយើងទំនេរខ្លះយើងត្រូវទៅជួយជីកគេខ្លះ។ ចម្លើយរបស់ខ្ញុំពិតជាត្រឹមត្រូវ។

**ស៖** ប៉ុន្តែចម្លើយរបស់ខ្ញុំចង់សួរថាតើលោកធ្លាប់បានឆ្លើយតែប៉ុណ្ណឹង ឬយ៉ាងម៉េច?

[១៤:១២:៤៥]

**ឆ៖** បាទៗ។

**ស៖** បាទសូមអរគុណ។ ខ្ញុំចង់សួរបន្តទៀត គឺថានៅពេលដែលលោកនៅក្នុងកងកុមារថាតើលោកធ្លាប់បានជួបប្រាស្រ័យទាក់ទងជាមួយនឹងក្រុមគ្រួសារ ឬឪពុកម្ដាយរបស់លោកឬទេនៅពេលនោះ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

បាទកុំទាន់ឆ្លើយ ក្បាលមីក្រូមិនទាន់ប្រតិបត្តិការទេ។

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំអ្នកឃ្វាលគោអាចនឹងមកជួបម្ដាយខ្ញុំ ឪពុកខ្ញុំពេលនោះ ព្រោះខ្ញុំជាកូនគោ ពេលយប់ឡើងគេឲ្យខ្ញុំមកផ្ទះ ព្រោះតូចជាងគេ។

**សួរដោយលោក សួន វិសាល៖**

**ស៖** សូមអរគុណ។ តើឪពុកម្ដាយរបស់លោកធ្វើអ្វីដែរនៅពេលនោះ?

**ឆ៖** ឪពុកខ្ញុំគេឲ្យធ្វើត្បាល់កិនសម្រាប់កិនស្រូវ ហើយធ្វើដងរែកសម្រាប់រែកដី ឬរែកអ្វីៗទាំងអស់។ ហើយម្ដាយខ្ញុំអ្នករែងអង្ករនៅសហករណ៍ពីព្រោះគាត់កូនខ្ចីគេឲ្យគាត់រែងអង្ករ។

**ស៖** តើឪពុកម្ដាយរបស់លោកទៅនៅក្នុងសហករណ៍របស់គាត់ នៅកន្លែង -- ខ្ញុំចង់សួរថាតើនៅពេលនោះតើសហករណ៍របស់ឪពកម្ដាយរបស់លោកហ្នឹងនៅឯណា? ចម្ងាយប៉ុន្មានពីកន្លែងផ្ទះរបស់លោក?

[១៤:១៤:២០]

**ឆ៖** សហករណ៍ភូមិខ្ញុំនៅចម្ងាយ ១០០ម៉ែត្រពីផ្ទះខ្ញុំ។

**ស៖** នៅជិត បាទនៅជិតតែម្ដងបាទ។

**ឆ៖** បាទ។

**ស៖** សូមសួរបន្តទៀត គឺខ្ញុំសូមសួរបន្តទៀតទាក់ទងទៅនឹងការចាប់ខ្លួនរបស់លោក។ លោកបានអះអាងថាលោកក៏បាន ត្រូវបានគេចាប់ខ្លួននៅខែមិថុនា ឆ្នាំ១៩៧៦ ហើយពេលនោះក៏ត្រូវបានចាប់ខ្លួនផងដែរ។ តើនៅពេលដែលចាប់ខ្លួន ខ្ញុំចង់បញ្ជាក់ឡើងវិញ តើមានគេចាប់ចំនួនប៉ុន្មាននាក់ដែរ?

**ឆ៖** ចំនួនចាប់ខ្លួនក្រុមគ្រួសារខ្ញុំមាននៅកន្លែងហ្នឹង តែថ្ងៃចាប់រូបខ្ញុំ ម្ដាយខ្ញុំមាន ១២នាក់ក្រុមគ្រួសារខ្ញុំ អ៎! ១០នាក់ ហើយអ្នកផ្សេងមានបួននាក់ ក្រុមគ្រួយាយស៊ិន នោះមានពីរនាក់--

**ស៖** បាទ ខ្ញុំចង់ដឹងតែចំនួនទេបាទ។ អ៊ីចឹងលោកថា ក្រុមគ្រួសាររបស់លោក គឺ១២នាក់។ បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំចង់ដកស្រង់សម្ដីរបស់លោកឡើងវិញនៅចំពោះមុខចៅក្រមស៊ើបអង្កេត គឺថាឯកសារ D25/31 ឯកសារជាភាសាខ្មែរគឺ 00163513, ជាភាសាអង់គ្លេសគឺ 223496។ ខ្ញុំសូមដកស្រង់បាទ "ខ្ញុំមកពីឃ្វាលគោ ខ្ញុំបានឃើញកងឈ្លបកំពុងបណ្ដើរបងប្អូនក្រុមគ្រួសាររបស់ខ្ញុំ ហើយគេឃើញខ្ញុំ គេក៏ហៅខ្ញុំ ដោយប្រាប់ថាឲ្យទៅតាមម្ដាយឯងទៅ។ បងប្អូនម្ដាយខ្ញុំនោះរួមមាន ម្ដាយ បងស្រី ប្អូនប្រុសស្រី ក្មួយ សរុបទាំងអស់ ទាំងខ្ញុំផងមានចំនួនប្រាំបីនាក់ ព្រមទាំងមានអ្នកភូមិប្រាំនាក់ទៀតផង នៅជាមួយផង។" តើនេះជាចម្លើយរបស់លោកឬទេ បាទ?

**ឆ៖** ចម្លើយខ្ញុំ។

**ស៖** បាទ សូមអរគុណ។

[១៤:១៩:២០]

**ប្រធានអង្គជំនុំ៖**

ម្ដងទៀត កុំអាលទាន់ឆ្លើយណ៎ា ព្រោះក្បាលមីក្រូមិនទាន់ប្រតិបត្តិការទេ ស្ដាប់តែពីរនាក់ទេ បានតែអ្នកឆ្លើយជាមួយនឹងមេធាវីហ្នឹងទេ។

**លោក មាស សុខា៖**

**ឆ៖** ចម្លើយរបស់ខ្ញុំ ពិតជាត្រឹមត្រូវ។

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទ ឥឡូវ ខ្ញុំសួរលោកទាក់ទងទៅនឹង គេបញ្ជូនលោកទៅដល់ពន្ធនាគារក្រាំងតាចាន់។ តើនៅពេលទៅដល់ គេអ្នកពន្ធនាគារបានរាក់ទាក់លើលោកយ៉ាងម៉េចដែរ បានន័យថាប្រព្រឹត្តមកលើយ៉ាងម៉េចដែរ?

**ឆ៖** អ្នកនាំចូលពន្ធនាគារនេះ គេនាំចូលទៅដល់ពីមាត់ទ្វារច្រកចូល គេនាំចូលទៅដល់ក្នុងអគារគុកហ្នឹងតែម្ដង ហើយគេនាំឲ្យចូល ហើយបងស្រីខ្ញុំ ហើយម្ដាយខ្ញុំ គេដាក់ឲ្យ ដាក់ខ្នោះ។

**ស៖** លោកបានទៅទីនោះប្រហែលជា២០ ទៅ២៥ថ្ងៃ។ តើក្នុងចន្លោះពេលនោះ តើលោកធ្វើអ្វីដែរ? គេប្រព្រឹត្តមកលើរូបលោកយ៉ាងម៉េចដែរ?

**ឆ៖** ២៥ថ្ងៃ ទៅមួយខែហ្នឹង ព្រោះខ្ញុំមិនដែលគេប្រព្រឹត្តអ្វីទេ គ្រាន់តែសួរចម្លើយម្ដាយខ្ញុំ ព្រោះគេអត់ទាន់លែងឲ្យធ្វើការងារក្រៅឃុំទេ។

**ស៖** ខ្ញុំសូមសួរសំណួរមួយទៀត។ តើហេតុអ្វីបានជាគេឲ្យលោកនៅក្រៅឃុំ មិនដាក់គុកលោក ហើយឲ្យលោកនៅក្រៅទីលានពន្ធនាគារហ្នឹង ហេតុផលអី? លោកមានដឹងទេ?

**ឆ៖** រឿងហ្នឹង ខ្ញុំអត់ដឹង ព្រោះដឹងហេតុផលថាគេឲ្យខ្ញុំនៅខាងក្រៅឃុំ យប់ឡើងគ្រាន់គេហៅទៅបាញ់សត្វ ឬផ្ទុះកង្កែបតែប៉ុណ្ណឹង ខ្ញុំដឹង ហើយជិតភ្លឺឡើង ឡើងដឹកក្របីទៅភ្ជួរជាមួយគេតែប៉ុណ្ណឹងទេ ដឹងតែប៉ុណ្ណឹងទេ ហេតុផល។

[១៤:១៨:៤៦]

**ស៖** ក្រៅពីរូបលោក តើមានអ្នកទោសណាផ្សេងទៀតដែលគេផ្តល់សេរីភាពឲ្យលោកបែបនេះទេ?

**ឆ៖** មានខ្លះដែរមាន តាចិន, តាសែន ហើយ សុក សាន, សុត ហ្នឹង ប៉ុន្តែគាត់រួចពីឆ្នាំ៧៧។ សុក សុត ចំណែកខ្ញុំ ហើយសែន ហើយតាចិន រួចដំណាលគ្នា។

**ស៖** នៅពេលដែលគេឲ្យនៅក្រៅ តើគេឲ្យលោកធ្វើអ្វីដែរ?

**ឆ៖** គេឲ្យខ្ញុំឃ្វាលតែក្របី ហើយនិងគោពីរ ក្របីបួន។

**ស៖** តើមានអ្នកផ្សេងទៀត ដែលទៅឃ្វាលក្របី ឃ្វាលគោជាមួយលោកឬទេនៅពេលនោះ?

**ឆ៖** អត់មានទេ គេការងារផ្សេង អ្នកពីរបីនាក់នោះ ពីរនាក់ ហើយ សុក សាន គាត់អ្នកឡើងត្នោត។

**ស៖** តើលោកទៅឃ្វាលក្របីនៅទីណា នៅពេលដែលលោកទៅ?

**ឆ៖** ឃ្វាលក្របី និងឃ្វាលគោអត់កំណត់ព្រំដែន គឺថាឲ្យតែម៉ោងប្រាំចូលមកដល់កន្លែង។

**ប្រធានអង្គជំនុំ៖**

តទៀត តសំណួរទៀត!

**សួរដោយលោក សួន វិសាល៖**

**ស៖** ជាធម្មតា លោកទៅឃ្វាលក្របីនៅម៉ោងប៉ុន្មាន?

**លោក មាស សុខា៖**

**ឆ៖** ពេលថ្ងៃម៉ោងមួយ ម៉ោងពីរអីចឹង ពេលមេឃត្រជាក់មេឃក្តៅ។ មេឃក្តៅម៉ោងពីរទៅ មេឃត្រជាក់ម៉ោងមួយទៅ។

**ស៖** ខ្ញុំសួរខ្ញុំចង់សួរបន្ថែមទៀតទាក់ទងទៅនឹងនៅពេលដែលគេផ្តល់សេរីឲ្យលោក។ តើគេ

អនុញ្ញាតឲ្យលោកដើរពេញទីលានពន្ធនាគារហ្នឹងឬទេបាទ ឬយ៉ាងម៉េច? គេមានផ្ដល់មានកំណត់ថាតើលោកត្រូវមានសិទ្ធិដើរត្រឹមនេះ ឬក៏មានកំណត់ដើរត្រឹមនោះ? ឬក៏លោកអាចដើរចូលកន្លែងណាក៏បាន?

**ឆ៖** គេអត់ដែលឃុំឃាត់ខ្លួនខ្ញុំដើរទៅណាមកណា គេស្រេចតែចិត្តខ្ញុំដើរ ឲ្យតែកុំឲ្យបាត់ក្របី គេនិយាយតែប៉ុណ្ណឹង ព្រោះក្របីឡើងក វាអត់ទឹក វាចេះតែរើដាច់ហើយ វារត់ហើយ។

[១៤:២១:៣៥]

**ស៖** ប៉ុនអ្វីដែលខ្ញុំចង់សួរអ៊ីចេះ! ថាតើនៅទីលានពន្ធនាគារ តើលោកអាចដើរៗគ្រប់អគារដើរលេងសេរីនៅក្នុងទីលានហ្នឹងបានដែរឬទេ? ឬក៏ចូលកន្លែងណាក៏បាន ឬក៏យ៉ាងម៉េចបាទ?

**ឆ៖** ខ្ញុំដើរសេរីចូលកន្លែងណាក៏បាន ព្រោះខ្ញុំយប់ឡើងគេប្រើទៅយកនេះទៅយកម្ហូបស៊ីកន្លែងចង្ក្រានបាយពួកក្រុមអង្គរក្សអ៊ីចឹងទៅ។ ពេលថ្ងៃអ៊ីចឹង គេប្រើយកដកព្រលឹត ដកបេះម្អម បេះអំពិលយកឲ្យគេស្លហូបអ៊ីចឹងទៅ ទៅចាប់ត្រីចាប់កង្កែបយកទៅឲ្យគេអ៊ីចឹងទៅ។ ថ្ងៃណាខ្ញុំដើរទៅណាក៏បានខ្ញុំដើររហូតដល់ភ្នំដំរីរមៀលទៀត។

**ស៖** បានន័យថា លោកមានសិទ្ធិឬក៏មានអំណាចដូចមន្ត្រីពន្ធនាគារដែរ ឬយ៉ាងម៉េចបានលោកមានសិទ្ធិទាំងអស់ឬយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សូមតាំងសំណួរឲ្យបានត្រឹមត្រូវ សិទ្ធិហើយនិងអំណាចហ្នឹងដូចជាខុសគ្នាឆ្ងាយ លោកមេធាវី។ ហើយកុំឲ្យជៀសមានការឆ្លើយតបហ្នឹងភ័ន្តច្រឡំ ព្រោះការផ្ដល់សិទ្ធិគឺផ្សេង ហើយផ្ដល់អំណាចហ្នឹងដូចជារឿងមួយផ្សេងទៀត។

[១៤:២២:៥៤]

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទសូមអរគុណលោកចៅក្រម។ ខ្ញុំចង់បញ្ជាក់ថាតើគាត់មានសិទ្ធិដូចអ្នកដែលគ្រប់គ្រងពន្ធនាគារហ្នឹងឬទេបាទ?

**លោក មាស សុខា៖**

**ឆ៖** គេកំណត់ឲ្យខ្ញុំថា "អ្នែងប៉ាន់តែរត់ចោលម៉ែឪ គឺអញសម្លាប់ម៉ែឯងចោល" ហើយខ្ញុំអត់ប៉ានរត់។ ខ្ញុំរត់ទៅណាបើគេថា "ឯងដើរទៅណាដើរចុះ ប៉ុន្តែតិចតែឯងរត់ទៅណាទៅណឺបាត់បួនប្រាំយប់ ឬមួយខែពីរខែ គេសម្លាប់ម៉ែឯងចោលហើយ" និយាយតែប៉ុណ្ណឹង។ ខ្ញុំដល់អ៊ីចឹង ខ្ញុំអត់ប៉ាន

រត់។ ខ្ញុំអត់ហ៊ានទៅណាចោល ព្រោះខ្ញុំដើរបានត្រឹមដី ៣គីឡូ ៤គីឡូអ៊ីចឹងទៅ ពេលថ្ងៃ។ អ៊ីចឹងដើរឃ្វាលគោឃ្វាលអ៊ីចឹង ដើរនាំឲ្យវាស៊ីអ៊ីចឹងទៅ។

**ស៖** ចំពោះអ្នកទោសផ្សេងទៀត តើគេមានវិន័យ អ្នកដែលរស់នៅក្នុងពន្ធនាគារគេមានវិន័យច្បាស់លាស់ឬទេ នៅពេលដែលអ្នកទោសទាំងអស់ចូលទៅក្នុងពន្ធនាគារនោះបាទ?

**ឆ៖** អ្នកទោសទាំងអស់យប់ថ្ងៃអី មានវិន័យគេ។ ដេកអត់ឲ្យរើ អត់ឲ្យស្រែក អត់ឲ្យថ្ងូរ អត់ឲ្យនិយាយគ្នា តែហ៊ានរើគឺៗរើអ៊ីចឹងតែម្ដងយប់ឡើង។

**ស៖** ខ្ញុំចង់សួរបន្ថែមទៀតគឺទាក់ទងទៅនឹងទីតាំងអគារពន្ធនាគារ ព្រោះកន្លងមកលោកបានបញ្ជាក់ខ្លះដែរ ប៉ុន្តែមិនទាន់បានច្បាស់លាស់អំពីបញ្ហាហ្នឹង។ តើអគារពន្ធនាគារហ្នឹងមានទ្រង់ទ្រាយរបៀបណា?

**ឆ៖** អគារទ្រង់ទ្រាយវា ដំបូលប្រក់ក្បឿង ជញ្ជាំងក្ដារ ពីក្រោមក្បឿងគេវែងលួសសំណាញ់បន្ទាលួស គេវែងដូចជាក្រឡាវែក ពីជញ្ជាំងគេវែងលួសក្រឡាវែកហ្នឹងសុទ្ធតែលួសបន្លា របងហ្នឹងពីក្រោមគេវែងលួស រនាបក្ដារ។

[១៤:២៥:១៣]

**ស៖** ពីអគារមួយទៅអគារមួយតើមានចម្ងាយប៉ុន្មានម៉ែត្រដែរ?

**ឆ៖** អគារពីរជាប់គ្នា អគារមួយដាច់គ្នាប្រហែល ១៥ម៉ែត្រ។

**ស៖** តើផ្ទះបាយនៅកន្លែងណាដែរបាទ?

**ឆ៖** ផ្ទះបាយអ្នកទោសនៅប្រឡោះកណ្ដាល។ ផ្ទះបាយអង្គរក្សគេនៅបៀតកន្លែងដែលសួរចម្លើយនៅជ្រុងពីខាងកើត។

**ស៖** នៅក្នុងពន្ធនាគារទាំងមូល លោកបានឆ្លើយថាដូចមានរបងពីរជាន់ កាលពីលោកផ្ដល់សក្ខីកម្មលើកមុន។ សួរថាតើរបងពន្ធនាគារហ្នឹងគេធ្វើរបៀបណា? គេសង់អំពីអី?

**ឆ៖** គេសង់ពីបង្គោលគ្រាក់ ហើយគេព័ទ្ធបន្លាលួស។

**ស៖** ចម្ងាយពីរបងទី១ ទៅរបងទី២ តើមានចម្ងាយប៉ុន្មានដែរ?

**ឆ៖** ចម្ងាយពីរបងទី១ របងទី២ គឺចម្ងាយប្រហែល ១០០ម៉ែត្រពីរបងចាស់។

**ស៖** នៅពេលដែលលោកចូលទៅក្នុងពន្ធនាគារនោះ ថាតើនៅមានដើមឈើ ឬក៏មានព្រៃអីទេនៅជុំវិញរបង ឬក៏កន្លែងដែលលោករស់នៅហ្នឹង កន្លែងពន្ធនាគារហ្នឹង?

[១៤:២៧:០៥]

**ឆ៖** មានដើមឈើទាលធំៗ ហើយមានដើមត្រាង មានគេច្រុះជាធាងដូងព័ទ្ធជុំវិញពីចំហៀងខាងត្បូង។

**ស៖** ប៉ុន្តែមិនមានព្រៃក្រាស់អីទេឬយ៉ាងម៉េច? មានព្រៃអីនៅជុំវិញមើលអត់ឃើញទេ បាំងព្រៃអីកើតទេ ឬក៏អត់ទេ ឬក៏មានដើមឈើខ្ពស់ៗតែប៉ុណ្ណឹង?

**ឆ៖** ព្រៃឈើអត់ក្រាស់ទេ មានព្រៃធំៗ ហើយរបងក្រោមកន្លែងគេឃាតកម្ម គេស្ទូកធាងដូង។

**ស៖** បាទ សូមអរគុណ ឆ្លើយតែសំណួររបស់ខ្ញុំបានហើយ ខ្ញុំមិនចង់-- ព្រោះអីយើងសន្សំពេលវេលាបាទ។ អូខេ សូមអរគុណច្រើន។ អ៊ីចឹងខ្ញុំចង់សួរលោកបន្តទៀតទាក់ទងទៅនឹងការសម្លាប់មនុស្ស។ នៅពេលដែលលោកបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត ខ្ញុំសូមដកស្រង់ -- ឯកសារ D25/31 ហើយជាភាសាខ្មែរ 00163516 និងភាសាបរទេស 00223499, នៅពេលនោះលោកបាននិយាយថា លោក -- នៅពេលដែលគេសម្លាប់មនុស្ស -- បានលបមើលទៅលើព្រឹត្តិការណ៍ហ្នឹង។ ហើយពេលនោះលោកបានឈរឡើងដើមឈើមើល ហើយដើមឈើនោះមានចម្ងាយប្រហែលជា ៥ម៉ែត្រពីទីតាំង ដែលគេសម្លាប់មនុស្ស។ ហើយលោកបានឃើញអ្វីៗទាំងអស់។ ខ្ញុំសូមដកស្រង់ "សំណួរ៖ ពេលលោកមើលនោះមានចម្ងាយប្រហែលប៉ុន្មានម៉ែត្រ? ចម្លើយរបស់លោកថា៖ "លបមើលនោះមានចម្ងាយប្រហែល ៥ម៉ែត្រ"។ តើនេះជាចម្លើយរបស់លោកឬទេ?

[១៤:២៨:១៩]

**ឆ៖** ជាចម្លើយរបស់ខ្ញុំ ពិតជាត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមឲ្យលោកពិចារណាឡើងវិញបន្តិចទាក់ទងទៅនឹងបន្ទប់សវនាការនេះបាទ។ តើចម្ងាយពីលោកទៅលោកចៅក្រមតើមានចម្ងាយប្រហែលប៉ុន្មានម៉ែត្រដែរបាទ?

**ឆ៖** ប្រហែល ៧ ទៅ៨ ម៉ែត្រ។

**ស៖** តាមការប៉ាន់ស្មានរបស់ខ្ញុំនៅពេលដែលយើងសម្រាកសវនាការនេះគឺថា ចម្ងាយពីលោកចៅក្រមទៅលោកចម្ងាយប្រហែលជា ១០ម៉ែត្របាទ។ អ៊ីចឹងបានន័យថា លោកនៅពេលដែលលបមើល គឺលោកឈរនៅចំកណ្តាលនេះទៅលោកចៅក្រមមែនទេបាទ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

លោកប្រធានខ្ញុំមិនដឹងថា មេធាវី -- មេធាវីការពារក្ដីគាត់សួរលឿនពេក។ ដូច្នេះការបកប្រែទៅជាភាសាអង់គ្លេសហាក់បីដូចជាពិបាកបន្តិច។ ដូច្នេះ សូមឱ្យដកឃ្លាបន្តិចរវាងសាក្សីហើយនិងមេធាវីការពារក្ដី បើមិនដូច្នេះទេគឺថាបកប្រែទៅជាភាសាអង់គ្លេសគឺថាមានការបាត់បង់នូវចម្លើយខ្លះៗពីសាក្សីរូបនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណនូវការគាត់សម្គាល់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ សូមបន្តតាំងសំណួរលោកមេធាវី ហើយសូមធ្វើឱ្យបានឃ្លាតគ្នាច្បាស់លាស់រវាងការសួរ ហើយនិងឆ្លើយដើម្បីឱ្យមានទុកពេលវេលាសមស្របសម្រាប់ការបកប្រែភាសា ហើយចំណែកឯសាក្សីក៏អាចឆ្លើយបានហើយ គឺនៅពេលណាដែលមានការក្បាលមីក្រូហ្វូនប្រតិបត្តិការ ព្រោះខាងអ្នកបច្ចេកទេស អាយ.ធី នោះគេបានសម្របសម្រួលលើការបើក ឬក៏បិទក្បាលមីក្រូហ្វូនរបស់លោកហើយ។ បាទសូមអញ្ជើញ!

[១៤:៣១:២៦]

**លោក សួន វិសាល៖**

បាទសូមអរគុណលោកប្រធាន ហើយនិងការកត់សម្គាល់របស់លោកព្រះរាជអាជ្ញា ខ្ញុំព្យាយាមបន្ថយល្បឿនរបស់ខ្ញុំបន្តិច។

ហើយសំណួរអម្បាញ់មិញគឺលោកសាក្សីមិនទាន់ឆ្លើយនៅឡើយទេបាទ សូមឱ្យលោកសាក្សីឆ្លើយបាទ។

**លោក មាស សុខា៖**

**ឆ៖** សំណួរសួរអម្បាញ់មិញនេះ លោកសួរខ្ញុំម្ដងទៀតខ្ញុំភ្លេចហើយ។

**ស៖** ខ្ញុំបានសួរលោកថា នៅពេលដែលលោកលបមើលគេធ្វើ ឬក៏ធ្វើឃាតមនុស្ស ឬក៏សម្លាប់មនុស្សហ្នឹង លោកនៅមានចម្ងាយ ៥ម៉ែត្រ ហើយបន្ទប់សវនាការនេះពីគម្លាតតាមការប៉ាន់ស្មានពីគម្លាតពីលោកចៅក្រមមកលោក ប្រហែលជា ១០ម៉ែត្រ។ អ៊ីចឹងខ្ញុំចង់សួរថាតើនៅពេលនោះគឺលោកចម្ងាយរបស់លោកហ្នឹងប្រហែលជាពាក់កណ្ដាលរវាងលោកចៅក្រម និងលោកទៅកន្លែងកើតហេតុ

អ៊ីចឹងមែនឬទេបាទ?

**ឆ៖** ចម្ងាយធ្វើឃាតកម្មចម្ងាយនោះគឺ --

**ប្រធានអង្គជំនុំ៖**

ឈប់ៗកុំអាលឆ្លើយៗ។ សូមអញ្ជើញ!

[១៤:៣២:៣៧]

**លោក មាស សុខា៖**

**ឆ៖** ចម្ងាយគេធ្វើឃាតកម្មចម្ងាយខ្ញុំថា៥ម៉ែត្រចុះ ព្រោះខ្ញុំនៅដេញគោនៅកៀកហ្នឹង ហើយខ្ញុំឡើងអើតមើល ហើយមានម្នាក់គេអ្នកឃាតកម្មគេថា ចង្អុលមុខខ្ញុំទៀតថា "អ្អែងដើរចេញ!"។

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទសូមអរគុណ។ អ៊ីចឹងបានន័យថានៅពេលដែលលោកមើលហ្នឹង គឺមានគេឃើញដែរ? បានន័យថាអ្នកដែលគេសម្លាប់មនុស្សហ្នឹងគេឃើញលោក ហើយដូចជាលោកអត់មានភ័យព្រួយអីទាល់តែសោះបាទ។ អ៊ីចឹងមែនទេ? ដូចជា បានន័យថាដំណើរការហ្នឹង ដូចមានន័យថាលោកមិនបាច់លបមើលក៏អាចទៅមើលបានដែរ ដូចអត់មានភ័យអីសោះបាទ។ អ៊ីចឹងមែនទេបាទ?

**ឆ៖** ភ័យដែរដល់គេគំរាមអ៊ីចឹង គេថា "អ្អែង" តែប៉ុណ្ណឹង ប៉ុន្តែអ្នកដែលប្រាប់ខ្ញុំហ្នឹងគេថា "អ្អែងថ្ងៃក្រោយថ្ងៃមុខកុំណា កុំទៅអើតមើលណា!" ខ្ញុំថា អើតមើលអីបើខ្ញុំដើរទៅប៉ះហ្នឹងហើយហ្នឹងបើគោក្របីដើរទៅត្រដុសនឹងរបងហ្នឹងហើយ វីរវដ្តលរបងមិនចាប់ខ្ញុំ រករឿងខ្ញុំ។

**ស៖** នៅពេលដែលលោកលួចមើលនោះ ថាតើលោកចំណាយពេលប៉ុន្មានដែរ?

**ឆ៖** ចំណាយពេលប្រហែលជា ១០នាទី។

**ស៖** បាទសូមអរគុណ។ លោកបានឆ្លើយថា -- ពីព្រឹកមិញលោកបានឆ្លើយថានៅពេលដែលសម្លាប់មនុស្សគឺថាមានរហូតពី ៥០ ដល់ ១០០នាក់ ហើយអម្បាញ់មិញនេះលោកថា ចំណាយពេល ១០នាទី តើលោកនៅ រាប់បានឃើញចំនួននេះនៅពេលណាបាទ?

[១៤:៣៤:២៩]

**ឆ៖** ចំនួនមនុស្សដឹងពេលគេយកមក ពេលគេយកមកគេរាប់មនុស្សដឹងហើយ បើគេកត់បញ្ជីចូល បញ្ជីហ្នឹងគេថាចំនួនប៉ុន្មាន ចំនួន១០០។

**ស៖** បាទៗ សូមអរគុណបាទ។ បានន័យថានៅពេលដែលអ្នកទោសចូល លួច លោកហ្នឹងបាន

ទៅមើលបញ្ជីអ្នកគុកហ្នឹង មើលថាគេកត់ប៉ុន្មានអីប៉ុន្មាន លោកមានសិទ្ធិអ៊ីចឹងដែរ? ឬយ៉ាងម៉េចបាទ?

**ឆ៖** ខ្ញុំអត់មានសិទ្ធិទៅមើលបញ្ជីគេ ប៉ុនគ្រាន់តែគេនិយាយគ្នាថា "អឺ! ថ្ងៃនេះ១០០នាក់ ថ្ងៃនេះ ៣០នាក់"។ ហើយខ្ញុំក៏ឃើញដែរ មនុស្សនាំម្តងៗ។ វានាំមួយយប់មានបីដង ឬពីរដង តិចបំផុតពីរដង ដែរមួយយប់។ មានម្តង២០នាក់អ៊ីចឹងមក នាំពីភូមិនានាអ៊ីចឹងទៅ។ ពីភូមិមួយទៅភូមិមួយ នាំមកដល់កន្លែងហ្នឹង មាន២០នាក់ មួយយប់, ៣០នាក់មួយយប់ ឬ១០នាក់មួយយប់អ៊ីចឹងទៅ។

**ស៖** សូមអរគុណច្រើន។ ដូច្នេះ ក្នុងន័យនេះលោក បានន័យថាឆ្មាំពន្ធនាគារហ្នឹងគឺទុកចិត្តលោកបំផុតហើយ គេធ្វើកិច្ចការងារអី ក៏លោកដឹងដែរ។ អ៊ីចឹងមែនទេបាទ?

**ឆ៖** គេទុកចិត្តខ្ញុំ ព្រោះអត់ហ៊ាននិយាយអីក្រៅពីក្នុងហ្នឹងផង ហ៊ានរឿង។

**ស៖** បាទសូមអរគុណបាទ។ ខ្ញុំ សំណួរខ្ញុំប៉ុណ្ណឹងទេ ដោយសារពេលវេលា។ ហើយខ្ញុំទុកវេលាបន្ទាប់ទៀតហ្នឹង ឲ្យសហការីរបស់ខ្ញុំនឹងសួរលម្អិតបន្តទៀតបាទ។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយដែរ។ ហើយមានប្រកាសសម្រាក ២០នាទី ចាប់ពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបីខ្វះប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:៤១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះផ្តល់វេទិកាជូន

ទៅមេធាវីការពារក្តី អន្តរជាតិការពារក្តីលោក នួន ជា បើសិនជាមានសំណួរអ្វី មានបំណងចង់សួរសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ តើលោកប្រធានអាចប្រាប់ខ្ញុំបានទេ ថាខ្ញុំនៅសល់ប្រហែលជាប៉ុន្មាននាទីទៀត ដើម្បីសួរទៅលើសាក្សីនេះ? មួយម៉ោងឬ? ឬមួយក៏យ៉ាងម៉េចដែលលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អឺ! កិច្ចប្រឹងប្រែងនេះ បើសិនជាយើងអាចធ្វើបាន ព្រោះយើងបានប្រាប់ហើយ ជម្រាបហើយថា យើងទំនងមួយពេលរសៀលនេះ ជូនភាគីទាំងពីរ។ មេធាវីការពារក្តី ទាំង នួន ជា ទាំង ខៀវ សំផន។ លើកលែងតែធ្វើមិនបានចុងម៉ោង អាហ្នឹងនឹងយើងបន្តទៅថ្ងៃស្អែកទៀត។ ហើយប្រសិនបើអាចប្រឹងបាន យើងគួរចប់ ធ្វើបាននោះគឺយើងធ្វើទៅ ដើម្បីឲ្យសម្រួលដល់សាក្សីអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់បានផង។ អានេះអាស្រ័យទៅលើស្ថានភាពចាំបាច់។ អ៊ីចឹង ពេលវេលាដែលនៅសេសសល់នេះ ជូនទៅក្រុមមេធាវីការពារក្តីទាំងពីរក្រុមបាទ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយដែលចង់សួរលោកអំពីអ្វីដែលលោកបាននិយាយប្រហែលជាមួយម៉ោងមុនកន្លងមកនេះ។ គឺថាលោកបាននិយាយអំពីគណៈកម្មាធិការ -- បានន័យថា លោកជាសមាជិកគណៈកម្មាធិការអដ្ឋិធាតុនៅក្រាំងតាចាន់។ តើវាជារឿងត្រឹមត្រូវដែរឬទេ? ប្រសិនបើវាជារឿងត្រឹមត្រូវ តើលោកអាចប្រាប់បានទេ ថាតើលោកក្លាយជាសមាជិកគណៈកម្មាធិការប្រមូលអដ្ឋិធាតុហ្នឹងនៅពេលណា?

[១៥:០០:៤០]

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំមិនមែនគណៈកម្មាធិការប្រមូលអដ្ឋិធាតុទេ។ ខ្ញុំជាគណៈកម្មាធិការសាងសង់។

**ស៖** លោកសាក្សី តើលោកអាចប្រាប់បានទេ ថាតើសកម្មភាពរបស់គណៈកម្មាធិការលោកហ្នឹង តើធ្វើសកម្មភាពអីខ្លះ? កសាង សាងសង់អ្វីដែរ?

**ឆ៖** សាងសង់ពីសាលាឆទាន។ សាងសង់ជាកន្លែងក្មេងរៀន ហើយគំនូរគូរ ផ្ទាំងរូប។

**ស៖** តើលោកទទួលខុសត្រូវសាងសង់ចេតិយ ឬក៏ស្តូប ដើម្បីរក្សាទុកអដ្ឋិធាតុ លលាដ៍ក្បាល

ផ្លឹងអ្វីដែរឬទេ?

**ឆ៖** កន្លែងស្តូប កសាង ខ្ញុំអត់បានសាងសង់ទេ។ ខ្ញុំសាងសង់តែសាលាឆទាន និងជាអំណោយរបស់បងប្អូនខ្ញុំចូលរួម។ ខ្ញុំធ្វើតែមួយគ្រាទេ សាងសង់នៅទីនោះ។

**សៈ** តើលោកចាំទេថានៅពេលណាដែលគេចាត់តាំងលោកឲ្យចូលរួមនៅក្នុងគណៈកម្មាធិការនេះ?

**ឆ៖** ឆ្នាំ២០០៦។ ខ្ញុំបានស្នើសុំដល់លោកមេឃុំគុស ឲ្យយកព្រះតេជគុណនៅខាងម៉ឿងចាជាកូនរបស់ខ្ញុំទៅសាងសង់នៅទីនោះ។

**សៈ** លោកសាក្សី លោកក៏បាននិយាយផងដែរ ថាលោកគឺជាទាហាននៅក្រោយឆ្នាំ៧៩។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំទាហានក្រោយឆ្នាំ៧៩ ដល់ឆ្នាំ៩៧។ ខ្ញុំឈប់ដោយស្ម័យប្រវត្តិ។

**សៈ** អ៊ីចឹង លោកធ្វើជាទាហានប្រហែលជា១៥ឆ្នាំ។ ខ្ញុំនិយាយអ៊ីចឹងត្រូវទេ?

[១៥:០៣:៤៤]

**ឆ៖** ត្រឹមត្រូវហើយ។

**សៈ** តើលោកឈរជើងនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំឈរជើងនៅខេត្តតាកែវ ស្រុកត្រាំកក់។

**សៈ** លោកសាក្សី តើលោកដឹងអំពីការស៊ើបអង្កេតព្រហ្មទណ្ឌដោយក្រសួងឃោសនាការ និងវប្បធម៌អំពីហេតុការណ៍ ក៏ដូចជាព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកដឹងអំពីការស៊ើបអង្កេតនេះដែរឬទេ?

**ឆ៖** រឿងស៊ើបអង្កេតនេះខ្ញុំអត់បានដឹងទេ កម្ពុជាប្រជាធិបតេយ្យ ខ្ញុំដឹងគ្រាន់តែកម្ពុជាប្រជាធិបតេយ្យធ្វើទារុណកម្មមនុស្ស។

**សៈ** លោកសាក្សី តើលោកដឹងអំពីការស៊ើបអង្កេតដែលធ្វើឡើងដោយមន្ទីរឃោសនាការ វិចិត្រសិល្បៈស្រុកត្រាំកក់ នៅក្នុងឆ្នាំ១៩៨៦ ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេរឿងហ្នឹង។

**សៈ** លោកសាក្សី ឥឡូវនេះខ្ញុំចង់លើកបង្ហាញបន្តិចអំពីថ្ងៃ អំពីកាលបរិច្ឆេទមួយគឺក្នុងឆ្នាំ៧៥ ដល់៧៩ គឺក្រោយខែមិថុនាឆ្នាំ៧៦ ហើយនិយាយឲ្យច្បាស់បន្តិចទៅ គឺនិយាយអំពីថ្ងៃដែលលោកបាន

ឃើញ គឺថាលោកនិយាយថាលោកបានឃើញការសួរចម្លើយអ្នកទោស គឺការច្រកស្បោងប្លាស្ទិកដើម្បីសួរចម្លើយអ្នកទោសនោះ។ តើលោកចាំថ្ងៃនោះច្បាស់ដែរឬទេ?

[១៥:០៦:០៣]

**ឆ៖** ខ្ញុំអត់ចាំច្បាស់ទេពេលនោះ គ្មានអ្នកណាកត់ត្រា ព្រោះខ្ញុំជាអ្នកទោសដែរ គ្រាន់តែឃើញគេច្រកម្ដង ហើយក្រោយមកខ្ញុំអត់បានត្រួតពិនិត្យទេ ដឹងៗពេលគេសួរចម្លើយប៉ុណ្ណឹង ព្រោះលែងមើលលែងគិតមើលទៀតហើយ ឃើញអ៊ីចឹងទៅហើយ។

**សៈ** ខ្ញុំយល់ ប៉ុន្តែខ្ញុំនៅតែចង់និយាយបន្តិច ខ្ញុំមិនមែនចង់សួរអំពីកាលបរិច្ឆេទទេ។ ប៉ុន្តែ លោកអាចចាំទេថាវាជារដូវក្ដៅ ឬក៏រដូវវស្សា?

**ឆ៖** ពេលសួរចម្លើយអត់មានរដូវប្រាំង រដូវវស្សាទេ មានអ្នកទោសកាលណាគេសួរពេលហ្នឹងគឺសួររាល់ថ្ងៃ។ ពេលព្រឹកគេសួរ ពេលថ្ងៃណាគេអត់សម្លាប់ គេសួរពេលថ្ងៃរសៀលទៀតទៅ។

**សៈ** ប៉ុន្តែលោកសាក្សី ខ្ញុំចង់និយាយអំពីថ្ងៃដែលគេច្រកថង់ប្លាស្ទិកនៅពេលដែលគេច្រកថង់ប្លាស្ទិកទៅលើអ្នកទោសហ្នឹង តើនៅពេលដែលគេច្រកហ្នឹងវានៅក្នុងរដូវប្រាំង ឬក៏រដូវវស្សា?

**ឆ៖** រដូវប្រាំង។

**សៈ** តើលោកចាំទេថាលោកនៅក្រាំងតាចាន់បានប្រហែលប៉ុន្មានខែប៉ុន្មានឆ្នាំហើយ ទើបលោកឃើញហេតុការណ៍ច្រកថង់ប្លាស្ទិកហ្នឹង?

**ឆ៖** បីខែ។

**សៈ** អ៊ីចឹង ខ្ញុំអាចនិយាយថា នៅថ្ងៃដែលលោកឃើញគេច្រកថង់ប្លាស្ទិកហ្នឹង គឺប្រហែលជាក្នុងខែ៩ ឆ្នាំ៧៦ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**សៈ** អ៊ីចឹង ខ្ញុំអាចនិយាយបានថា វានៅក្នុងរដូវវស្សានៅក្នុងឆ្នាំនោះ។ អ៊ីចឹងមែនទេ?

**ឆ៖** មិនដឹងរដូវវស្សា មិនដឹងរដូវប្រាំង កាលហ្នឹងខ្ញុំវាអត់ដឹងរដូវវស្សាប្រាំងទេ ពីព្រោះអត់ចេះដឹងរឿងរដូវវស្សាប្រាំង ដឹងមេឃក្ដៅ ដឹងថាក្ដៅ។

[១៥:០៩:០៥]

**សៈ** លោកសាក្សី តើនៅពេលទុំងលោកក្រោកពីពេលព្រឹក តើលោកអាចប្រាប់បានទេថាលោកសម្រាក ឬក៏លោក លោកសម្រាកនៅកន្លែងណាដែរ?

**ឆ៖** នៅកន្លែងក្រាំងតាចាន់ហ្នឹង គេប្រើខ្ញុំទៅយក បេះផ្លែក្រសាំងឲ្យគេធ្វើម្ហូរ។ ពេលព្រឹក។

**ស៖** ខ្ញុំចង់សួរលោកថា តើលោកសម្រាកនៅកន្លែងណានៅពេលយប់ហ្នឹង បានន័យថាយប់មុនថ្ងៃដែលលោកភ្ញាក់ឃើញគេ ឃើញហេតុការណ៍ហ្នឹង។ តើលោកសម្រាកនៅកន្លែងណាដែរ?

**ឆ៖** សម្រាកនៅក្បែរអគារគុកហ្នឹង គ្រែមួយក្រោមដើមឈើទាលហ្នឹង។

**ស៖** ដូច្នេះ លោកសម្រាកនៅក្នុងបរិវេណគុក ប៉ុន្តែមិនមែននៅក្នុងអគារជាមួយអ្នកទោសទេ អ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ។

**ស៖** តើលោកចាំបានទេថា លោកអាចចាំមុខ ឬក៏ចាំឈ្មោះអ្នកទោសដែលគេឃុំឃាំងនៅក្រាំងតាចាន់ តើលោកអាចនៅចាំមុខ ចាំឈ្មោះអ្នកនៅជាប់ឃុំឃាំងហ្នឹងដែរឬទេ?

[១៥:១០:៥០]

**ឆ៖** អ្នកស្លាប់បាត់អស់ហើយ ខ្ញុំចាំយ៉ាងម៉េចទៅ! ចាំតែអ្នកនៅរស់។

**ស៖** ឥឡូវនេះ ខ្ញុំសួរលោកសំណួរមួយទៀត។ លោក គឺថានៅថ្ងៃនោះ ថ្ងៃហេតុការណ៍កើតឡើងនោះ តើមានអ្នកទោសប្រហែលជាប៉ុន្មាននាក់ដែរ ដែលគេឃុំខ្លួននៅមន្ទីរនោះ?

**ឆ៖** ខ្ញុំអត់បានរាប់ទេ ដាក់ក្នុងពន្ធនាគារពេញៗអគារ ឲ្យខ្ញុំរាប់ម៉េចទៅ!

**ស៖** នៅថ្ងៃនោះ នៅថ្ងៃហេតុការណ៍នុ៎ង តើលោកចាំទេថា លោកអាចស្គាល់ -- បានន័យថានៅថ្ងៃដែលមានហេតុការណ៍កើតឡើងនោះ លោកអាចស្គាល់នរណាម្នាក់ អាចថាជាអ្នកភូមិជាមួយលោក ឬក៏អ្នកណាម្នាក់ដែលលោកស្គាល់ ហើយគេឃុំនៅទីនោះទេ?

**ឆ៖** គេអត់ឲ្យយើងឃើញទេអ្នកទោស គឺទុកតែ -- តែគេទៅគេសម្លាប់ហើយ គេអត់មានឲ្យចាំមុខទេ។ អ្នកភូមិខ្ញុំគេសម្លាប់អស់ហើយឲ្យខ្ញុំចាំម៉េចទៅ។

**ស៖** នៅពេលដែលលោកក្រោកឡើងនៅពេលព្រឹក តើមើលទៅឃើញមានអ្នកទោសនៅទីនោះទេ?

**ឆ៖** អ្នកទោសអត់មាននៅក្រៅឃុំទេ អ្នកទោសគឺខុសពីរូបខ្ញុំប៉ុន្មាននាក់គឺអត់មាននៅក្រៅឃុំទេ គឺដាក់ក្នុងឃុំទាំងអស់។ សួរចម្លើយហើយក៏ដាក់ក្នុងឃុំ អត់មានទុកចេញក្រៅវាលណាបានទេ គឺបញ្ចូលទៅក្នុងអគារទាំងអស់។

[១៥:១៣:១១]

**ស៖** តើលោកមានឃើញអ្នកទោស ឧទាហរណ៍ថាប៉ុន្មានថ្ងៃមុនមកដល់ក្រាំងតាចាន់ហ្នឹងដែរឬទេ?

**ឆ៖** អ្នកទោសមុនក្រាំង -- សួរខ្ញុំពេលអ្នកទោសមកក្រាំងតាចាន់ ហើយមុនខ្ញុំមកក្រាំងតាចាន់ ឬក្រោយក្រាំងតាចាន់? សូមឆ្លើយម្តងទៀតមើល!

**ស៖** ខ្ញុំចង់សួរអំពីអ្នកដែលត្រូវគេឃុំឃាំងនៅថ្ងៃដែលលោកឃើញហេតុការណ៍ហ្នឹង។ តើលោកអាច -- តើលោកឃើញគេ -- បានន័យថាមុនហេតុការណ៍ហ្នឹងកើតឡើងពីរបីថ្ងៃហ្នឹង លោកធ្លាប់ឃើញមាននរណាដែលគេនាំយកមកចូលក្នុងគុកហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបានជម្រាបប្រាប់តុលាការហើយតើ! គេនាំរាល់តែយប់។ លុះយប់បន្តិច យប់-- រាល់តែយប់ហ្នឹង។ មួយយប់ ១០នាក់ ២០នាក់ ៣០នាក់ ទៅ៥០នាក់ ក្នុងមួយយប់ៗ។ លោះថ្ងៃតិច។

**ស៖** លោកសាក្សី ខ្ញុំចង់សួរអ៊ីចេះ ថាតើលោកអាចចាំមុខ ឬក៏ចាំឈ្មោះអ្នកទោសដែលគេនាំយកមក អាចមួយថ្ងៃ ឬក៏ពីរថ្ងៃមុនពេលដែលលោកឃើញហេតុការណ៍ដែលគេច្រកថង់ប្លាស្ទិកហ្នឹង។ តើលោកចាំថា មុនមួយថ្ងៃ ពីរថ្ងៃដែលលោកឃើញហេតុការណ៍ហ្នឹង លោកមានចាំមុខអ្នកទោស ឬក៏ចាំឈ្មោះអ្នកទោសដែលគេទើបនឹងនាំចូលមកហ្នឹងដែរឬទេ?

**ឆ៖** អត់ចាំទេ។

**ស៖** លោកសាក្សី គឺថាប៉ុន្មានថ្ងៃមុនហេតុការណ៍ហ្នឹង តើលោកឃើញគេនាំអ្នកទោសចូលមកគុក -- ចូលមកក្នុង -- បានន័យថាគេនាំអ្នកទោសចេញពីមន្ទីរឃុំឃាំងយកទៅសួរចម្លើយដែរឬទេប៉ុន្មានថ្ងៃមុនដែលលោកឃើញហេតុការណ៍ហ្នឹង?

[១៥:១៥:២៨]

**ឆ៖** ឃើញរាល់តែថ្ងៃ។

**ស៖** ខ្ញុំមិនមែនចង់សួររាល់ថ្ងៃទេ ខ្ញុំចង់សួរថា គឺថាលោកនិយាយថា លោកឃើញគេច្រកថង់ប្លាស្ទិកសួរចម្លើយ បានន័យថាមុននឹង មួយថ្ងៃ ពីរថ្ងៃហ្នឹង តើលោកឃើញគេនាំអ្នកទោសចេញពីអគារឃុំឃាំងហ្នឹងយកទៅសួរចម្លើយដែរទេ គឺថាមុនដែលឃើញគេច្រកប្លាស្ទិកមួយថ្ងៃ ពីរថ្ងៃហ្នឹងមានគេយកអ្នកទោសទៅសួរចម្លើយដែរទេ?

**ឆ៖** ឃើញ។

**ស៖** សូមលោករៀបរាប់ថាលោកឃើញអ្វី។ លោកនិយាយថាឃើញ តើឃើញអ្វី?

**ឆ៖** ឃើញនាំទៅសួរចម្លើយរាល់ថ្ងៃ។

**ស៖** ខ្ញុំមិនចង់សួរបែបនេះទេ ខ្ញុំចង់សួរថានៅមួយថ្ងៃមុនដែលលោកឃើញហេតុការណ៍ហ្នឹងថា តើលោកឃើញ ឬក៏លោកចាំថាតើអ្នកទោសដែលគេយកទៅសួរចម្លើយហ្នឹងមានលក្ខណៈបែបណាដែរ? តើលោកឃើញអ្នកទោសហ្នឹងមានស្ថានភាពបែបណា? គឺមួយថ្ងៃមុនពេលដែលលោកឃើញគេច្រកថង់ប្លាស្ទិកហ្នឹង?

[១៥:១៦:៤៨]

**ឆ៖** ខ្ញុំឃើញគេនាំយកទៅច្រកថង់ប្លាស្ទិកហ្នឹង គឺមនុស្សរាងធាត់មិនស្គមមិននេះ គេខ្ទាចខ្ទាំងគេដាក់បង្អន់កម្លាំងឱ្យកុំឱ្យរត់ទៅ ហើយគេដើម្បីសួរចម្លើយ។ ហើយអ្នកនោះរឹងទទឹងមិនឆ្លើយ គឺត្រូវតែច្រកអ៊ីចឹង។

**ស៖** ដូច្នេះលោកនិយាយថាម្នាក់ហ្នឹងរាងធាត់បន្តិច។ តើលោកអាចប្រាប់ឱ្យរៀងលម្អិតជាងហ្នឹងតិចទេ ក្រៅពីត្រឹមតែថាធាត់បន្តិចហ្នឹង តើលោកមានចាំថាមានអ្វីផ្សេងទៀតទេ?

**ឆ៖** អត់មានអ្វីផ្សេងទៀតទេ។

**ស៖** តើគាត់ខ្ពស់ ឬក៏ទាប តើម្នាក់នោះជាបុរស ឬមួយជានារី?

**ឆ៖** រាងខ្ពស់ល្មម បុរស។ ស្ត្រីគេមិនដែល -- កម្រសួរចម្លើយណាស់។

**ស៖** តើលោកចាំថាលោកធ្លាប់ឃើញបុរសម្នាក់ដែលធាត់ ប៉ុន្មានថ្ងៃមុននៅក្នុងពេលដែលគេយកគាត់មកធ្វើទារុណកម្មច្រកប្លាស្ទិកហ្នឹង មានធ្លាប់ឃើញគាត់ពីមុនមកទេ?

**ឆ៖** ខ្ញុំមិនបានឃើញទេ អត់ដែលស្គាល់ទេមនុស្សហ្នឹង។

[១៥:១៨:៤៦]

**ស៖** អ៊ីចឹងមានន័យថាលោកឃើញគាត់ ចង់និយាយថា ឃើញគាត់ដំបូងនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំឃើញពេលខ្ញុំដើរចេញពីកន្លែងដេកទៅយកក្រសាំងឱ្យគេស្ល។ ពេលគេសួរចម្លើយ ពេលហ្នឹង ខ្ញុំឃើញពេលហ្នឹងទេ។

**ស៖** អ៊ីចឹងបានន័យថាបុរសម្នាក់ហ្នឹង គឺជាមនុស្សម្នាក់គត់ដែលលោកឃើញនៅព្រឹកនោះ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកចាំទេថាលោកឃើញគាត់ហ្នឹងនៅប្រហែលពេលណាដែរ? ម៉ោងប៉ុន្មានដែរ?

**ឆ៖** ម៉ោងប្រាំបួនព្រឹក។

**ស៖** តើលោកឃើញមុនពេលស្រស់ស្រូបអាហារពេលព្រឹក អ៊ីចឹងមែនទេ -- ក្រោយពេលលោកស្រស់ស្រូបអាហារពេលព្រឹក។ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំឃើញពេលខ្ញុំយកផ្លែក្រសាំងឲ្យគេស្ល។ ខ្ញុំឃើញពេលហ្នឹងម៉ោងប្រាំបួនព្រឹក។ អត់មានអាហារណាស្រូបស្រស់ទេពេលព្រឹក នៅកន្លែងមន្ទីរឃុំឃាំងនោះ!

**ស៖** តើលោកអាចពន្យល់ប្រាប់ខ្ញុំបន្តិចបានទេ តើលោកទៅណា? បានន័យថាលោកដើរពីចំណុចណា ទៅចំណុចណាយកផ្លែហ្នឹង? ខ្ញុំមិនយល់ច្បាស់ ថាតើលោកឃើញបុរសហ្នឹងដោយរបៀបណា? ចង់និយាយថា លោកដើរពីណាដល់ណា យកផ្លែឈើហ្នឹងទៅឲ្យគេហ្នឹង?

**ឆ៖** ខ្ញុំទៅបេះផ្លែក្រសាំងហើយ ក៏គេហៅឲ្យយកផ្លែក្រសាំងទៅចង្ក្រានបាយ។ ចង្ក្រានបាយហើយ ខ្ញុំក៏គេឲ្យទៅពុះឧសកៀនហ្នឹង។ រើសឧសយកមកដុតដាំបាយហ្នឹង ហើយក៏ខ្ញុំងាកឃើញមនុស្សហ្នឹងកំពុងតែច្រកស្បោងកៅស៊ូ រុំ។ តែប៉ុណ្ណឹងទេ!

[១៥:២១:១៩]

**ស៖** លោកសាក្សី ខ្ញុំព្យាយាមឲ្យច្បាស់ខ្លួនឯង ថាតើលោកឃើញបុរសហ្នឹងដែលគេច្រកថង់ប្លាស្ទិកហ្នឹងនៅជាមួយអ្នកដទៃទៀត ឬមួយក៏គាត់នៅតែម្នាក់ឯងទេ?

**ឆ៖** នៅជាមួយពួកឆ្មាំគុក ពេលគេសួរចម្លើយ។ អត់មានអ្នកដទៃ។

**ស៖** អ៊ីចឹងគាត់ជាអ្នកទោសតែម្នាក់ទេនៅថ្ងៃហ្នឹង ដែលលោកឃើញនៅបរិវេណគុកហ្នឹង។ តើអ៊ីចឹងមែនទេ ជាអ្នកទោសតែម្នាក់មែនទេ?

**ឆ៖** ឃើញកន្លែងសួរចម្លើយតែម្នាក់ទេ គេសួរតែម្តងម្នាក់ទេ គេអត់ម្តង សួរបួនប្រាំទេ សួរតែមួយៗ។

**ស៖** ខ្ញុំចង់សួរថា លោកឃើញគាត់ហ្នឹង គឺបានន័យថាគាត់ហ្នឹងគឺជាអ្នកទោសតែម្នាក់ដែលដើរនៅក្នុងបរិវេណគុកហ្នឹង។ តើមែនទេ?

**ឆ៖** ខ្ញុំដើរយករបស់របរ ផ្លែឈើទៅឲ្យគេស្លស្លុកអ៊ីចឹងទៅ វាត្រូវប្រទេះភ្នែកឃើញ គេប្រើយកឧសទៅដុតក្បែរចង្ក្រានទៀត ខ្ញុំក៏ងាកទៅឃើញ ឃើញតែម្នាក់ មានអ្នកដទៃណាមកមើលឃើញមានតែបុគ្គលិកគេធ្វើការក្នុងហ្នឹងគេឃើញ។ ត្រង់ខ្ញុំអ្នកដទៃទៀត មិនអាចទៅមើលឃើញទេ ព្រោះគេក្រៅពីនោះ គេធ្វើការផ្សេងហើយ ព្រោះគេទុកចិត្តខ្ញុំ បានគេឲ្យខ្ញុំយករបស់របរចូលកន្លែងចង្ក្រានបាយ

ទៀតនោះ។ កន្លែងចង្ក្រានគេជាងចង្ក្រានបាយស្ដេចទៀត មិនមែនដែលធ្វើលេងៗទេ តែមិនទុកចិត្ត គេមិនឲ្យចូលជិតទេ។

[១៥:២៣:៤៣]

**ស៖** អ៊ីចឹងបុរសដែលលោកនិយាយថា រាងធាត់បន្តិចហ្នឹង តើគាត់ដើរទៅតែម្នាក់ឯង ឬក៏មានគេបណ្ដើរគាត់ទៅ?

**ឆ៖** មានឆ្មាំគុកគេបណ្ដើរទៅ។ គេសួរអស់ចិត្តហើយ បានគេច្រកថង់កៅស៊ូ។

**ស៖** លោកសាក្សី ខ្ញុំចង់ឲ្យលោកឆ្លើយតបខ្ញុំបន្តិច តើលោកដឹងថា អ្នកណាជាអ្នកបណ្ដើរបុរសដែលធាត់បន្តិចហ្នឹង បណ្ដើរទៅហ្នឹង តើអ្នកដែលបណ្ដើរទៅហ្នឹងជាអ្នកណា?

**ឆ៖** គេជានគរបាលនៅកន្លែងនោះ គេអនុរក្សឃាតកម្មមនុស្ស អ្នកសម្លាប់មនុស្ស អ្នកសួរចម្លើយហ្នឹងម្ដង គឺឈ្មោះ ចេង។

**ស៖** អ៊ីចឹងបានន័យថា ចេង គឺជាអ្នកបណ្ដើរអ្នកទោសហ្នឹងទៅ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** លោកឃើញថាគេបណ្ដើរទៅ តើពួកគេដើរទៅណា?

**ឆ៖** ដើរទៅត្បូង ទៅកន្លែងសួរចម្លើយ។

**ស៖** អ៊ីចឹងបន្ទាប់មក មានអ្វីកើតឡើងទៀត?

**ឆ៖** បន្ទាប់មកកើតឡើង គេសួរបន្តទៀត គេដកស្បោងចេញ គេសួរបន្តទៀត អ្នកនោះឆ្លើយលែងរួច វាទន់ខ្លួន គេអូសយកមកដាក់ឃុំឃាំងវិញមក។

**ស៖** លោកសាក្សី ខ្ញុំចង់ឲ្យលោកនិយាយឲ្យច្បាស់បន្តិចបាទ។ គឺថាលោកឃើញគេបណ្ដើរអ្នកទោសទៅសួរ បន្ទាប់មកទៀតគេនាំអ្នកទោសចូលទៅក្នុងបន្ទប់ ឬក៏ក្នុងរោងសួរចម្លើយ។ នៅពេលដែលគេនាំអ្នកទៅដល់ក្នុងរោងសួរចម្លើយ ហើយមានសកម្មភាពអីបន្តទៅទៀត?

**ឆ៖** ទៅដល់គេឲ្យអង្គុយ គេវាយចាប់ខ្នោះដៃគេដាក់ខ្នោះ ពេលគេសួរទៅគេដាក់ខ្នោះដៃអ៊ីចឹងតែម្ដង។ ដល់ហើយគេសួរចម្លើយ សួរចម្លើយបើអ្នកណារឹងគឺត្រូវដំបង បើដំបងហើយមិនឆ្លើយទៀតគេច្រកស្បៀងកៅស៊ូហ្នឹង ប៉ុនពេលច្រកស្បៀងកៅស៊ូ ខ្ញុំឃើញតែម្នាក់ហ្នឹងទេ ខ្ញុំអត់ -- ហើយពីហ្នឹងខ្ញុំលែងតាមដានទៀតហើយ ព្រោះឃើញដូចស្រស់ៗពេក ខ្ញុំញាក់សាច់ ខ្ញុំលែងហ៊ានមើល។

[១៥:២៧:០២]

**ស៖** លោកសាក្សី ខ្ញុំហាក់ដូចជាស្តាប់មិនច្បាស់ អ៊ីចឹងលោកឃើញថាអ្នកនាំហ្នឹងបណ្តើរអ្នកទោសចូលទៅក្នុងរោងហ្នឹង តើបន្ទប់ហ្នឹងមានទ្វារបិទជិតអត់ទេ? ហើយលោកឈរនៅកន្លែងណា? លោកឮអីដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាទាន់ឆ្លើយតប។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់អ្វីទេដែលមេធាវីការពារក្តីបានចំណាយពេលដើម្បីសួរលម្អិតអំពីហេតុការណ៍ដែលកើតឡើងកន្លងយូរណាស់មកហើយហ្នឹង ប៉ុន្តែខ្ញុំគិតថាខ្ញុំមិនចង់ឲ្យមេធាវីការពារក្តីនាំខុសទៅដល់សាក្សី ទាក់ទងទៅនឹងភស្តុតាងដោយសារតែវាមិនមាន -- ដោយសារតែរោងនោះវាមិនមានទ្វាទេ វាជារោងចំហមួយ។ ដូច្នេះ ខ្ញុំសង្ឃឹមថាមេធាវីការពារក្តីមិននាំព័ត៌មានខុស ឬ បង្ហាញព័ត៌មានខុសនោះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណ ខ្ញុំនឹងបន្តទៅមុខទៀត។ អ៊ីចឹងបានន័យថាអ្នកឆ្មាំគុកហ្នឹងនាំអ្នកទោសហ្នឹងចូលទៅ។ ហើយចង់សួរថាតើលោកឈរនៅកន្លែងណាដែរ នៅពេលគេនាំអ្នកទោសចូលទៅក្នុងរោងនោះ?

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំឈរនៅទិសព្លសានខាងកើត ព្រោះរោងបាយគេនៅខាងកើតធៀងព្លសាន។ កន្លែងសួរចម្លើយប្រហែលពីនេះទៅទ្វារ ចម្ងាយប្រហែល២០ម៉ែត្រចុះ។

[១៥:២៨:៥៨]

**ស៖** អ៊ីចឹងបានន័យថាលោកឈរនៅក្បែរ ហើយលោកឃើញអ្វីដែលកើតឡើងនៅទីនោះ។ អ៊ីចឹងបានន័យថា លោកអាចមើលឃើញទាំងអស់នៅក្នុងរោងសួរចម្លើយហ្នឹងអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំឃើញទាំងអស់។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេថាតើឆ្មាំហ្នឹងសួរ -- គាត់អង្គុយនៅកន្លែងណា? ហើយអ្នកសួរចម្លើយហ្នឹងគេអង្គុយនៅកន្លែងណា? តើតុកៅអីហ្នឹងយ៉ាងម៉េចដែរ? លោកអាចប្រាប់អំពីស្ថានភាពរបស់តុកៅអីនៅកន្លែងសួរចម្លើយហ្នឹងបានដែរឬទេ?

**ឆ៖** តុគេអង្គុយ តុដាក់ពីមុខមួយ ហើយតុអង្គុយពីរ ហើយអ្នកទោសគេឲ្យអង្គុយកៅអីមួយ ហើយអ្នកឆ្មាំសួរ -- ចាំវ៉ៃឈរពីចំហៀងរបស់អ្នកទោស ហើយមេគេចាប់ផ្ដើមសួរចម្លើយ។

**ស៖** អ៊ីចឹងបានន័យថា លោកអាចមើលឃើញពួកគេអង្គុយចុះ ហើយចាប់ផ្ដើមសួរចម្លើយ គឺសួរចម្លើយទៅអ្នកទោស។ អ៊ីចឹងលោកអាចឃើញអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែន។

**ស៖** តើគេប្រើអង្គុលីលេខ ឬក៏គេប្រើប៊ិកដើម្បីកត់ត្រាចម្លើយនោះ?

**ឆ៖** ប្រើប៊ិក។

**ស៖** តើគេប្រើប៊ិកហ្នឹង ប្រើដោយ -- តើអ្នកណាជាអ្នកប្រើប៊ិកសរសេរចម្លើយនោះ?

**ឆ៖** ពេលនោះអនុប្រធានគេឈ្មោះ ឱម ពេញ។ ផៃ អាន់ អ្នកសួរចម្លើយ។

**ស៖** តើលោកស្ដាប់ឮពីចម្ងាយបានទេ ស្ដាប់ឮសួរគេសួរចម្លើយពីចម្ងាយ លោកស្ដាប់ឮទេ?

**ឆ៖** ពេលគេសួរឮដែរ មិនមែនថាអត់ឮទេ បើគេសួរខ្លាំង គេមិនមែនសួរតិចណា។ គេសួរថា "អ្អែង ធ្វើអី?" អ្នកទោសវាឆ្លើយថា "ខ្ញុំអត់ធ្វើអី"។ "អ្អែងរឹង។ អ្អែងធ្វើស័ក្តិ៥ ឬអ្អែងធ្វើសេ.អ៊ី.អា អាមេរិកកាំង ឬសេ.អ៊ី.អា យួន?" គេសួរតែប៉ុណ្ណឹង។ "បើអ្អែងមិនឆ្លើយអញវ៉ៃ"។

**ស៖** លោកចាំទេ លោកសាក្សី អ្នកគេសួរចម្លើយហ្នឹងសំណួរដំបូងបំផុតហ្នឹងលោកស្ដាប់ឮគេសួរថាម៉េចដែរ?

**ឆ៖** ខ្ញុំមិនបានចាំអស់ទេ ព្រោះអានេះពីចម្ងាយ គ្រាន់តែខ្ញុំចាំពាក្យគេសួរសំណួរថា "អ្អែងធ្វើអីជំនាន់លន់នល់? អ្អែងស័ក្តិប៉ុន្មានៗ" សួរតែប៉ុណ្ណឹងទេ។ ខ្ញុំដឹងចាំតែប៉ុណ្ណឹង។

[១៥:៣២:២១]

**ស៖** លោកសាក្សី ខ្ញុំសុំឲ្យលោកគិតបន្តិចមើល៍ លោកមានចាំសំណួរណាផ្សេងទៀតទេ។ អាចចាំបានទេ សំណួរដែលគេសួរនៅពេលនុ៎ង?

**ឆ៖** ពេលគេសួរ ជួនណា អ្អែងធ្វើការអី បាក់នង្គ័ល លួចដំឡូង លួចមាន់ លួចអ្វីៗផ្សេងទៀតទៅ អ្អែងប្រឆាំងនឹងសហករណ៍ អ៊ីចឹងទៅ។ គេសួរគ្រប់ជំពូកទាំងអស់។ ខ្ញុំមិនចាំបានអស់ទេ ព្រោះអានេះវាកាលកន្លងហួសយូរដែលហើយ។ បើគេសួរសំខាន់បំផុតរឿង សេ.អ៊ី.អា យួន ហើយអាមេរិកាំងតែប៉ុណ្ណឹង។

**ស៖** លោកសាក្សី លោកអាចឆ្លើយជាទូទៅបាន។ ខ្ញុំសួរថាតើលោកមានចាំសំណួរជាក់លាក់

ណាខ្លះទៀតទេ ដែលអ្នកគេសួរចម្លើយបានសួរទៅអ្នកទោសហ្នឹង?

**ឆ៖** ខ្ញុំចាំច្បាស់គ្រាន់តែគេសួរ "អ្នែងធ្វើអី?" "សក្តិប៉ុន្មាន?" តែប៉ុណ្ណឹងទេ ខ្ញុំចាំច្បាស់តែប៉ុណ្ណឹង។

**ស៖** ចុះអ្នកទោសឆ្លើយថាដូចម្តេចដែរ?

**ឆ៖** អ្នកទោសខ្លះវាឆ្លើយតាមត្រង់ ខ្លាចឈឺដំបងចេះតែថា ស័ក្តិ៥ ស័ក្តិ -- ផ្កាយមួយ អ៊ីចឹងទៅ អាហ្នឹងតាមគេឈឺដំបងអី ខ្លាចគេវ៉ៃ ចេះតែឆ្លើយហើយ។ ហើយ "គ្នាអ្នែងនៅប៉ុន្មាននាក់ៗ" គេសួរ អ៊ីចឹងទៅទៀតទៅ។ "គ្នាអ្នែងនរណាខ្លះ?" ហើយទៅចាប់អ្នកហ្នឹងមកទៀតមក។

**ស៖** នេះមិនមែនជាសំណួររបស់ខ្ញុំទេ។ បុរសដែលធាត់បន្តិចហ្នឹង តើគាត់បានឆ្លើយថា គាត់មានបុណ្យស័ក្តិ ឋានន្តរសក្តិប៉ុនណាដែរ?

**ឆ៖** គាត់លែងឆ្លើយរួចហើយអាហ្នឹង ព្រោះអីគេដាក់ច្រកស្បោងដល់ទន់ខ្លួន ដល់គេយកទៅដាក់ពន្ធនាគារ គាត់ស្លាប់វិញហើយ គាត់លែងឆ្លើយរួច គាត់រឹងអត់ឆ្លើយបានគេច្រក។

[១៥:៣៤:៥៩]

**ស៖** លោកសាក្សី តើសាក្សីហ្នឹងគឺគេច្រកហ្នឹង ច្រករយៈពេលប៉ុន្មានដែរមុននឹងឲ្យទៅបន្ទប់វិញហ្នឹង?

**ឆ៖** ច្រកមិនដឹងប៉ុន្មាននាទី ខ្ញុំអត់ដឹងនាទី ឬកំណត់ម៉ោងទេ ខ្ញុំអត់ដឹង ព្រោះឃើញដល់ពេលនេះគេអូសយកទៅដាក់ក្នុងពន្ធនាគារវិញ ស្អែកឡើងឃើញអូសម្នាក់ហ្នឹងទៅកប់។

**ស៖** លោកសាក្សី លោកឈរនៅក្នុងបរិវេណគុកហ្នឹង លោកមើលឃើញគេយកអ្នកទោស មកកាន់តុសួរចម្លើយ ហើយគេក៏សួរចម្លើយ សំណួរខ្ញុំ គឺសួរថាតើគេសួរចម្លើយហ្នឹងអស់រយៈពេលយូរប៉ុនណាដែរមុននឹងគេច្រកថង់ប្លាស្ទិកហ្នឹង?

**ឆ៖** តាមអ្នកឆ្លើយលឿនឆ្លើយរហ័ស។ បើអ្នកឆ្លើយលឿនហ្នឹង ហើយចេះតែឆ្លើយទៅគេអត់ច្រក។ បើអ្នកណារឹងទទឹងគេឆ្លើយ -- មិនឆ្លើយ គេវ៉ៃហើយ វ៉ៃហើយវ៉ៃទៀត មិនឆ្លើយបានគេច្រកបន្ត។

**ស៖** បាទនេះមិនមែនជាចម្លើយទៅនឹងសំណួររបស់ខ្ញុំទេ សំណួរខ្ញុំ ថាតើអ្នកយាមពីរនាក់ហ្នឹងគឺគេច្រកថង់ប្លាស្ទិកហ្នឹងរយៈពេលយូរប៉ុន្មានដែរ ប្រាំនាទី ពីរម៉ោង ឬក៏ច្រកថង់ប្លាស្ទិកហ្នឹងពេញមួយថ្ងៃ ឬក៏យ៉ាងម៉េច?

**ឆ៖** គេមិនមែនច្រករាប់ម៉ោងទេ គេច្រកកំណត់នាទីគេ ប៉ុន្តែមិនដឹងប៉ុន្មាននាទី ខ្ញុំអត់ដឹងទេ។

**ស៖** ប្រហែលជាបញ្ហាដោយសារការបកប្រែ។ សំណួរខ្ញុំសួរថាតើ គេសួរប្រហែលជាសំណួរ

ប៉ុន្មានសំណួរដែរ ឬរយៈពេលប៉ុន្មានដែរ មុននឹងច្រកថង់កៅស៊ូទៅអ្នកទោសនោះ?

**ឆ៖** គេសួរតែពីរសំណួរទេ គេសួរថា "អ្អែងធ្វើអី?" និង "អ្អែងស័ក្តិប៉ុន្មាន?" សួរប៉ុណ្ណឹងទេ។

**ស៖** សក្ខីកម្មរបស់លោក គឺថាអ្នកនាទី -- ប្រហែលជាពីរបីនាទី គឺហើយបានអ្នកយាមហ្នឹងក៏យកថង់ប្លាស្ទិកមកច្រកក្បាលគាត់ ដើម្បីឲ្យគាត់ថប់ដង្ហើម។ អ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ។

**ស៖** អ៊ីចឹងតើខ្ញុំអាចសន្និដ្ឋានថាអ្នកទោសដែលនៅខាងក្នុងកន្លែងគេសួរចម្លើយហ្នឹង គឺគេអាចសួរ១០នាទី អ៊ីចឹងមុននឹងគេដាក់ថង់ប្លាស្ទិកអ៊ីចឹង ឬក៏យ៉ាងម៉េចដែរ?

[១៥:៣៨:៣០]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ សាក្សីគ្មានកាតព្វកិច្ចក្នុងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ខ្ញុំសូមរៀបសំណួរឡើងវិញ លោកសាក្សី។ ខ្ញុំចង់សួរថា តើរយៈពេលពិតប្រាកដ រយៈពេលប៉ុនណា មុននឹង ក្រោយពេលគេច្រកថង់កៅស៊ូហ្នឹង រយៈពេលសួរចម្លើយតែម្តង គឺរយៈពេលប៉ុនណាដែរ មុននឹងឲ្យអ្នកទោសទៅបន្ទប់វិញ។

**ឆ៖** មុនច្រកថង់កៅស៊ូ គេសួរប្រហែលជា ២០នាទី ឬ១០នាទីអ៊ីចឹងបានគេច្រក។ សួរហើយសួរទៀតៗ សួរមិនចេញគេច្រក។ ច្រកហើយ គេអង្គុយចាំឆ្លើយ បើមិនឆ្លើយ មនុស្សជិតដាច់ខ្យល់ហើយ គ្នាឆ្លើយយ៉ាងម៉េចរួច។

**ស៖** តើលោកអាចពន្យល់បន្តិចបានទេ ពន្យល់ឲ្យបានលម្អិតបន្តិចបានទេពីការសួរចម្លើយដោយច្រកថង់ប្លាស្ទិកហ្នឹង?

**ឆ៖** ឲ្យខ្ញុំនិយាយលម្អិតយ៉ាងម៉េចទៀត បើខ្ញុំនិយាយច្រំដែល ដដែលៗហើយ បើខ្ញុំថាគេច្រកសួរ ដើម្បីសួរចម្លើយឲ្យឆ្លើយ។ បុគ្គលណាបន្តវេន ធ្វើអីធ្វើអីហ្នឹង គេសួររកអ្នកធ្វើរាជការ ឬមន្ត្រីតូចធំអី គេសួរបន្តអ៊ីចឹងទៅ។ ហើយបើអ្នកច្រកថង់កៅស៊ូ វាទន់កលែងឆ្លើយរួចហើយឲ្យខ្ញុំឆ្លើយម៉េចទៀត?

**ស៖** សំណួររបស់ខ្ញុំ ខ្ញុំសួរជាថ្មីម្តងទៀត។ ថាតើអ្នកយាមគុកច្រកថង់កៅស៊ូ គ្របក្បាលអ្នកទោសហ្នឹង តើគេមានប្រើកម្លាំងបាយយ៉ាងដូចម្តេចដែរក្នុងពេលច្រកថង់កៅស៊ូនោះ ឬក៏គ្រាន់តែច្រក

ច្រកថង់កៅស៊ូ ឬក៏ប្រើកម្លាំងបាយណាផ្សេងទៀត?

**ឆ៖** គេអត់ប្រើកម្លាំងបាយទេ។ ច្រកថង់កៅស៊ូ មិនមែនគ្របច្រកគ្រប់មនុស្សទេ។ មនុស្សណារឹងទទឹងខ្លាំងមិនឆ្លើយ បានគេច្រក។

**ស៖** ម្តងទៀត គឺថាមិន -- លោកមិនឆ្លើយទៅនឹងសំណួរខ្ញុំទេ។ សំណួរខ្ញុំ ថាតើអ្នកយាមពីរនាក់ដែលសួរចម្លើយហ្នឹង គេមានប្រើហិង្សា ប្រើកម្លាំងបាយបង្ខំទៅលើអ្នកទោសហ្នឹងទេ ពេលច្រកថង់កៅស៊ូហ្នឹង?

**ឆ៖** ពេលគេច្រក គេមុន -- គេសួរហើយ គេវាយដំ វាយទាត់ធាក់អ៊ីចឹងទៅ។ ចាប់ក្រចក ចាប់ដៃអ៊ីចឹងទៅ។ ចាប់មួលជង្គង់អ៊ីចឹងទៅ។ គេប្រើហិង្សា បើមិនប្រើហិង្សា អ្នកទោសម៉េចឆ្លើយ។

[១៥:៤២:០៩]

**ស៖** តាមដែលខ្ញុំស្តាប់ឮគឺថា អ្នកសួរចម្លើយហ្នឹង គាត់ទាត់ធាក់អ្នកទោសដែរ។ តើអ្នកណាជាអ្នកទាត់ធាក់អ្នកទោសហ្នឹង? គេទាត់ធាក់របៀបណាដែរ?

**ឆ៖** គេទាត់ ពេលគេទាត់ គេទាត់ពាក់ស្បែកជើងទាត់។ ស្បែកជើងអាម៉េហ្វ៊ក អាមេរិកាំងហ្នឹង ហើយដំបង គេសួរចម្លើយអ៊ីចឹង។

**ស៖** សូមកុំឆ្លើយទូទៅលោកសាក្សី សូមឲ្យឆ្លើយនូវអ្វីដែលលោកឃើញនៅព្រឹកនុង នៅថ្ងៃនុង។ តើអ្នកណាម្នាក់ក្នុងចំណោមអ្នកសួរចម្លើយទាំងពីរហ្នឹង ជាអ្នកទាត់ធាក់អ្នកទោសនុង?

**ឆ៖** តាចេង។

**ស៖** តើគាត់ទាត់ជើងឆ្វេង ឬក៏ទាត់ជើងស្តាំ? ក៏ទាត់ជើងណា លោកចាំទេ?

**ឆ៖** ទាត់ជើងស្តាំ ទាត់ជើងឆ្វេង។ ឈឺអាមួយ ទាត់អាមួយ។

**ស៖** សូមលោកជម្រាបជូនតុលាការបន្តិចមើល៍ តើអ្នកទោសហ្នឹងមានប្រតិកម្មតបតវិញដូចម្តេចដែរ?

**ឆ៖** អត់មានប្រតិកម្មអីតបតទេ មនុស្សដាក់ខ្នោះហើយ។ ប្រតិកម្មតឆ្លើយតបអីរួចទៀតទេនិងមនុស្សជិតដាច់ខ្យល់ហើយ ឲ្យគ្នាតបតយ៉ាងម៉េច!

[១៥:៤៤:០៥]

**ស៖** តើអ្នកទោសមាននិយាយអ្វីអីទេ? ឧទាហរណ៍ថា "ឈប់ធ្វើបាបខ្ញុំ ខ្ញុំគ្មានបុណស័ក្តិអីទេ" អ៊ីចឹងថាសូមលោកឲ្យ ពន្យល់ឲ្យលម្អិតជាងហ្នឹងបន្តិចបានទេ?

**ឆ៖** ខ្លះមាន មានឆ្លើយថា "កុំធ្វើបាបខ្ញុំ" មានខ្លះ។ ខ្លះអត់ទេ រឹងនៅមិនខ្វីមាត់ហ្នឹងហ្នង។ សុខចិត្តខាំមាត់សង្កត់ចិត្ត ធ្វើគធ្វើថ្លង់។ គេវាយយ៉ាងណា ក៏អត់ឆ្លើយដែរ។ ខ្លះមានថា "កុំធ្វើបាបខ្ញុំ"។ ចេះតែឆ្លើយទៅ។

**ស៖** ចម្លើយនេះមិនទាន់ឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ។ ថាតើអ្នកទោសហ្នឹងមានប្រតិកម្មយ៉ាងដូចម្ដេចដែរ? គាត់និយាយថាម៉េចទៅវិញដែរ នៅពេលគេទាត់ធាក់គាត់នុង?

**ឆ៖** អត់មានប្រតិកម្មអីទេ នៅស្ងៀម។

**ស៖** តើគាត់មាននិយាយ មាននិយាយអីខ្លះដែរទេលោក ពេលគេធ្វើបាបគាត់ហ្នឹង? ពេលគេសួរចម្លើយប្រើហិង្សាទៅលើគាត់ហ្នឹង?

**ឆ៖** ពេលដំបូងគាត់ឆ្លើយ ឆ្លើយថា "ខ្ញុំអត់ធ្វើអី។ ខ្ញុំធ្វើតែអ្នកធាក់ស៊ីក្លូ អ្នកបើកឡានអីចឹងទៅ" ហើយគេមិនជឿ មានតែវាយការណ៍ប្រាប់គាត់អីចឹងទៅ។

**ស៖** តើអ្នកសួរចម្លើយហ្នឹងគេថាម៉េចដែរ នៅពេលដែលអ្នកទោសឆ្លើយថាដូចលោករៀបរាប់អម្បាញ់មិញហ្នឹង?

**ឆ៖** គេមិនជឿ គេបន្តការសួរចម្លើយបន្តទៀតថា "អ្នែងធ្វើ ស៊ី.អ៊ី.អា អាមេរិកាំង" គេឆ្លើយតបទៅអ្នកទោសអីចឹង។ គេឲ្យបង្ហាញរបាយការណ៍ឲ្យមើលទៀត។

[១៥:៤៦:២០]

**ស៖** តើគេវាយការណ៍ថាម៉េច ការវាយការណ៍ហ្នឹងរបៀបម៉េច លោកចាំទេ?

**ឆ៖** ខ្ញុំអត់ចាំទេ។

**ស៖** ចុះម៉េចបានលោកប្រើពាក្យថា "វាយការណ៍" ម៉េចបានលោកប្រើពាក្យ "វាយការណ៍" យ៉ាងដូច្នេះ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

សូមអធ្យាស្រ័យលោកប្រធាន។ ដោយខ្ញុំបានទទួលសម្ដីលោកពី ខៀវ សំផន ថាគាត់អស់កម្លាំង ហើយគាត់មិនអាចបន្តសវនាការទៅទៀតទេ។ អីចឹង សូមលោកប្រធានមេត្តាពិចារណាថាតើអាចសម្រាកនៅពេលនេះតែម្ដង ឬមួយក៏យ៉ាងម៉េចបាទ សូមអធ្យាស្រ័យ។ សូមអរគុណ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី ថាតើគាត់អាចតាមដានកិច្ចដំណើរការនីតិវិធីនៅបន្ទប់ឃុំខ្លួនខាងក្រោមបានទេ? យើងសល់ពេលតែ១០នាទីទេ លោកមេធាវី ថាតើបន្តបានទេ?

[១៥:៤៨:០៨]

**លោក គង់ សំអុន៖**

បាទ សូមជម្រាបលោកប្រធាន លោក ខៀវ សំផន គាត់ស្នើសុំឲ្យផ្អាក វាអាចល្អសម្រាប់គាត់ ប៉ុន្តែបើសិនជាថា តម្រូវត្រូវតែ ត្រូវបន្តឲ្យគាត់នៅបន្តនៅខាងក្រោមនោះ អាហ្នឹងគាត់នឹងធ្វើតាមនេះ បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវ យើងអង្គជំនុំជម្រះស្តាប់សំណើសុំរបស់ជនជាប់ចោទ ខៀវ សំផន បានស្នើសុំ តាមរយៈមេធាវីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោម សវនាការនេះ ដោយគាត់មានបញ្ហានឿយហត់ បញ្ហាសុខភាព ក្នុងការតាមដានកិច្ចដំណើរការ ហើយ ដោយសារតែពេលវេលានៅសេសសល់ ហើយយើងប្រឹងប្រែងដើម្បីជំរុញល្បឿននៃកិច្ចដំណើរការ សវនាការឲ្យបានប្រសើរនោះ គឺអង្គជំនុំជម្រះយល់ព្រម ហើយនិងអនុញ្ញាតឲ្យលោក ខៀវ សំផន ទៅ ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមសាលសវនាការនេះតាមប្រព័ន្ធ សោតទស្សន៍។ ហើយបង្គាប់ឲ្យមន្ត្រីបុគ្គលិកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ ខៀវ សំផន ក្នុងរយៈពេលចុងម៉ោងនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់ បន្ទប់ឃុំឃាំងខាងក្រោមសាលសវនាការនេះ ដែលរៀបចំសម្រាប់គាត់ ឲ្យគាត់តាមដានកិច្ចដំណើរការ សវនាការនៅម៉ោងចុងក្រោយ។

នាំទៅចុះ!

អញ្ជើញលោក កូប៉េ! សូមផ្តើមសំណួរចុងក្រោយម្តងទៀត។ អំមិញអាចសាក្សីអាចភ្លេច ហើយ។ បាទ សូមអញ្ជើញ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបាននិយាយថា អ្នកសួរចម្លើយបានបង្ហាញរបាយការណ៍ហ្នឹងទៅ តើ ហេតុអីចាំបាច់បង្ហាញរបាយការណ៍ហ្នឹងទៅអ្នកទោសហ្នឹង?

[១៥:៥០:២៣]

**លោក មាស សុខា៖**

**ឆ៖** គេចង់ដឹងរឿង។ គេចង់ដឹងរឿង តើអ្នកឯងធ្វើអីៗ របាយការណ៍គេនៅក្នុងហ្នឹងហើយ គេមិនដឹង? បើមានអ្នករាយការណ៍ពីភូមិមកថា អ្នកនេះធ្វើមន្ត្រីរាជការ ស័ក្តិប៉ុន្មានៗ គេធ្វើសរសេរដាក់ក្នុងហ្នឹងហើយ។

**ស៖** លោកឆ្លើយទូទៅពេកលោកសាក្សី សំណួរខ្ញុំថាហេតុអ្វីបានជាលោកឆ្លើយថា ក្រដាសដែលគេបង្ហាញទៅអ្នកទោសហ្នឹងគឺលោកគិតថាវាជារបាយការណ៍។ ហេតុអីលោកគិតថាវាជារបាយ-ការណ៍?

**ឆ៖** តែខ្ញុំឃើញក្រដាស គឺរបាយការណ៍ហើយ ខ្ញុំមិនថាជាស្អីទេ ព្រោះគេឲ្យអ្នកទោសមើលហើយ។ របាយការណ៍ចម្លើយពីភូមិមក។

**ស៖** ហេតុអីក៏លោកជឿថា ក្រដាសហ្នឹងគឺវាជារបាយការណ៍ដែលគេរាយការណ៍ពីណាៗមកអ៊ីចឹង។ ម៉េចបានលោកជឿជាក់ថាយ៉ាងដូច្នេះ?

**ឆ៖** ខ្ញុំជឿព្រោះមនុស្សសម័យនោះស្លាប់រស់ពីមូលដ្ឋានទៅ អ្នកនៅក្នុងក្រាំងតាចាន់ អ្នកចាំទទួលសម្លាប់ទេ អត់មានពីណាក្រៅពីមូលដ្ឋានភូមិហើយនិងឃុំទេ។

**ស៖** លោកសាក្សីខ្ញុំសួរទៅការសួរ -- ការច្រកថង់ប្លាស្ទិកដើម្បីឲ្យថប់ដង្ហើម។ តើការច្រកថង់ប្លាស្ទិកនេះ គេច្រករយៈពេលយូរប៉ុនណាដែរ?

[១៥:៥២:២២]

**ឆ៖** ខ្ញុំអត់មាននាឡិការវាស់ម៉ោងមើលទេ ព្រោះខ្ញុំឃើញហើយខ្ញុំដើរចេញ ហើយខ្ញុំបានត្រឡប់មកវិញទៀត ត្រឡប់មកយកខសមួយសាទៀត ហើយបានឃើញគេបណ្តើរមនុស្សយកទៅដាក់ពន្ធនាគារវិញហើយ។

**ស៖** តើនៅពេលណាដែរ ដែលឃើញគាត់ត្រឡប់ គេយកគាត់ទៅចូលក្នុងបន្ទប់វិញហ្នឹង?

**ឆ៖** ម៉ោងប្រហែលដប់ថ្ងៃត្រង់។

**ស៖** តើខ្ញុំអាចយល់ខុសឬក៏ត្រូវ ដែលថាការសួរចម្លើយហ្នឹងគឺវាអាចសរុបទាំងអស់ រយៈពេលដល់ អាចដល់មួយម៉ោង ខុសឬក៏ត្រូវ?

**ឆ៖** ត្រូវ។

**សៈ** ចម្លើយរបស់លោកគឺតែ ចម្លើយតែប៉ុណ្ណឹងទេឬ នៅពេលដែលលោកស្ថិតនៅក្នុងពន្ធនាគារ បរិវេណពន្ធនាគារ លោកឃើញសកម្មភាពអស់ហ្នឹង?

[១៥:៥៤:៤៥]

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសុំឱ្យមេធាវីការពារក្តីសួរឱ្យជាក់លាក់បន្តិច។ ការសួរបែបនេះវាមិនច្បាស់លាស់ទេ។ គាត់បានថាគាត់ -- ការដែលឃើញច្រកថង់ប្លាស្ទិកនេះ គឺថាគាត់ឃើញតែម្តងហ្នឹងគត់។ អ៊ីចឹង កុំសួរ --

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសួរសាក្សីរូបនេះ គឺថាគាត់គឺជាអ្នកដែលមានវត្តមាន ហើយបានឃើញបុរសម្នាក់ត្រូវគេច្រកថង់ប្លាស្ទិកដើម្បីសួរចម្លើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** លោកសាក្សី លោកឃើញការច្រកថង់ប្លាស្ទិកបែបហ្នឹង ឃើញតែម្តងហ្នឹងទេឬ?

**ឆៈ** ខ្ញុំឃើញតែម្តងហ្នឹង ហើយពីហ្នឹងខ្ញុំអត់យកចិត្តទុកដាក់ទៀតទេ។

**សៈ** តើមានអ្វីកើតឡើងទៅអ្នកទោសហ្នឹងទៀតនៅពេលគេយកគាត់ទៅដាក់ក្នុងបន្ទប់វិញហ្នឹង?

**ឆៈ** អត់មានកើតអី ឡើងអីទេ ស្អែកឡើងគាត់ស្លាប់បាត់ហើយ គាត់គេអូសយកទៅកប់ហើយ កើតឡើងគឺនៅថ្ងៃទីបញ្ចប់របស់គាត់ហ្នឹងតែម្តង។ គាត់គេវៃគ្រាំគ្រាពេលហ្នឹងពេក ស្អែកឡើងគេអូសយកទៅកប់។

**សៈ** ចុះហេតុធ្វើយ៉ាងម៉េចបានជាលោកដឹងថា ស្អែកឡើងគេអូសយកទៅកប់?

**ឆៈ** --

[១៥:៥៥:៣៥]

**ប្រធានអង្គជំនុំ៖**

កុំអាល មិនមើលដៃទេ! អត់ទាន់ ក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការទេ។ រង់ចាំរហូតដល់ក្បាលមីក្រូហ្វូនប្រតិបត្តិការ សឹមលោកនិយាយដោយភ្លើងក្រហមជាសញ្ញា។

**លោក មាស សុខា៖**

**ឆ៖** ពេលព្រឹកអីចឹង គេប្រើខ្ញុំបើកទ្វារបើកអីចឹង ខ្ញុំឃើញមនុស្សហ្នឹងស្លាប់ហើយ។ ដល់អីចឹង គេហៅ សយ សែន, តាចិន កាប់រណ្ដៅកប់ហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួររបស់ខ្ញុំ គឺបុរសដែលធាត់បន្តិចហ្នឹង តើលោកឃើញសាកសពគាត់ហ្នឹងនៅត្រង់កន្លែងណា?

**ឆ៖** នៅក្នុងអគារគុក។

**ស៖** តើអគារមួយណាដែរ?

**ឆ៖** អគារទី២។

**ស៖** សូមពន្យល់បន្តិចមើល៍ អគារទី២ហ្នឹងលោកចង់និយាយថាម៉េច?

**ឆ៖** អគារទី២ អគារដាក់មនុស្ស វាស្រេចតែគេយកមនុស្សទៅដាក់ក្នុងហ្នឹង មិនបាច់ថាអ្នកណាទោសធ្ងន់ ទោសស្រាលទេ កន្លែងគុកហ្នឹង គេអត់មានរើសទោសធ្ងន់ ទោសស្រាល គឺកន្លែងណាឲ្យតែមានទូលាយសម្រាប់ដាក់មនុស្ស គេយកទៅដាក់ហើយ។

**ស៖** អីចឹងលោកឃើញសាកសពរបស់គាត់ គឺសាកសពរបស់គាត់នៅចន្លោះអ្នកទោសដទៃទៀតអីចឹងហ៎! អីចឹងឬ?

**ឆ៖** នៅចន្លោះអ្នកដេក អ្នកទោសគ្រប់ៗគ្នា។

[១៥:៥៧:៣៣]

**ស៖** ដូច្នេះ លោកអាចមើលឃើញអ្នកទោសដទៃទៀតបាន គឺលោកអាចមើលឃើញអ្នកទោសដទៃទៀតក្នុងអគារបាន។ ថាតើអីចឹងមែនទេ?

**ឆ៖** អាចមើលឃើញរាល់ថ្ងៃ។ ថ្ងៃណាគេប្រើយកទឹកនោម សែងទឹកនោម យកអីចេញទៅចាក់វាលស្រែទៅ អាហ្នឹងឃើញហើយ។ ហើយទឹកនោមមួយថ្ងៃ សែងម្ដង ពីរដង ព្រឹក ល្ងាច។

**ស៖** លោកសាក្សី សូមឆ្លើយឲ្យបានច្បាស់លាស់តែម្ដង ថាតើសាកសពរបស់អ្នកទោសមួយហ្នឹង គេដាក់នៅ -- គាត់ស្លាប់នៅកន្លែងណា?

**ឆ៖** គាត់ស្លាប់នៅក្នុងអគារទី២។

**ស៖** តើសាកសពរបស់គាត់ហ្នឹងគឺពេលស្លាប់ទៅហ្នឹងឃើញនៅកន្លែងណា?

**ឆ៖** នៅអគារទី២ គ្រែខាងត្បូង។

**ស៖** តើស្លាប់នៅលើគ្រែ ឬក៏យ៉ាងម៉េច?

**ឆ៖** លើគ្រែ ជើងជាប់ខ្នោះ។

**ស៖** តើគាត់ស្លាប់ -- ហើយមានអ្នកទោសដទៃទៀតនៅដេកព័ទ្ធជុំវិញគាត់អ៊ីចឹងឬទេ?

**ឆ៖** អ្នកទោស ដេកជុំវិញទាំងអស់ ដេកតម្រៀបគ្នាដូចកូនជ្រូកអ៊ីចឹង ដេកតម្រៀបគ្នាអ៊ីចឹងទៅ។

[១៥:៥៩:៤៦]

**ស៖** តើលោកអាចរៀបរាប់បន្តិចបានទេ ពេលដែលលោកចូលទៅក្នុងអគារហ្នឹង ដែលលោកឃើញតែសាកសពគាត់ហ្នឹងទេ ឬក៏លោកឃើញស្អីទៀត?

**ឆ៖** ឃើញតែសាកសពគាត់ ឃើញតែមនុស្សនៅក្នុងហ្នឹងទាំងអស់។ អ្នកជាប់ទោសនៅទាំងអស់គ្នាដេកតម្រៀបគ្នានៅក្នុងហ្នឹង។

**ស៖** តាមដែលខ្ញុំយល់គឺថា គឺអ្នកទោសហ្នឹងដើរពីកន្លែងសួរចម្លើយចូលទៅក្នុងបន្ទប់របស់គាត់។ នៅពេលដែលគាត់ដើរពីកន្លែងសួរចម្លើយចូលទៅក្នុងបន្ទប់របស់គាត់ តើស្ថានភាពទូទៅរបស់គាត់ហ្នឹងវាយ៉ាងម៉េចដែរ? លោកមើលទៅឃើញសភាពយ៉ាងម៉េចសម្រាប់អ្នកទោសហ្នឹង?

**ឆ៖** ទ្រុឌទ្រោមហើយ ទ្រោមដើរឱន គេគ្រាហើយ គេគ្រាចូលបន្ទប់ហើយ។

**ស៖** តើលោកៗអាចឆ្លើយជូនតុលាការបានទេ ហេតុអីចាំបាច់ដល់មានគេគ្រា?

**ឆ៖** ចុះគេវ៉ៃឡើងទន់ខ្លួនហើយៗ ពេលទន់ខ្លួនអ៊ីចឹង គាត់ដើរលែងរួចហើយ ព្រោះវ៉ៃមនុស្សអត់បាយពីរបីពេលទៅហើយ។ ហើយណាមួយហេវផង ណាមួយត្រូវដំបងផង ណាមួយដៃជាប់ខ្នោះផង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

[១៦:០១:៣៤]

**លោក គង់ សំអុន៖**

សូមគោរពលោកប្រធាន សូមអធ្យាស្រ័យ សូមរំខានម្តងទៀត។ តាមការនាំពាក្យរបស់មន្ត្រីរបស់យើងពីខាងក្រោមអម្បាញ់មិញនេះថា ពេទ្យបានបញ្ជាក់ថាសម្ពាធឈាមរបស់លោក ខៀវ សំផន

ឡើងខ្ពស់ ហើយគាត់អស់កម្លាំងខ្លាំង ហើយគាត់មិនអាចបន្តតាមដាននៅខាងក្រោមទេ។ បើអ៊ីចឹងសូមលោកប្រធានផ្អាកសវនាការ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះត្រូវដល់ម៉ោងដែលត្រូវសម្រាកដែរហើយនៅល្ងាចនេះ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ព្រឹកថ្ងៃនេះត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី មាស សុខា ហើយនិងបន្តមកទៀតអង្គជំនុំជម្រះនឹងបន្ត -- នឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-296 សូមភាគីនិងសាធារណជនជ្រាប។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ទៅចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*